ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ភាតពូកិច្ចសីលធម៌ ក្នុងអំឡុងពេលនៃជំងឺរាតត្បាតពាសពេញពិភពលោក ការចងចាំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺជាការក្រើនរំឭកយើងទាំងអស់គ្នាអំពីភាតពូកិច្ចសីលធម៌ចំពោះមនុស្សជាតិ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៤៤ ខែមេសា ឆ្នាំ២០២០

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨៤ ខែមេសា ឆ្នាំ២០២០

# មាតិកា

**សំបុត្រ**

◆ កាតព្វកិច្ចសីលធម៌ ក្នុងអំឡុងពេលនៃ ........១

**ផ្នែកឯកសារ**

◆ សឹង ក្លឿល ហៅ នីន ជនជាតិទំពួន............ ៤
◆ ខ្ញុំក្លាយជាជនបដិវត្តន៍តាមឪពុកខ្ញុំ............ ៨

**ផ្នែកប្រវត្តិសាស្ត្រ**

◆ ជីវិតគ្រួសារខ្ញុំក្រោយថ្ងៃជម្លៀស ........... ១៤
◆ រស់ ស៊ីថាត និង កែ ពក.................... ១៨
◆ បូជាភ្លើង ..................................... ២០

**ផ្នែកច្បាប់**

◆ សាលក្រមសំណុំរឿង០០២/០២ ........... ៣៣

**ផ្នែកវេទិកាសាធារណៈ**

◆ ១៧ មេសា គឺជាថ្ងៃនៃការចាប់ផ្តើម .........៤០

**ផ្នែកស្រាវជ្រាវរកគ្រួសារ**

◆ «ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
◆ កុក សារឿន ៖ អនុសេនីយ៍ឯក.............. ៤៣
◆ ខៀវ នឿន ៖ អនុសេនីយ៍ទោ ................ ៤៥
◆ វីង វន ៖ ពលទាហាន ..................... ៤៧
◆ ហេង សុជាណា ៖ ពលបាលទោ ...........៤៩
◆ អ៊ុក គាត ៖ អនុសេនីយ៍ទោ.................៥២
◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់............. ៥៥



យោធាខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧/៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះ៖** ឆាំង យុ, ហេឌី ប្រាយ, ប៉ាង ពីរ័ត្ន, វេនី ខកហ្គៀល, វ៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ថុនា,ដារ៉ាវរដ្ឋ មេត្តា, អ៊ុន សុដារី **អ្នកបកប្រែ៖** អ៊ុន សុដារី
**និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ថុនា
**ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង ពៃង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ភាគព្វកិច្ចសីលធម៌ ក្នុងអំឡុងពេលនៃជំងឺរាតត្បាតពាសពេញពិភពលោក

## ការចងចាំរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺជាការក្រើនរំឭកយើងទាំងអស់គ្នាអំពីភាគព្វកិច្ចសីលធម៌ចំពោះមនុស្សជាតិ

**ឆាំង យុ**



*អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជួបជុំគ្នា នៅខែមករា ឆ្នាំ១៩៧៩ នៅមុខព្រះរាជដំណាក់ នៅខេត្តសៀមរាប ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

កាលពីប៉ុន្មានសប្តាហ៍មុន ខ្ញុំបានធ្វើដំណើរទៅកាន់ទីជនបទជាច្រើននៅក្នុងប្រទេសកម្ពុជា។ ខ្ញុំបានធ្វើដំណើរនៅតាមទីជនបទនៃខេត្តកណ្តាល កំពង់ចាម ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន កោះកុង បន្ទាយមានជ័យ និងសៀមរាប នៅក្នុងអំឡុងពេលនៃជំងឺរាតត្បាតកំពុងកើតមានឡើងនៅជុំវិញពិភពលោក និងនៅមុនពេលដែលប្រទេសកម្ពុជាចេញបម្រាមគោចររបស់ខ្លួន។ អ្វីៗដែលខ្ញុំសង្កេតឃើញនៅក្នុងអំឡុងពេលធ្វើដំណើរ និងក្រោយពីខ្ញុំបានត្រឡប់មក

ភ្នំពេញវិញ បានធ្វើឲ្យខ្ញុំនឹកឃើញដល់ពេលវេលាដ៏ខ្មៅងងឹត ដ៏គួរឲ្យសោកសង្រេង និងប្រកបដោយសោកនាដកម្មជាងនេះទៅទៀត កាលពីសម័យខ្មែរក្រហម ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ខ្ញុំគឺមិនមែនជាជនរងគ្រោះតែម្នាក់ឯងនោះទេ។

ខ្ញុំបានជួបនិយាយជាមួយស្ត្រីម្នាក់ដែលជាអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម ហើយក៏ដូចទៅនឹងអ្នកភូមិដទៃទៀតដែលខ្ញុំបាននិយាយជាមួយដែរ ស្ត្រីរូបនេះមានអារម្មណ៍ភ័យខ្លាចចំពោះជំងឺរាតត្បាតជាសកលនេះ ដែលកំពុងជ្រៀតចូលមកក្នុងប្រទេសកម្ពុជា។ គាត់ចាប់អារម្មណ៍ចង់ដឹងអំពីគំនិតរបស់ខ្ញុំទាក់ទងនឹងស្ថានការណ៍នេះ។ គាត់បានសួរខ្ញុំតែមួយសំណួរ ហើយដែលបានធ្វើឲ្យខ្ញុំនៅឈរទ្រឹង ជាមួយនឹងការឆ្លើយតបទៅគាត់ដែលគ្រាន់ត្រឹមតែជាភាពស្ងៀមស្ងាត់តែប៉ុណ្ណោះ។

គាត់បានសួរខ្ញុំថា៖ «ហេតុអ្វីបានជាពិភពលោកជ្រួលច្របល់ម្ល៉េះ? ឥឡូវនេះ ប្រទេសកម្ពុជា គ្មានមនុស្សស្លាប់ដោយសារជំងឺកូវីដណានេះទេ ហើយអត្រាអ្នកស្លាប់នៅសហរដ្ឋអាមេរិក គឺមានត្រឹមប្រមាណជាង ០,០០៧ ភាគរយតែប៉ុណ្ណោះ។ នៅក្នុងរបបខ្មែរក្រហម ក្រៅពីតួលេខមនុស្សដែលត្រូវបានសម្លាប់ជារៀងរាល់ថ្ងៃ យើងឃើញមនុស្សជាច្រើនទៀត ដែលបានធ្លាក់ខ្លួនឈឺរហូតដល់ស្លាប់ អ្នកដែលគ្មានអាហារហូបចុក ហើយប្រជាជនជាច្រើនម៉ឺននាក់រងគ្រោះដោយសារជំងឺរាតត្បាតថែមទៀតផងនៅពេលនោះ ក៏ប៉ុន្តែហាក់ដូចជាគ្មានប្រទេសណាបានខ្វល់ខ្វាយពីយើងទេ រហូតទាល់តែយើងបាត់បង់មនុស្សអស់ជាងបីលាននាក់។ តើវាយ៉ាងម៉េចរឿងនេះ?»

ខ្ញុំមិនអាចឆ្លើយតបបានទៅនឹងអ្វីដែលគាត់សួរនោះទេ ពីព្រោះថាខ្ញុំមិនអាចផ្តល់ចម្លើយសមហេតុសមផលណាមួយដល់គាត់។ សំណួររបស់គាត់ បានបង្ហាញអំពីគម្លាត កំហុសឆ្គង និងភាពបរាជ័យរបស់សហគមន៍អន្តរជាតិពីអតីតកាល។ សំណួរនេះ ក៏បង្ហាញអំពីការឈឺឆ្អាល ដែលជាកាតព្វកិច្ចសីលធម៌របស់យើងចំពោះមនុស្សជាតិទៀតផង។

ក្រោយវិលត្រឡប់មកពីការធ្វើដំណើរនេះវិញ ខ្ញុំចាប់ផ្តើមភ្ញាក់ផ្អើលអំពីរបៀបដែលវិបត្តិសង្គមបែបនេះបានបង្ហាញពីការគិត ការប្រព្រឹត្ត និងការឈឺឆ្អាលរបស់យើងចំពោះអ្នកដទៃ។ បើទោះជាវិបត្តិនេះកើតឡើងនៅក្នុងកម្រិតបុគ្គល សហគមន៍ ឬសង្គមក៏ដោយ វិបត្តិនេះគួរត្រូវបានចាត់ទុកថា ជាឱកាសក្នុងការបង្ហាញអំពីភាពជាអ្នកដឹកនាំ និងឥរិយាបថដែលប្រកបដោយសីលធម៌។ ជំងឺរាតត្បាតជាសកលនេះ បានក្លាយទៅជាការព្រួយបារម្ភរបស់មនុស្សគ្រប់ស្រទាប់វណ្ណៈនៅក្នុងសង្គម ក៏ប៉ុន្តែកាតព្វកិច្ចសីលធម៌របស់យើងចំពោះមនុស្សជាតិមិនគួរប្រែប្រួលនោះទេ។

វិបត្តិនេះផ្តល់ឱកាសដល់បុគ្គល អាជីវកម្ម និងរដ្ឋាភិបាល ក្នុងការបង្ហាញសច្ចភាពចំពោះគោលការណ៍គ្រឹះរបស់ខ្លួន និងភាពស្មោះត្រង់ចំពោះប្រជាជនដែលកំពុងតែពឹងផ្អែកមកលើខ្លួន។ រដ្ឋាភិបាលគួរតែបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះការពិតនិងការថែទាំប្រជាជនរបស់ខ្លួន ដោយចាប់ផ្តើមចេញពីការធានាឲ្យបានថា ប្រជាជនទាំងអស់ទទួលបានព័ត៌មានគ្រប់គ្រាន់ដើម្បីការពារខ្លួន និងគ្រួសារ។ ការពិត គឺមិនគួរត្រូវបិទបាំង កែសម្រួល ឬរឹតត្បិតនោះទេ ខណៈពេលដែលជីវិតមនុស្សម្នាក់ៗស្ថិតក្នុងភាពគ្រោះថ្នាក់។

អាជីវកម្មគួរតែបង្ហាញថា សម្ព័ន្ធភាពរបស់ខ្លួនជាមួយអតិថិជន សាធារណជន និងដៃគូខ្សែចង្វាក់ផ្គត់ផ្គង់ គឺមិនមែនធ្វើឡើងសម្រាប់តែប្រាក់ចំណេញ និងការទូទាត់បំណុលជាទៀងទាត់នោះទេ។ គ្រប់អាជីវកម្មទាំងអស់ពឹងផ្អែកលើរបស់ដែលមិនអាចកាត់ថ្លៃបានមួយនោះគឺ កេរ្តិ៍ឈ្មោះ និងរបៀបដែលអាជីវកម្មនីមួយៗអនុវត្តចំពោះអតិថិជន សាធារណជន និងដៃគូរបស់ខ្លួន ចំណែកឯដៃគូរបស់ខ្លួនក៏នឹងប្តេជ្ញា

ចំពោះតម្លៃពិតនៃរបស់នោះដែរ នៅក្នុងរយៈពេលជាច្រើនខែ និងឆ្នាំខាងមុខៗ

ក្នុងនាមជាមនុស្ស យើងមានកាតព្វកិច្ចចំពោះមនុស្សជាតិទាំងអស់ៗ យើងមានកាតព្វកិច្ចមិនត្រឹមតែធានាចំពោះសុខមាលភាពផ្លូវកាយ និងសុវត្ថិភាពតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាដល់សន្តិសុខសង្គមរបស់មនុស្សជាតិថែមទៀតផង ពីព្រោះថាមនុស្សគ្រប់រូបទាមទារឲ្យមានការបញ្ជាក់ថា ខ្លួនមិនមែននៅតែម្នាក់ឯងនោះទេៗ មនុស្សនៅគ្រប់ស្រទាប់សង្គម គួរយកឱកាសនេះស្វែងរកវិធីសាស្ត្រ ដើម្បីបង្ហាញពីការប្តេជ្ញារបស់ខ្លួន ចំពោះគោលការណ៍ប្រសើរជាងមុននៃតួនាទីរបស់ប្រជាជន ការពិត និងការសណ្តោសប្រណីចំពោះមនុស្សជាតិទាំងមូលៗ

នៅក្នុងប្រវត្តិសាស្ត្រ កាតព្វកិច្ចសីលធម៌ និងច្បាប់របស់យើងចំពោះមនុស្សជាតិ ពឹងផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងនយោបាយៗ ការណ៍នេះមិនអាចទទួលយកបានឡើយ ប្រសិនបើយើងពិតជាចង់ពណ៌នាស្ថានភាពសេដ្ឋកិច្ច និងនយោបាយថាគឺជា «កាតព្វកិច្ចនៃមនុស្សជាតិ»ៗ

ការតស៊ូប្រយុទ្ធប្រឆាំងទៅនឹងជំងឺកូវីដនានាពេលបច្ចុប្បន្នបានធ្វើឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើនរំឭកឡើងវិញ នូវការចងចាំដ៏គួរឲ្យភ័យរន្ធត់របស់ខ្លួនៗ ការចងចាំនេះ បានផ្តល់ឲ្យយើងនូវកម្លាំងចិត្តផង និងការឈឺចាប់ផងៗ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទទួលបានកម្លាំងចិត្តពីការចងចាំនេះ ដោយមនុស្សជំនាន់ក្រោយជាច្រើនអាចយល់បានត្រឹមផ្នែកខ្លះតែប៉ុណ្ណោះៗ ក្រៅពីភាពភ័យខ្លាច សោកនាដកម្ម និងការបាត់បង់ជីវិត អ្នករស់រានមានជីវិតទាំងឡាយនៅពេលនេះ នឹងទទួលបាននូវភាពមិនងាយទ្រុឌទ្រោមក្នុងកម្រិតមួយ ដែលមនុស្សជំនាន់ក្រោយៗទៀត មិនអាចយល់បានឡើយៗ

ក្រៅពីភាពមិនងាយទ្រុឌទ្រោមនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទទួលបាននូវការយល់ដឹងមួយៗ ដោយសារតែមានការចងចាំដ៏គួរឲ្យរន្ធត់ និងប្រកបដោយសោកនាដកម្មនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ប្រាកដជាមានការយល់ដឹងធំធេងជាង ទាក់ទងនឹងបញ្ហារបស់មនុស្សជាតិទាំងឡាយ និងថាតើជីវិតមនុស្សមានភាពផុយស្រួយយ៉ាងដូចម្តេចខ្លះៗ ការយល់ដឹងអំពីជីវិតមនុស្ស គឺជាមូលដ្ឋានគ្រឹះនៃសេចក្តីគោរព ដែលការគោរពនេះអាចជាវត្ថុដ៏វិសេសវិសាលនៃគុណធម៌ និងសីលធម៌របស់មនុស្សជាតិៗ

នៅក្នុងអំឡុងពេលនៃជំងឺរាតត្បាតនេះ ប្រទេសកម្ពុជាត្រូវតែប្រើប្រាស់បទពិសោធន៍នៃអតីតកាលដ៏រន្ធត់របស់ខ្លួន ដើម្បីគូសបញ្ជាក់ពីភាពមិនងាយទ្រុឌទ្រោម និងអំពើមនុស្សធម៌ នាពេលសព្វថ្ងៃៗ ខ្ញុំបានស្តាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបង្ហាញអំពីភាពមិនងាយទ្រុឌទ្រោម ហើយរឿងរ៉ាវទាំងអស់នោះ នៅមានឥទ្ធិពល ហើយដក់ជាប់ក្នុងខ្លួនរបស់ខ្ញុំមកដល់សព្វថ្ងៃៗ ខ្ញុំក៏បានស្តាប់រឿងរ៉ាវពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបង្ហាញអំពីទឹកចិត្តជ្រះថ្លានៃអំពើមនុស្សធម៌ ដែលត្រូវបានធ្វើឡើងនៅក្នុងពេលនៃការសម្លាប់រង្គាល ភាពអត់ឃ្លាន និងសេចក្តីស្លាប់ៗ ប្រទេសកម្ពុជា មិនត្រឹមតែជាប្រទេសជាតិមួយ ដែលពោរពេញទៅដោយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតែប៉ុណ្ណោះទេ ប៉ុន្តែប្រទេសកម្ពុជា គឺជាប្រទេសជាតិមួយដែលពោរពេញទៅដោយភាពមិនងាយទ្រុឌទ្រោម និងសេចក្តីសង្ឃឹមៗ យើងត្រូវប្រើប្រាស់ភាពមិនងាយទ្រុឌទ្រោមនិងសេចក្តីសង្ឃឹមនេះ ដើម្បីប្រយុទ្ធប្រឆាំងនឹងវីរុសកូវីដ និងមិនត្រូវទុកឲ្យជំងឺរាតត្បាតនេះបង្វែរយើងចេញពីកាតព្វកិច្ចសីលធម៌របស់យើងឡើយៗ

# សឹង គ្លើល ហៅ នីន ជនជាតិទំពួន

## ប្រធានយានដ្ឋានជួសជុលឡាន យ-១ ក្រសួងឧស្សាហកម្ម

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ D0២០៤២

*អ៊ុន សុជាទី*



រោងចក្រផលិតជ័រកៅស៊ូ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សឹង គ្លើល ហៅ នីន ភេទប្រុស អាយុ ២៦ ឆ្នាំ គិតត្រឹមឆ្នាំ១៩៧៨។ ខ្ញុំ គឺជាជនជាតិទំពួន។ ខ្ញុំមានស្រុកកំណើតនៅភូមិសាម៉ុត ឃុំជីព ស្រុកលំផាត់ ខេត្តរតនគិរី។ ឪពុកម្តាយរបស់ខ្ញុំ បានឈឺស្លាប់ចោលខ្ញុំតាំងពីខ្ញុំនៅតូចៗ បន្ទាប់មក ខ្ញុំបានទៅរស់នៅជាមួយម្តាយមីងវិញ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៩។

រស់នៅជាមួយម្តាយមីងរហូតដល់ឆ្នាំ១៩៧៦ ខ្ញុំបានប្រកបមុខរបរជីកត្បូងនៅបប៉ៃលិន ខេត្តបាត់ដំបង (សព្វថ្ងៃស្ថិតក្នុងខេត្តប៉ៃលិន)។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៧០ ខ្ញុំបានសម្រេចចិត្តចូលព្រៃធ្វើបដិវត្តន៍ជាមួយយោធាភូមិភាគពាយព្យចំនួន ២នាក់ គឺបង សាន និង បង សាយ។ ខ្ញុំក៏បានជាប់ខ្សែរយៈសេអ៊ីអាជាមួយគាត់ចាប់តាំងពីពេលនោះមក។ រហូតដល់ឆ្នាំ១៩៧២ បងសាន និងបងសាយ បានទទួលការចាត់តាំងពី អ៊ុំញឹម ខាងភូមិភាគ ហើយ បងសាន បានឲ្យខ្ញុំនិងគ្នីគ្នាចំនួន៤នាក់ផ្សេងទៀតមកបន្តប់ខ្លួនជាមួយ បងវ៉ន នៅភូមិភាគពិសេស។ បង

សាន និងបងសាយ បានណែនាំខ្ញុំជាច្រើនអំពីការបង្កប់ខ្លួន និងការធ្វើសកម្មភាព។ គាត់ឲ្យខ្ញុំមកធ្វើជានីរសារ ដើម្បីទាក់ទងពីភូមិភាគពិសេសទៅភូមិភាគពាយព្យវិញ។ ខ្ញុំ និងគ្នីគ្នាចំនួន ៤នាក់ បានមកស្នាក់នៅមន្ទីរ ៣០៤ ឃុំពាម ជាមួយបងវន ហើយបន្ទាប់មក គ្នីគ្នារបស់ខ្ញុំចំនួន ២នាក់ទៀតត្រឡប់ទៅវិញអស់ គឺនៅតែខ្ញុំនិងមិត្តសាញ់តែប៉ុណ្ណោះ។ ក្រោយមកខ្ញុំបានភ្ជាប់ខ្សែរយៈជាមួយឈ្មោះ ហុង វឹន សន មុត ហ៊ិន និងបងអន។ រហូតដល់ឆ្នាំ ១៩៧៤ បងវន ដឹងថាខ្ញុំក្បត់ គាត់ក៏យកខ្ញុំធ្វើជានីរសារ និងជូនដំណើរគាត់រហូតដល់ឆ្នាំ១៩៧៥។

នៅពេលដែលខ្មែរក្រហមបានឡើងកាន់កាប់អំណាចទាំងស្រុង នៅក្នុងឆ្នាំ១៩៧៥ បងវនបានឲ្យខ្ញុំមកធ្វើការនៅក្នុងរោងចក្រជួសជុល ឡាន ជាអនុប្រធានរហូតដល់ខែមេសា ឆ្នាំ១៩៧៦ ទើបធ្វើជាប្រធាននៅយានដ្ឋានយ-១ ជួសជុល ឡានដដែល។ ចំពោះខ្សែ សេ.អ៊ុ.អា ដែលខ្ញុំធ្លាប់ទំនាក់ទំនងមានច្រើនទាំងក្នុង និងខាងក្រៅក្រសួង។ នៅក្នុងក្រសួងឧស្សាហកម្ម ប្រធានរោងចក្រភាគច្រើន និងប្រជាជនមួយចំនួនទៀតសុទ្ធសឹងជាខ្សែរយៈរបស់យើង។ នៅខែកក្កដា ឆ្នាំ១៩៧៨ បងអន ប្រធានក្រសួងឧស្សាហកម្ម បានហៅគ្រប់រោងចក្រមកប្រជុំ។ នៅមន្ទីរឧស្សាហកម្ម ដោយមាន បងអន និង បងរ៉ុម ដឹកនាំប្រជុំរហូតដល់ម៉ោង១០ព្រឹក។ បងអនបានប្រកាសបើកអង្គប្រជុំអំពីផែនការក្បត់អង្គការដោយលើកឡើងថា «ថ្ងៃនេះយើងប្រជុំដើម្បីរៀបចំផែនការអប់រំបំផុសមហាជន កម្មករ ឲ្យបំផ្លាញសម្ភារសំខាន់ៗនៅក្នុងរោងចក្រឲ្យខូចរាល់ថ្ងៃ មិនថា រោងចក្រតូចក្តី ឬធំក្តី ហើយគ្រប់រោងចក្រយើងត្រូវបំផុសខាងផ្នែកនយោបាយឲ្យច្របូកច្របល់លើនយោបាយរបស់បក្ស ព្រោះបញ្ហាទាំងអស់នេះ វាសំខាន់ណាស់សម្រាប់ការរារាំងដល់បដិវត្តន៍»។ បងអន បានណែនាំឲ្យបំផ្លាញកីតម្បាញ សម្ភារជួសជុលម៉ាស៊ីន បំផ្លាញសម្ភារតូចតាចដែលប្រើប្រចាំថ្ងៃនៅក្នុងរោងចក្រ។ ចំណែកផ្នែក ឡានវិញ គឺត្រូវបើក ឡានឲ្យបុកភ្លៀវ ឬបើកឲ្យក្រឡាប់ ដើម្បីឲ្យខូចនយោបាយបក្ស ថែមទាំងធ្វើឲ្យ ឡានខូចច្រើន ដើម្បីរាំងស្ទះដល់ការដឹកជញ្ជូន។ ក្រៅពីនោះ ត្រូវលួចដាក់ថ្នាំពុលខ្លះៗនៅក្នុងទឹកក្រូច ទឹកដោះគោ និងទឹកស៊ីអ៊ីវ ដើម្បីឲ្យខូចនយោបាយបរទេស។ មុនពេលបែកគ្នា បងអនបានផ្តាំថា «យើងទាំងអស់គ្នាត្រូវតែយកចិត្តទុកដាក់លើភារកិច្ចទាំងអស់នេះ ដោយសំខាន់អប់រំមហាជនឲ្យធ្វើសកម្មភាពបំផ្លាញឲ្យខ្លាំង»។ ខ្ញុំបានយកយោបល់របស់ បងអន មកណែនាំបំផុសក្នុងអង្គភាពរបស់ខ្ញុំឲ្យស្អប់ និងស្អុគស្អាញប្រឆាំងបដិវត្តន៍ ដើម្បីវាយបក្សកុម្មុយនីស្ត ថែមទាំងណែនាំឲ្យបំផ្លាញ ឡាន ដោយប្រើប្រាស់មិនប្រុងប្រយ័ត្ន។ ចាប់តាំងពីខ្ញុំចូលមកធ្វើការនៅក្នុងយានដ្ឋាននេះ ខ្ញុំមានខ្សែរយៈក្បត់ មានឈ្មោះ ម៉ន អនុប្រធានខ្ញុំ ម៉េង សមាជិក មឿន ប្រធានក្រុម ប៉ក់ប្រធានក្រុម តាទី ប្រធានក្រុម គា ប្រធានក្រុម ស្រេង ប្រធានក្រុម ឡាយ អនុប្រធានក្រុម ហ៊ាង អនុប្រធានក្រុម ឆែ អនុប្រធានក្រុម អ៊ី អនុប្រធានក្រុម និងណាក់ អនុប្រធានក្រុម។

នៅក្នុងខែកក្កដាឆ្នាំ១៩៧៨ នេះដដែល បងអន បានហៅខ្ញុំ និងសន ប្រធានរោងចក្រដ៧ ទៅជួបនិងទទួលការចាត់តាំងពីគាត់ថា ឲ្យខ្ញុំទៅកន្លែង មិត្តជន និង មិត្តម៉ែន ជាជំនួយការនៅក្រសួងសាធារណការ ដើម្បីប្រាប់ដំណឹងថាយើងត្រូវរៀបចំផែនការជាថ្មី ដើម្បីវាយរំលំបក្សកុម្មុយនីស្ត និងបំផុសចលនាត្រៀមវាយបក្សកម្ពុជាកុម្មុយនីស្ត ដើម្បីកសាងសង្គមថ្មីឡើងវិញ។ បងជនបានឆ្លើយតបបន្ទាប់ពីទទួលបានដំណឹងពីខ្ញុំថា «ខ្ញុំបាននិយាយរឿងទាំងអស់នេះជាមួយបងអនរួច ហើយពីថ្ងៃមុន ខ្ញុំយល់អស់ហើយពីបញ្ហានេះ ហើយខ្ញុំបានចាប់ផ្តើមដំណើរការជាបណ្តើរៗដែរ»។ បន្ទាប់មក ខ្ញុំក៏បានចាប់ដៃ បងជន លាត្រឡប់មកក្រសួងឧស្សាហកម្មវិញ ដើម្បីប្រាប់ដំណឹងនេះដល់ បងអន។ មិនយូរប៉ុន្មាន ខ្ញុំនិងបងសន ក៏បានទៅទាក់ទងខាងក្រសួងសាធារណការ ដើម្បីប្រាប់ពីផែនការបន្ថែមទៀត ព្រោះនៅទីនោះ មាន បងហេង និងបងម៉ែន ដែលខ្ញុំធ្លាប់រស់នៅជាមួយតាំងពីឆ្នាំ១៩៧៤មកម្ល៉េះ។ ក្រោយៗមកទៀត ខ្ញុំបានទំនាក់ទំនងជាញឹកញាប់ជាមួយ



*រោងចក្រតម្បាញ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



*រោងចក្រកែវ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ក្រសួងសាធារណការនៅកន្លែងអគ្គិសនី ថែមទាំងធ្វើសកម្មភាពផ្សេងៗ ដើម្បីរួមសហការជាមួយក្រសួងផ្សេងៗនៅក្នុងក្រុងភ្នំពេញដែរ។

នៅខែសីហា ឆ្នាំ១៩៧៨ បងអន បានហៅប្រធានរោងចក្រមួយចំនួនមកប្រជុំម្តងទៀត ដើម្បីរំពុកពីសភាពការណ៍មួយចំនួន និងពង្រឹងសកម្មភាពឲ្យខ្លាំងក្លា ដោយពង្រីកខ្សែបណ្តាញឲ្យបានកាន់តែច្រើនថែមទៀត។ បន្ទាប់ពីទទួលបានការណែនាំរួច ខ្ញុំបានទៅអប់រំកម្មករក្នុងរោងចក្ររបស់ខ្ញុំតាមបណ្តាំរបស់ បងអន ថា «ឲ្យមើលឃើញពីសង្គមចាស់ ដូចជា រឿងចាយលុយ មានប្រាក់ខែ មានផ្សារលក់ដូរ ឲ្យស្អប់បដិវត្តន៍ ឲ្យស្មុគស្មាញពីសង្គមបដិវត្តន៍ ប្រឆាំងនឹងបដិវត្តន៍ តាមរយៈការបំផ្លិចបំផ្លាញសម្ភារផ្សេងៗ»។ ក្រៅពីនេះ ខ្ញុំក៏បានធ្វើសកម្មភាពជាបន្តបន្ទាប់តាមការចាត់តាំងរបស់ បងអន។ ចំពោះសកម្មភាពទំនាក់ទំនងខាងក្រៅ មិត្តរ៉ុន មិត្តណយ និងខ្ញុំបានទទួលការចាត់តាំងពីបងអនឲ្យទៅជួប បងប្រាង និងបងសាំង នៅក្រសួងរទេះភ្លើងអំពីផែនការថ្មីៗ ជំនួសគាត់ព្រោះ បងអន ខ្លាចគេចាប់អារម្មណ៍មកលើគាត់។ បងអន បានផ្តាំផ្ញើពាក្យសំដីថា «ខ្ញុំសុំរំពុកអំពីផែនការរបស់យើង និងស្នើរៀបចំឲ្យបានស្រួល និងត្រូវប្រុងប្រយ័ត្នឲ្យបានមែនទែន។ មិនតែប៉ុណ្ណោះ ត្រូវខំយកចិត្តទុកដាក់បំផុសសកម្មភាព ដើម្បីឲ្យទទួលបានការឯកភាពពីក្រសួងមួយទៅក្រសួងផ្សេងទៀត»។ ខ្ញុំក៏ត្រឡប់មកវិញរាយ-ការណ៍ជូនបងអនវិញ និងសុំទាក់ទងផ្ទាល់ទៅ មិត្តចាន់ មិត្តដា និងមិត្តសឿន នៅក្រសួងរទេះភ្លើង ដែលខ្ញុំធ្លាប់ស្គាល់ជាយូរមកហើយបន្ថែមទៀត។ បងអន ក៏អនុញ្ញាតព្រោះគាត់មិនសូវស្គាល់នរណាច្រើននោះទេ។ យើងទាំងបីនាក់បានត្រឡប់ទៅទីនោះម្តងទៀត ដើម្បីទាក់ទងមិត្តចាន់មិត្តដា និងមិត្តសឿន។ នៅពេលទៅដល់ ខ្ញុំមិនទាន់និយាយរឿងបំផុសចលនានោះទេ គឺខ្ញុំបានសួរនាំជុំវិញបញ្ហាធ្វើស្រែ ដំណើរការនៅក្នុងរោងចក្រ និងរឿងដោះស្រាយជីវភាពកម្មករនៅក្នុងរោងចក្រ ហើយជាចុង



រោងចក្រផលិតចាន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយ ពេលដែលខ្ញុំគ្នាប់សភាពការណ៍បាន ខ្ញុំក៏និយាយចូលដល់សភាពការណ៍បដិវត្តន៍តែម្តងៗ ក្រោយពីខ្ញុំដាក់ផែនការរួច មិត្តទាំងបីនាក់បានឯកភាពទទួលយកផែនការនេះ។ បន្ទាប់មកទៀត ខ្ញុំ និង បងភិន ត្រូវបងអនចាត់តាំងម្តងទៀតឲ្យទៅទាក់ទង មិត្តសាវ៉ាត និងមិត្តជឿននៅក្រសួងកសិកម្មវិញម្តងៗ បន្ទាប់ពីទាក់ទងរួច បងសាវ៉ាត និងបងជឿន ឲ្យខ្ញុំជម្រាបទៅបងអនវិញថា «នៅក្នុងក្រសួងរបស់ខ្ញុំកំពុងតែចាប់ផ្តើមដំណើរការជាបណ្តើរៗ តាមការពិភាក្សាពីមុន ដោយខ្ញុំបានព្យាយាមអប់រំកម្មករ និងកម្មាភិបាលទាំងអស់ដើម្បីបម្រើដល់ផែនការនិងសកម្មភាពរបស់យើងខាងមុខនេះ»។

រហូតមកដល់ខែតុលា ឆ្នាំ១៩៧៨ បងអន បានកោះហៅប្រធានរោងចក្រទាំងអស់ឲ្យមកប្រជុំជាលើកចុងក្រោយនៅមន្ទីរឧស្សាហកម្ម។ បងអន និយាយថា «ថ្ងៃនេះ គឺជាថ្ងៃដែលយើងប្រជុំចុងក្រោយ ដើម្បីឲ្យមិត្តគ្នាប់បាននូវផែនការល្អិតរបស់យើងនៅចុងក្រោយនេះ ព្រោះពេលនេះជិតដល់ពេលកំណត់ដែលយើងត្រូវវាយក្នុងខែកុម្ភៈ ឆ្នាំ១៩៧៩ ខាងមុខនេះ»។ បងអន សុំឲ្យមានការចាត់តាំងផែនការទៅតាមរោងចក្រនីមួយៗដូចជា៖

១) ត្រូវបំផុសនយោបាយសតិអារម្មណ៍ដោយចាត់តាំងឲ្យកម្មករនៅក្នុងរោងចក្រវាយបក្សកុម្មុយនីសកម្ពុជារួមគ្នាជាមួយវៀតណាម។

២) អប់រំកម្មករឲ្យបំផ្លិចបំផ្លាញសម្ភារនៅក្នុងរោងចក្រឲ្យកាន់តែខ្លាំង

៣) ដាក់ថ្នាំបំពុលនៅក្នុងរោងចក្រទឹកដោះគោ ទឹកក្រូច ទឹកស៊ីអ៊ីវ ទឹកត្រី ដើម្បីឲ្យបែកបាក់នយោបាយនៅបរទេស។

៤) នៅមន្ទីរពេទ្យ ត្រូវចាក់ថ្នាំសម្លាប់អ្នកជំងឺ និងព្យាយាមកម្ទេចមន្ទីរពេទ្យឲ្យបានច្រើនជាងគេ។

៥) រៀបចំដករបបកម្មករសម្រាប់ទុកត្រៀមពេលកំពុងវាយ ដើម្បីជួយវៀតណាមឲ្យចូលមកវាយដល់ក្នុងទីក្រុង និងញុះញង់ដល់កម្មករពីបញ្ហាដករបបនេះដោយយកហេតុផលថា មកពីអង្គការខ្វះខាតច្រើន ហើយអង្គការឲ្យដកយកវិញ។

នៅពេលប្រជុំនេះ បងអនបានប្រាប់អំពីផែនការវាយចូលទីក្រុង និងការរៀបចំទិសដៅ និងមុខសញ្ញានីមួយៗដើម្បីវាយចូលនៅក្នុងទីក្រុងភ្នំពេញរួចជាស្រេចៗ

ក្រោយពីទទួលបានការណែនាំ និងការចាត់តាំងរួចហើយ ខ្ញុំយកបញ្ហាទាំងអស់នេះមករៀបចំត្រៀមដើម្បីសហការជាមួយរោងចក្រគេធំៗ ឲ្យត្រៀមកម្លាំងដែលមានក្នុងរោងចក្ររបស់ខ្លួន ដើម្បីធ្វើសកម្មភាពថ្ងៃខាងមុខនេះ។ ខ្ញុំបានធ្វើសកម្មភាពតាមការចាត់តាំងពីបងអនដែលបានណែនាំជាបន្តបន្ទាប់រហូតដល់ខែវិច្ឆិកាឆ្នាំ១៩៧៨។

ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ខ្ញុំត្រូវបានអង្គការចាប់ខ្លួន និងយកមកឃុំឃាំងក្នុងគុកទួលស្លែងដោយមានឈ្មោះ រស់ ទិត គឺជាអ្នកសួរចម្លើយខ្ញុំ។

កំណត់ចំណាំ ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ សឹង គ្លើល ហៅ នីន ពិតប្រាកដយ៉ាងណានោះទេ។

# ខ្ញុំក្លាយជាជនបដិវត្តន៍តាមឪពុកខ្ញុំ

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ D២៤០២១

**ដារ៉ារដ្ឋ មេត្តា**



ជនរងគ្រោះដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ឬ គុកទួលស្លែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស៊ុនផុន ផៃ ហៅ អន គឺជាជនជាតិ និង មានអាយុ ៣៥ឆ្នាំ នៅក្នុងឆ្នាំ ១៩៧៨។ ខ្ញុំនៅភូមិហាត់ប៉ក់ ឃុំហាត់ប៉ក់ ស្រុកវ៉ឺនសៃ ខេត្តរតនគិរី។ ឪពុកម្តាយរបស់ខ្ញុំបានប្រកបរបរធ្វើស្រែចម្ការ។ បន្ទាប់មកគាត់បានចូលខ្មែរឥស្សរៈ ហើយត្រូវបានខ្មាំងចាប់ដាក់គុកអស់រយៈពេល ៦ឆ្នាំ គឺជាប់ឃុំនៅស្ទឹងត្រែង ២ឆ្នាំ និងនៅភ្នំពេញ៤ឆ្នាំ។ នៅឆ្នាំ១៩៦៥ គាត់ត្រូវបានដោះលែង។ ពីរឆ្នាំក្រោយមក ឪពុកខ្ញុំបាននាំខ្ញុំ និងម្តាយខ្ញុំរត់ចូលក្នុងព្រៃភូមិចាន់ ស្ថិតនៅក្នុងស្រុកបរកែវខាងជើង តំបន់រតនគិរី។

នៅខែមិថុនា ក្នុងឆ្នាំ១៩៦៥ ខ្ញុំទទួលបានការអប់រំពីឪពុករបស់ខ្ញុំឲ្យចូលក្នុងបក្សពលករវៀតណាម ដើម្បីក្លាយជាសហព័ន្ធឥណ្ឌូចិន។ ក្រោយមក ខ្ញុំក៏បានរៀនអំពីនយោបាយរបស់បក្សពលករវៀតណាម នៅមន្ទីរក្នុងព្រៃភូមិចាន់ ដោយមានអ្នកខទ្ទេសនាមឯកសារឈ្មោះ ថងស៊ី (ពីឆ្នាំ១៩៧២ ដល់ ឆ្នាំ១៩៧៧ គឺលេខាស្រុក ២៣)។ អ្នករៀននយោបាយមានឈ្មោះ កាវិន (លេខាស្រុកសៀមប៉ាង), កាលាច (ប្រធានចម្ការកប្បាស បានលុង), កងដែង (លេខាតំបន់១០២), ស៊ីម ហៅ ម៉ាន និង ជឺន (ប្រធានចម្ការដំណាំរបស់ភូមិភាគឦសាន), ស៊ូផុន (ឪពុករបស់ខ្ញុំ កាលនោះ គឺជាប្រធានសេដ្ឋកិច្ចស្រុកវ៉ឺនសៃខាងជើង), ខ្ញុំ (កងការពារមន្ទីររបស់ ថងស៊ី) និង វណ្ណា (ពេទ្យស្រុកវ៉ឺនសៃខាងជើង)។ ពេលរៀនសូត្រ ថងស៊ី បានលើកឡើងពីបញ្ហាមួយចំនួន ធ្វើឲ្យជឿជាក់លើបក្សពលករវៀតណាម ដែលដឹកនាំធ្វើការតស៊ូដណ្តើមជ័យជម្នះលើបារាំង ហើយបក្សពលករវៀតណាម ចង់រួបរួមប្រទេស ឡាវ, ខ្មែរ និងវៀតណាម ឲ្យជាសហភាពឥណ្ឌូចិនតែមួយ។ ចំណែកខ្លឹមសារត្រូវគោរពតាមផែនការអប់រំសហព័ន្ធឥណ្ឌូចិន។ ក្រោយមក បានរយៈពេលប្រហែលជា១ខែ ឈ្មោះ ថងស៊ី បានឲ្យខ្ញុំរៀនបច្ចេកទេសយោធាយួន ដែលកាលនោះអ្នកចូលរៀនមានខ្ញុំ, ចំប៉ាំ (កងការពារភូមិចាន់) និង ក្តី (កងការពារភូមិចាន់)។ គ្រូបង្រៀនឈ្មោះ

លឿ (ជនជាតិចារ៉ាយ) ទើបតែមកពីឃុំនខាងជើង និងឈ្មោះ គាន់។ ក្រោយពីរៀនសូត្រចប់ ឪពុករបស់ខ្ញុំបានប្រាប់ខ្ញុំថា មនុស្សទាំងអស់ដែលកូនបានរៀនជាមួយ សុទ្ធតែជាអ្នកតស៊ូដ៏យជម្នះក្នុងការរួបរួមប្រទេសឲ្យក្លាយជាឥណ្ឌូចិន។ នៅក្នុងឆ្នាំ១៩៦៦ ខ្ញុំបានទាក់ទងជាមួយឈ្មោះខាងលើធ្វើសកម្មភាព ឃោសនាប្រជាជនឲ្យមានជំនឿលើបក្សពលករវៀតណាម។ នៅក្នុងឆ្នាំ១៩៦៧ ថងស៊ី បានចាត់តាំងខ្ញុំ និងឪពុករបស់ខ្ញុំឲ្យធ្វើសកម្មភាពនៅក្នុងព្រៃភូមិកុកឡាស់ ស្រុកវ៉ឺនសៃ។ ឪពុករបស់ខ្ញុំបានទៅទាក់ទងជាមួយឈ្មោះ ស៊ុម។ ក្រោយមក ឪពុករបស់ខ្ញុំបាននាំខ្ញុំទៅទាក់ទងជាមួយខ្សែរយៈបក្សពលករវៀតណាមមួយចំនួននៅក្នុងភូមិកុកឡាក់, ភូមិតាក និងភូមិខាំពីវ ក្នុងស្រុកវ៉ឺនសៃខាងជើង រួមមានឈ្មោះ ធួម (កម្មាភិបាលចលនាប្រជាជនភូមិកុកឡាក់), ភួន (ប្រជាជននៅក្នុងសហករណ៍កុកឡាក់), សាវ៉ាង (ប្រធានសហករណ៍ណាង៉ាម), ប៊ុនសុំ (សមាជិកស្រុកកុកឡាក់), សួល (ប្រជាជនសហករណ៍ភូមិខាំពីវ), សា (កម្មាភិបាលចលនាប្រជាជន), តង(ប្រធានសហករណ៍ភូមិកាឡាក់), តឿន (ប្រជាជននៅសហករណ៍កងណក), ខាំ បន (អនុប្រធានសហករណ៍ភូមិទាម)។ ខ្ញុំ និងឪពុកខ្ញុំ រួមទាំងបក្ខពួក កសាងកម្លាំងបានឈ្មោះ ប៊ុនមាំ (ប្រធានរោងបាយសហករណ៍ ភូមិកុកឡាក់), បៀ (ប្រជាជននៅសហករណ៍កុកឡាក់)។ នៅក្នុងសកម្មភាពនោះខ្ញុំបានចូលរួមបន្តិចបន្តួចប៉ុណ្ណោះ ឪពុកខ្ញុំ គឺជាអ្នកលើកឡើងឲ្យធ្វើបដិវត្តន៍ជាមួយយួន។

នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦៧ ឈ្មោះ ស៊ុម បានទៅជួបឪពុកខ្ញុំ ហើយបានរៀបចំបញ្ចូលខ្ញុំ និងប៊ុនមាំ ក្នុងបក្សពលករវៀតណាម ដោយមានឪពុករបស់ខ្ញុំជាអ្នកឧទ្ទេសនាម និងឈ្មោះ ស៊ុម ជាអ្នកទទួលស្គាល់។ នៅក្នុងពិធីនោះ ខ្ញុំ និងប៊ុនមាំ គោរពទង់ដែលមានរូបកណ្តៀវ



មន្ទីរសន្តិសុខស-២១ ឬ គុក ទួលស្លែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ខ្នោះ និងច្រវាក់សម្រាប់ដាក់អ្នកទោស នៅមន្ទីរសន្តិសុខស-២១ ឬ គុកទួលស្លែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ញញួរនៅខាងលើ និងមានរូបផ្កាយ៣នៅខាងក្រោម ព្រមទាំងគោរពរូបហូជីមិញ នៅខាងក្រោមរូបផង។ នៅឆ្នាំ១៩៦៧ សំបុត្រមួយច្បាប់ពីឈ្មោះ កាវិន បាន ផ្ញើមកឲ្យឪពុកខ្ញុំ ដោយអង្គការរកមនុស្សធ្វើនីរសារ ហើយ នៅក្នុងសំបុត្របញ្ជាក់ថា ខ្ញុំត្រូវតែធ្វើជានីរសារ។ មុនពេល ឪពុកខ្ញុំឲ្យខ្ញុំទៅធ្វើនីរសារអង្គការ គាត់បានណែនាំខ្ញុំថា កូនទៅនេះ គឺរក្សាគោលជំហរពលករវៀតណាមឲ្យរឹងមាំ ហើយមិនត្រូវអួតអាង ថាខ្លួនបានចូលបក្សពលករទេ ព្រោះបក្សនេះមិនឯកភាពជាមួយអង្គការខ្មែរក្រហមទេ។ នៅដើមខែមិថុនា ឆ្នាំ១៩៦៧ ខ្ញុំបានចាកចេញពីឪពុកទៅ ធ្វើជានីរសារអង្គការនៅមន្ទីរ១០០ ក្នុងភូមិកាឡែង ស្រុក បរកែវខាងជើង តំបន់រតនគិរី។ ពេលទៅដល់កន្លែងអង្គការ មានឈ្មោះវិនដែលជាប្រធានមន្ទីរ បានចាត់តាំងខ្ញុំជា ប្រធានក្តាប់រួម និងនីរសាររបស់អង្គការ។ ខ្ញុំធ្វើនៅមន្ទីរ នីរសារនៅអូរកប ជិតកន្លែងអង្គការ។ ក្រោយមក កាវិន បានហៅខ្ញុំ និងនីរសារអង្គការ៣នាក់ទៀត មានឈ្មោះ ដួន (ប្រជាជននៅសហករណ៍ភូមិល្អក ស្រុកបរកែវខាងជើង, សេង (ប្រធានចម្ការបន្លែ និងគោក្របី នៅម្តុំភូមិស្រែគោ ស្រុកស៊ើងត្រែង តំបន់១០៤) និងឈ្មោះ បាន់ (យុទ្ធជន កម្មករ នៅរោងជាងធំ)។ កាវិន បានហៅយើងទៅអប់រំ ដើម្បីប្រឆាំងបដិវត្តន៍។ ក្រោយអប់រំរួច កាវិន មិនបាន ណែនាំឲ្យធ្វើសកម្មភាពអ្វីទេ ថាបើធ្វើខ្មាចបែកការណ៍ គឺធ្វើតាមអង្គការសិនទៅ។ ខ្ញុំបានរាយការណ៍ពីការណែនាំ របស់កាវិនទៅប្រាប់ ស៊ុម ដែលមានមន្ទីរនៅភូមិតាឡែង។

នៅក្នុងឆ្នាំ១៩៧០ បងស៊ុម បែកពីខ្ញុំ ហើយខ្ញុំក៏មិន បានទទួលការណែនាំអ្វីពីគាត់ទៀតដែរ។ អង្គការបាន ផ្លាស់មកមន្ទីរនៅភូមិចាន់ ស្រុកបរកែវខាងជើង។ ក្រោយ មកមានកម្មាភិបាលម្នាក់ ឈ្មោះ យ៉ា មកធ្វើគណៈភូមិ

ភាគត្បូងសាន។ ខែកញ្ញា ឆ្នាំ១៩៧០ ខ្ញុំហៅមិត្តនីរសារ នៅមន្ទីរក១១ រៀនឯកសាររបស់អង្គការ។ យ៉ា បាន ទៅដេកសម្រាកនៅទីនោះមួយយប់ ហើយបានហៅខ្ញុំ, សន, ថត ហៅ ប៉ុង និងនីរសារម្នាក់ទៀត ឈ្មោះ សៀន មកអប់រំឲ្យប្រឆាំងបដិវត្តន៍។ យ៉ា បាននិយាយថាមិត្ត ទាំងអស់គ្នាឃើញទេកម្លាំងបដិវត្តន៍ ដែលអង្គការដឹក នាំមានកម្មាភិបាលជើងចាស់តិចណាស់ ឯកម្លាំង បដិវត្តន៍មួយទៀតបានរួបរួមជាមួយវៀតណាម ហើយ កម្លាំងកម្មាភិបាលដែលរួមជាមួយវៀតណាមមានកម្លាំង ច្រើន ជាកម្មាភិបាលដែលមានជំនាញបច្ចេកទេស, ពេទ្យ, យោធា និងបច្ចេកទេសផ្សេងៗទៀត។ តើមិត្តគិតថាខាង ណាជាអ្នកឈ្នះ? ខ្ញុំថាមិនដឹងខាងណាឈ្នះចាញ់ទេ។ យ៉ា បានបន្តទៀតថា មិនអាចឈ្នះកម្លាំងបក្សពលករ កម្ពុជាទេ។ ការអប់រំនេះ យើងខ្ញុំបានធ្វើតាម យ៉ា ។

នៅខែឧសភា ឆ្នាំ១៩៧១ អង្គការលេខាភូមិភាគ ត្បូងសានចាស់ បានផ្លាស់ពីមន្ទីរមកនៅភូមិភាគឧត្តរចាស់ ហើយឈ្មោះ យ៉ា បានឡើងកាន់កាប់លេខាភូមិភាគ ត្បូងសាន និងមាន បងវី គឺជាអនុលេខា។ ក្រោយពីអង្គការ ផ្លាស់ប្តូរអ្នកដឹកនាំ បងយ៉ា បានផ្លាស់មកនៅមន្ទីរភូមិ ស្រែគោ ឃុំស្រែគោ ស្រុកស្ទឹងត្រែងតំបន់១០៤។ នៅខែ មិថុនា ឆ្នាំ១៩៧១ បងយ៉ា និងបងវី បានចាត់តាំងខ្ញុំធ្វើ ជាអនុប្រធានកងដឹកជញ្ជូនសេដ្ឋកិច្ច ភូមិភាគត្បូងសាន។ ខ្ញុំ និងបក្ខពួកបានទាក់ទងគ្នាធ្វើសកម្មភាពតាមផែនការ របស់ យ៉ា និង បងវី ជាបន្តបន្ទាប់ ហើយជាលទ្ធផលគឺៈ ផ្នែកសេដ្ឋកិច្ច និងកងដឹកជញ្ជូន កសាងកម្លាំងបាន ៣នាក់ មានឈ្មោះ លីហ៊ាង (បុគ្គលិករោងសិប្បកម្មភូមិភាគ ត្បូងសាន នៅស្ទឹងត្រែង) និង ផ្នែកបុគ្គលិកខាងក្រសួង សំណង់ផ្សេងៗរបស់ភាគត្បូងសាន មានឈ្មោះ វង់។

នៅខែកក្កដា ឆ្នាំ១៩៧៣ បងយ៉ា និង បងវី បានចាត់ តាំងខ្ញុំឲ្យដឹកកាំភ្លើងជាង៣០០ដើម ពីឃ្លាំងជិតមន្ទីរភាគ យកទៅប្រគល់ឲ្យ បងប៊ុត ទុកត្រៀមផែនការប្រឆាំង បដិវត្តន៍។ ខ្ញុំក៏បានដឹកកាំភ្លើងជូន បងប៊ុត នៅក្នុងមន្ទីរ ១០៤។ ក្រោយមក បងប៊ុត បានឲ្យខ្ញុំទាក់ទងជាមួយខ្សែ នៅស្រុកសៀមប៉ាង ដោយមានឈ្មោះ ម៉ុន (លេខាស្រុក សៀមប៉ាង) ដោយយកក្រណាត់១៥០គីទៅឲ្យ ម៉ុន ដើម្បី យកទៅឲ្យប្រជាជនដែលបានរត់ទៅប្រទេសឡាវ ប្រមាណ ជា២០០នាក់។ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៣ បងយ៉ា បាន ហៅបក្ខពួកមួយចំនួនទៅប្រជុំនៅសាលាមន្ទីរស៣ ក្នុង នោះអ្នកចូលរួមមានឈ្មោះ បងយ៉ា, បងវី, បងប៊ុត, ទុំ, អេន, អុន, អំ, សឿន ហៅ ថាវិន, ស៊ូ ឡែន, ស៊ីឡា, កែវ, ខ្មៅ, បៀន, នូ សន, ប៊ូ, ខ្ញុំ, ថងស៊ី, ផែង និងចាន់។ ខ្លឹមសារ នៅក្នុងការប្រជុំចំណុចទី១) បងយ៉ា បានប្រាប់ថា មួយ រយៈនេះគាត់មិនបាននៅជាមួយទេ ព្រោះត្រូវទៅបំពេញ ការងារបដិវត្តន៍ ហើយមានមិត្ត ប៊ុត និងបងវី ជា អ្នកទទួលខុសត្រូវជំនួស។ ទី២) គឺត្រូវអនុវត្តការងារយូរ អង្វែង។ ម្នាក់ៗត្រូវតែម្ចាស់ការលើខ្លួនឯង ដោយធ្វើ សកម្មភាព និងលាក់ការសម្ងាត់ឲ្យបានល្អ ហើយទទួលបាន លទ្ធផល ទើបហៅថាកម្មាភិបាលទទួលខុសត្រូវខ្ពស់។ ក្រោយប្រជុំ បងយ៉ា ត្រូវបានផ្លាស់ប្តូរទៅកន្លែងផ្សេង។

នៅក្នុងខែមីនា ឆ្នាំ១៩៧៥ បងវី និង ប៊ុត បានហៅ បក្ខពួកមួយចំនួនទៅប្រជុំនៅមន្ទីរ ដែលមានគ្នាប្រមាណ ជា១៤នាក់។ ខ្លឹមសារនៃការប្រជុំ គាត់បានណែនាំផែនការ គ្រប់អង្គភាពត្រូវប្រមូលកម្លាំង និងសមាសភាពមិនល្អ ដែលជាវណ្ណៈប្រឆាំងជាមួយបដិវត្តន៍។ ត្រួតពិនិត្យកម្លាំង នេះកុំឲ្យបាត់បង់ទៅខាងបដិវត្តន៍ និងលាក់ការសម្ងាត់ ឲ្យបានល្អ។ នៅខែមិថុនា ឆ្នាំ១៩៧៥ បងវី បានមកដល់ មន្ទីរពាណិជ្ជកម្មភាគនៅភ្នំពេញ។ ក្រោយពីបងវី មក បងប៊ុត បានចាត់តាំងខ្ញុំនិងកម្លាំងមួយចំនួនឲ្យមកដឹក សម្ភារ ពីមន្ទីរពាណិជ្ជកម្មភាគនៅភ្នំពេញ ហើយយក ទៅដាក់នៅមន្ទីរពាណិជ្ជកម្មនៅក្រចេះ ដែលមានឈ្មោះ ទុំ ជាអ្នកនៅប្រចាំការ។ ពេលខ្ញុំមកដល់មន្ទីរពាណិជ្ជកម្ម ភាគ នៅខាងជើងស្ពានជ្រោយចង្វារ បងវី បានប្រជុំជាមួយ ខ្ញុំ, អុន និង ទុំ។ ក្នុងការប្រជុំនេះ បងវី បានលើកផែនការ មួយចំនួន ចំពោះក្រណាត់ និងខោអាវល្អៗ ត្រូវយកទៅ ដាក់នៅមន្ទីរក្រចេះ ទុកប្រឆាំងបដិវត្តន៍ ចំណែកសម្ភារ ណាដែលមិនល្អត្រូវទុកចែកឲ្យប្រជាជន។ ខ្ញុំនិងបក្ខពួក បានដឹកសម្ភារនេះរហូតដល់ចុងឆ្នាំ១៩៧៥។

នៅក្នុងឆ្នាំ១៩៧៦ បងវី និងបងប៊ុត បានហៅបក្ខពួក មួយចំនួនប្រជុំនៅសាលានយោបាយរបស់ភាគនៅខាង កើតវត្តភ្នំស្ទឹងត្រែង មានអ្នកចូលរួម បងវ៉ាន់, បងប៊ុត,

ទុំ, អុំ, អេន, អុន, ប៊ូ, សន, ស៊ូឡែម, សឿត ហៅ ថាវ៉ាន, ស៊ីឡា, កែវ, ខ្មៅ, នូ សន, ទិន, ដែង, ថង ស៊ី,ខាំវៀងៗ ខ្លឹមសារប្រជុំមានត្រួតពិនិត្យកម្លាំងដែលកសាងបាន រួមមាន ភាគ, តំបន់, ស្រុក ហើយឲ្យមានអាវុធគ្រប់ដៃៗ ត្រូវត្រៀមកម្លាំងធ្វើរដ្ឋប្រហារ គឺទិសដៅវាយយក ស្រុកសៀមប៉ាងមុន នៅក្នុងខែមេសា ឆ្នាំ១៩៧៦ ដើម្បីជាមូលដ្ឋានបង្អែកវាយរំដោះយកភាគឦសានឲ្យបាន នៅថ្ងៃអនាគតខាងមុខៗ ចំណែកកម្លាំងខាងក្រៅមាន មិត្តប៊ិត និង មិត្តស៊ីឡា ទាក់ទងបានទាំងទ័ពវៀតណាម និងកងទ័ពដែលបានបាត់ទៅ (មានជនជាតិលាវ និង ជនជាតិទំពួន)ៗ នៅពេលយើងរំដោះកន្លែងណាបានហើយ ត្រូវក្តាប់ប្រជាជន ហើយប្រមូលប្រជាជនឲ្យធ្វើរដ្ឋប្រហារជាមួយយើងៗ នៅក្នុងខែមិនា ឆ្នាំ១៩៧៦ បងយ៉ា បានត្រឡប់ទៅមន្ទីរភាគឦសានវិញ ហើយក៏បានប្រជុំៗ បងយ៉ា បានលើកឡើងចំពោះផែនការនៅខែកុម្ភៈ ឆ្នាំ១៩៧៦ ដែលលើកឡើងពីការធ្វើរដ្ឋប្រហារ ប៉ុន្តែឥឡូវមិនបានធ្វើទេ ដូច្នេះផែនការរបស់យើងត្រូវលើកទៅធ្វើនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៦ វិញៗ

នៅខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំបានទទួលសំបុត្រពី បងវី ហៅខ្ញុំឲ្យទៅទទួលភារកិច្ចថ្មីៗ ពេលខ្ញុំទៅដល់ បងប៊ិត បានហៅខ្ញុំទៅប្រជុំនៅមន្ទីររបស់គាត់ (មន្ទីរ១០៤)ៗ អ្នកចូលរួម មាន បងប៊ិត, អុន, អេន, អន និង សាំងៗ ខ្ញុំត្រូវបានចាត់តាំងជាប្រធានដឹកនាំសម្ភារសេដ្ឋកិច្ចជុំវិញមន្ទីរភាគៗ បងប៊ិត បានឲ្យម៉ូតូខ្ញុំមួយគ្រឿងសម្រាប់ខ្ញុំទៅមកចុះឡើងពិនិត្យសភាពការណ៍ៗ គ្រប់អង្គភាពចម្ការកៅស៊ូបានលុងរបស់ភាគ និងមន្ទីរផ្សេងៗរបស់ភាគ ត្រូវយកអង្ករដែលជារបបប្រចាំថ្ងៃ ទៅលាយគល់ចេក គល់ល្ហុង ត្រកួន ក្តួច មើមប្រង់ ស្លឹកដំឡូងមី ផ្លែល្ហុង ផ្លែល្ពៅ ត្រឡាច ចេក គឺលាយរកគ្រាប់អង្ករស្ទើរតែមិនឃើញៗ របបអាហារពិសេស បងប៊ិត បានឲ្យចែកដំឡូងឈើ និងដំឡូងមីលាយបាយកន្លះខែម្តងៗ ចំណែកការចែកខោអាវគឺចែកតែចំពោះអ្នកណាដែលមានខោអាវរហែកខ្លាំងមែនទែន ឯអ្នកណាដែលរហែកល្មមៗមិនចែកទេក្រោមលេសថាសន្សំសំចៃៗ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ បងវី បានចាត់តាំងខ្ញុំជាអនុប្រធានកសិកម្មភូមិភាគឦសាន ហើយឲ្យទទួលខុសត្រូវខាងចម្ការដំណាំនៅអូរខេ ខាងជើងក្រុងស្ទឹងត្រែងៗ

នៅខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំនិង មិត្តអន ត្រូវបានអង្គការចាប់ដាក់សន្តិសុខភាគឦសាន នៅស្ទឹងត្រែង ព្រែកអូរពងមាន់ ខាងលិចក្រុងស្ទឹងត្រែងៗ ពេលខ្ញុំជាប់ឃុំបាន ២ថ្ងៃ បងប៊ិត បានទៅដោះខ្ញុំចេញ ហើយបាននាំខ្ញុំទៅផ្ទះខ្ទមតូចមួយចម្ងាយប្រមាណជា៥០ម៉ែត្រពីមន្ទីរៗ បងប៊ិត គាត់បានណែនាំខ្ញុំថា ចំពោះមិត្តគ្មានកំហុសអ្វីឲ្យគ្នាយើងចាប់ទេ គឺអង្គការឲ្យចាប់ៗ ដូច្នេះពេលមិត្តចេញពីកន្លែងនេះ ទៅកន្លែងអង្គការ ត្រូវឆ្លើយសារភាពចាប់តាំងពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៨ ហើយការឆ្លើយនេះត្រូវយកបងយ៉ា ធ្វើជាមេបង្អែកៗ ក្រោយមកត្រូវយកបង អុន, មិត្តអេន និងមិត្តទុំ ធ្វើជាមេដឹកនាំក្បត់ៗ ជៀសវាងកុំឆ្លើយដាក់ខ្ញុំ បើមិនដូច្នេះទេ ប្រាកដជាមិនមានអ្នកដឹកនាំទៀតឡើយៗ បន្ទាប់មក បងប៊ិត បានសរសេ ចម្លើយខ្ញុំដោយខ្លួនគាត់ចាប់តាំងពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៨ ខ្លឹមសារដូចការណែនាំរបស់គាត់ៗ ខ្ញុំបានមើលគម្រោងរបស់ បងប៊ិត សរសេររយៈពេលមួយម៉ោង និងទទួលបានការណែនាំពីគាត់បានខ្លះ រួចបងប៊ិត ក៏បាននាំខ្ញុំមកដាក់កន្លែងដើមវិញ ហើយគាត់ក៏លាខ្ញុំទៅៗ ខ្ញុំជាប់ឃុំនៅក្នុងសន្តិសុខភូមិភាគឦសានរហូតដល់ដើមខែសីហា ឆ្នាំ១៩៧៨ ទើបអង្គការបាននាំខ្ញុំយកមកដាក់កន្លែងនេះតែម្តងៗ

កំណត់ចំណាំ ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ ស៊ុនដុន ផៃ ហៅ អន ពិតប៉ុណ្ណាណនោះទេៗ

# វិចិត្រសាលសិល្បៈ
# សហសម័យវិទ្យាស្ថានស្លឹករឹត










*វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថាន ស្លឹករឹត ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែល ដែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែង ដែលដាក់បង្ហាញពីសិល្បៈ និងវប្បធម៌ តាមរយៈ ការតាំងពិព័រណ៍ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និង ការធ្វើបទបង្ហាញរបស់វាគ្មិននានា។ វិចិត្រសាលសិល្បៈ សហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើក កម្ពស់ និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់ កសាងឡើងក្នុងរជ្ជកាលបារាំង សម្រាប់ការដាក់តាំង ពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។*

*សម្រាប់សិស្ស-និស្សិត អ្នកស្រាវជ្រាវ និង សាធារណជនទូទៅ ដែលមានចំណាប់អារម្មណ៍ មកទស្សនានៅមជ្ឈមណ្ឌលឯកសារកម្ពុជា* (DC-CAM) *និងវិចិត្រសាលសិល្បៈសហសម័យ វិទ្យាស្ថានស្លឹករឹត, សូមទាក់ទងមកកាន់* **សុាំង ចិន្តា** *អ្នកសម្របសម្រួល តាមរយៈ ទូរសព្ទលេខ ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖* truthchenda.s@dccam.org

*សូមអរគុណ!*

# ជីវិតគ្រួសារខ្ញុំក្រោយថ្ងៃជម្លៀស

**ជាវ៉ារដ្ឋ មេត្តា**



ថៃ យូហុង
(ថៃ យូហុង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ថៃយូ ហុង។ ខ្ញុំកើតនៅឆ្នាំ១៩៦០ នៅរាជធានីភ្នំពេញ។ ឪពុកខ្ញុំឈ្មោះ តុ ឆ និង ម្តាយខ្ញុំឈ្មោះ លឹម ស៊ីវមួយ គឺជាអ្នកស្រុកស្អាង ខេត្តកណ្តាល។ ឪពុកម្តាយខ្ញុំបានមករស់នៅ និងរកស៊ីនៅភ្នំពេញបន្ទាប់ពីរៀបការរួច។ ម្តាយខ្ញុំគឺជាអ្នកលក់ចាប់ហួយ ហើយឪពុកខ្ញុំគាត់ប៉ិនប្រសប់ធ្វើតុ និងទូ។ ប៉ុន្តែក្រោយមករវាងឆ្នាំ១៩៧៣ ដោយសារស្ថានភាពប្រទេសច្របូកច្របល់ ទាហាន លន់ នល់ ខ្លះបានមកទិញអ៊ីវ៉ាន់ម្តាយរបស់ខ្ញុំមិនឲ្យប្រាក់ ធ្វើឲ្យឪពុកខ្ញុំមានទំនាស់ជាមួយទាហានទាំងនោះជាញឹកញាប់។ ដូច្នេះ ម្តាយខ្ញុំបានសម្រេចចិត្តឈប់លក់អ៊ីវ៉ាន់ មកលក់ តុ ទូ វិញម្តង។

ផ្ទះរបស់ខ្ញុំនៅជិតរោងកុនកំពូលពេជ្រ (ម្តុំពេទ្យចិន) តាមបណ្តោយមហាវិថីព្រះមុន្នីវង្ស។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានអាយុប្រហែលជា១៥ឆ្នាំ។ ខ្ញុំបានឮសំឡេងផ្ទុះអាវុធចេញពីសាលាបឋមសិក្សា១៨ មីនា (បច្ចុប្បន្នសាលាយុគន្ធរ)។ ពេលឃើញយោធាខ្មែរក្រហមចូលមកដល់ ប្រជាជនខ្លះនាំគ្នាស្វាគមន៍ និងទះដៃអបអរសាទរ។ យោធាខ្មែរក្រហមខ្លះឲ្យប្រជាជនលើកទង់ជ័យស។ ខ្ញុំមិនមានទង់ជ័យស ដូច្នេះខ្ញុំបានដោះអាវយឺតរបស់ខ្ញុំពណ៌សដែលកំពុងពាក់លើខ្លួនយកទៅពាក់លើដងទង់ជាតិដាក់បញ្ឈរនៅមុខផ្ទះស្រាប់។ ខ្មែរក្រហមបានស្រែកបញ្ជាថា បងប្អូនដែលមានកាំភ្លើងយកចេញដាក់នៅចិញ្ចើមថ្នល់ម្ខាង។ បងថ្លៃជីដូនមួយរបស់ខ្ញុំឈ្មោះ ជីក ឈុន គឺជាគ្រូបង្រៀន។ នៅសម័យ លន់ នល់ គ្រូបង្រៀន និងប្រជាជនគ្រប់រូបមានសិទ្ធិអាចទិញកាំភ្លើងទុកការពារខ្លួន។ បងឈុន មិនបានយកកាំភ្លើងមកទុកតាមបញ្ជារបស់ខ្មែរក្រហមទេ។

ក្រោយមក ម៉ោងប្រហែលជា១២ថ្ងៃត្រង់ ខ្មែរក្រហមចាប់ផ្តើមប្រកាសឲ្យប្រជាជនចេញពីទីក្រុងដោយនិយាយថា ខ្លាចអាមេរិកទម្លាក់គ្រាប់បែក។ គ្រួសារខ្ញុំបានរៀបចំចាកចេញ។ ខ្ញុំបានយកកាបូបដែលខ្ញុំស្រឡាញ់ស្ពាយជាប់ខ្លួន ដោយក្នុងនោះមាន ប៊ិក សៀវភៅ ព្រោះខ្ញុំគិតថាអាចបានចូលរៀនវិញ និងស្ពាយអង្ករ២០កំប៉ុងនៅលើស្មាថែមទៀត។ ត្រកូលខ្ញុំ ឈ្មោះ ថៃ ប៉ុន្តែឪពុកខ្ញុំបានលុបចោល ដោយយកត្រឹមតែ យូហុង ប៉ុណ្ណោះ ដោយខ្លាចខ្មែរក្រហមគិតថា ខ្ញុំគឺជាជនជាតិថៃ ដែលអាចនឹងមានគ្រោះថ្នាក់។



ក្លោងទ្វារវត្តនរា។ វត្តនរា គឺជាទីកន្លែងដែលឪពុករបស់ ថៃ យូហុង ស្លាប់។
(ថៃ យូហុង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)




មហាវិថីព្រះមុន្នីវង្សជិតស្តុបពេទ្យចិន គឺជាផ្ទះរបស់ ថៃ យូហុង ធ្លាប់រស់នៅមុនពេលយោធាខ្មែរក្រហមចូលមកគ្រប់គ្រងនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។
(ថៃ យូហុង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមគ្រួសារខ្ញុំបានធ្វើដំណើរទៅផ្ទះបងស្រី នៅម្តុំបឹងត្របែក មុនពេលចាកចេញពីទីក្រុងភ្នំពេញ។ ក្រោយមក បង ឈុន ដែលជម្លៀសមកជាមួយ ត្រូវបានយោធាខ្មែរក្រហមបាញ់សម្លាប់ភ្លាមៗបន្ទាប់ពីគាត់ត្រូវបានខ្មែរក្រហមឆែកឆេរឃើញកាំភ្លើងនៅជាប់ខ្លួនរបស់គាត់។ យើងធ្វើដំណើរសំដៅទៅភូមិឫស្សីស្រុក ស្ថិតនៅស្រុកស្អាង ខេត្តកណ្តាល ព្រោះមានម្តាយមីងនៅទីនោះ។ នៅក្នុងភូមិឫស្សីស្រុកមានអ្នករើសអើងគ្រួសារខ្ញុំតិចតួចប៉ុណ្ណោះ។ របបអាហារនៅទីនោះ គឺមានបបរពោតលាយបាយ។ អាហារនេះធ្វើឲ្យខ្ញុំរាកជាញឹកញាប់។ ខ្ញុំត្រូវបានចាត់តាំងឲ្យនៅក្នុងកងកុមារ និងឃ្វាលគោ។ ថ្ងៃមួយខ្ញុំភ័យខ្លាំងណាស់ ព្រោះខ្ញុំធ្វើឲ្យបាត់គោ។ ខ្ញុំមិនចំណាំគោទេ ហើយពេលសម្លឹងហ្វូងគោ គឺដូចៗគ្នាទាំងអស់។ ខ្ញុំត្រូវបានអ្នកនៅក្នុងកងជាមួយសើចចំអក និងរិះគន់ថាជាពួកមូលធន ពេលឃើញស្លឹកគ្រៃថាស្រូវ។

គ្រួសារខ្ញុំរស់នៅភូមិឫស្សីស្រុក បានរយៈពេល ១ សប្តាហ៍ ក្រោយមកមេភូមិបានឲ្យគ្រួសារខ្ញុំទៅចុះឈ្មោះដើម្បីបានទៅរស់នៅភូមិថ្មីមួយទៀត។ ភូមិថ្មីនោះមានឈ្មោះថាភូមិដីស្លាប់ និងមានចម្ងាយប្រមាណជា ៣ គីឡូម៉ែត្រពីភូមិដែលគ្រួសារខ្ញុំរស់នៅ។ យើងរស់នៅភូមិដីស្លាប់បានរយៈពេលកន្លះឆ្នាំ ឪពុករបស់ខ្ញុំក៏បានសុំមេភូមិត្រឡប់មករស់នៅភូមិឫស្សីស្រុកវិញ។

រយៈពេល៣ទៅ ៤ខែ បន្ទាប់មក គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសជាលើកទីពីរទៅកាន់ខេត្តបាត់ដំបង។ មេភូមិបានប្រាប់ប្រជាជនឲ្យជួបជុំគ្នានៅវត្តកោះខែល ស្ថិតនៅឃុំកោះខែ ស្រុកស្អាង ខេត្តកណ្តាល ព្រោះមានឡានមកដឹកយើងទៅដាក់រ៉ឺរថភ្លើងបន្ទុះឡាង។ គ្រួសារខ្ញុំបានដល់វត្តនរា ស្ថិតនៅក្នុងស្រុកសង្កែ ខេត្តបាត់ដំបង។ នៅពេលទៅដល់ទីនោះមានអ្នកភូមិបររទេះ មកចាំដឹកយើងបន្តទៅដាក់នៅភូមិផ្សេងៗ។ មារបស់ខ្ញុំម្នាក់ គឺជាគ្រូបង្រៀន។ គាត់ពូកែប្រាស្រ័យទាក់ទងជាមួយអ្នកភូមិណាស់។ គាត់បានសុំខ្មែរក្រហមរស់នៅភូមិជិតៗនោះ។ យើងត្រូវបានអនុញ្ញាតឲ្យទៅរស់នៅក្នុងចម្ការភ្លៀវ ដែលមានចម្ងាយប្រមាណមួយគីឡូម៉ែត្រពីវត្តនរា។ នៅក្នុងចម្ការ

នោះសម្បូរទៅដោយដើមស្តៅដុះយ៉ាងច្រើន និងងាយស្រួលរកកំពឹសធ្វើយកមកធ្វើម្ហូបទៀតៗ ក្រោយមកស្ថានភាពរស់នៅទីនោះកាន់តែរឹតត្បិត និងមិនអាចបេះរុក្ខជាតិមកធ្វើម្ហូបហូបដូចមុនទេៗ

ខ្ញុំបានចូលកងកុមារៗ ក្រោយមកខ្ញុំត្រូវបានផ្លាស់ចូលក្នុងកងយុវជនវិញ ព្រោះមេកងឃើញខ្ញុំមានមាឌធំ ប៉ុន្តែអ្នកដេរ្ងសំណាងល្អ អាយុដំណាលខ្ញុំមាឌតូចល្អិតនៅធ្វើការក្នុងកងកុមារដដែលៗ ខ្ញុំអាចមកលេងផ្ទះម្តងមួយកាលៗ កងយុវជនខ្ញុំទៅធ្វើការនៅព្រៃរនាម គឺកាប់ព្រៃ និងធ្វើស្រែដែលមានចម្ងាយពីវត្តនរាប្រហែលជា២០ ទៅ៣០ គីឡូម៉ែត្រៗ ថ្ងៃមួយខ្ញុំត្រូវបានប្រធានកងចាត់ឲ្យស្ទូងស្រូវៗ ខ្ញុំមិនដឹងដឹងថាត្រូវស្ទូងយ៉ាងណាទេ ព្រោះមិនធ្លាប់ធ្វើការងារនេះពីមុនមកៗ ខ្ញុំឃើញខ្មែរក្រហមស្ទូងដើរថយក្រោយ ខ្ញុំក៏ដើរថយក្រោយតាម ប៉ុន្តែពេលងាកមើលទៅមុខសន្ទូងមិនត្រង់ជួរឡើយៗ ខ្ញុំត្រូវបានអ្នកនៅក្នុងកងជាមួយស្ទូងបិទជិតរកផ្លូវចេញមិនរួចៗ

ជាធម្មតានៅវេលាម៉ោង៤ភ្លឺ ខ្ញុំតែងឮសំឡេងជួងដាស់ប្រជាជនឲ្យទៅធ្វើការៗ សមាជិកកងខ្លះភ្ញាក់ក្រញាងប៉ុន្តែមិនទាន់បើកភ្នែកនៅឡើយៗ អ្នកខ្លះដើរជំពប់ដុំថ្មទើបបានស្វាងងងុយដេកៗ នៅអំឡុងឆ្នាំ១៩៧៧ នៅខេត្តបាត់ដំបង មានប្រជាជនកើតដំបៅងាររច្រើនណាស់ៗ នៅថ្ងៃមួយ ក្នុងរដូវផ្លែមាក់ប្រេង មាក់ប្រាងទុំ ចំពេលមានខ្យល់បោកបក់ខ្លាំងបណ្តាលជ្រុះផ្លែយ៉ាងច្រើនៗ ខ្ញុំនិងក្មេងៗបានដណ្តើមគ្នារត់ទៅរើសផ្លែឈើទាំងនោះហូប ហើយខ្ញុំក៏បានប៉ះនឹងខ្សែលួសៗ ក្រោយមកក៏ក្លាយជាដំបៅ នឹងរីកកាន់តែធំពីមួយថ្ងៃទៅមួយថ្ងៃដែលចាស់ៗតែងតែហៅ «ដំបៅងារ»ៗ ខ្ញុំបានយកឆ្អឹងខ្មោច បុកលាយជាមួយប្រេងដូងដើម្បីលាប ប៉ុន្តែមិនបានសះឡើយៗ ខ្ញុំនៅតែទៅធ្វើការទោះបីខ្ញុំមានដំបៅ ប៉ុន្តែខ្ញុំបានសុំមេកងមិនចុះទឹកទេៗ នៅថ្ងៃមួយចៃដន្យស្រាប់តែនៅមន្ទីរពេទ្យជិតការរដ្ឋានរបស់ខ្ញុំធ្វើការ មានថ្នាំប៉េនីស៊ីលីន ខ្ញុំបានសុំថ្នាំនេះយកមកលាបលើដំបៅ ស្រាប់តែថ្ងៃបន្ទាប់ដំបៅរបស់ខ្ញុំបានរួមតូចវិញៗ ខ្ញុំបានលាបថ្នាំប៉េនីស៊ីលីនបីដងទៀតលើដំបៅរបស់ខ្ញុំក៏បានជាសះស្បើយៗ

នៅវេលាម៉ោងប្រហែលជា៥ល្ងាចថ្ងៃមួយ ក្នុងឆ្នាំ១៩៧៨ ខ្ញុំបានលួចរត់ចេញពីកងទៅផ្ទះ ហើយបានដេកនៅផ្ទះមួយយប់ៗ ព្រលឹមឡើងស្រាប់តែឈ្លបបានមក



បឹងនៅជិតទីតាំងដែល ថៃ យូហុង ត្រូវបានខ្មែរក្រហមជម្លៀសទៅដល់ជាលើកដំបូងនៅក្នុងឆ្នាំ១៩៧៦ ស្ថិតនៅស្រុកសង្កែ ខេត្តបាត់ដំបងៗ (ថៃ យូហុង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



កាបូបដាក់ប៊ិចរបស់ ថៃ យូ ហុង នៅជាមួយគាត់តាំងពីឆ្នាំ១៩៧២ រហូតមកដល់បច្ចុប្បន្នៗ (ថៃ យូហុង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់ខ្ញុំ យកទៅដាក់គុកកាប់រទេះ។ ខ្ញុំមិនចាំទីតាំងគុកនៅទីណាទេ។ ខ្ញុំឃើញមានអ្នកទោសដេកពីរជួរ និងមានផ្លូវដើរកណ្តាល ព្រមទាំងមានធុងលាមកពីរដាក់នៅដើមផ្លូវមួយ និង ចុងផ្លូវមួយ។ នៅទីនោះមានឆ្មាំគុកយាមខាងមុខម្នាក់ និងខាងក្រោយម្នាក់។ អ្នកទោសជាប់ខ្នោះទាំងអស់។ អ្នកទោសខ្លះដេកផ្ទាល់លើដី ហើយអ្នកទោសខ្លះមានបាវក្រចៅក្រាលធ្វើជាកន្ទេល។ ពេលខ្ញុំទៅដល់ ឈ្លបដាក់ខ្ញុំចូលទៅក្នុងគុកនោះ ហើយពេលយប់ថ្ងៃបន្ទាប់ឆ្មាំគុកបានសួរចម្លើយខ្ញុំ។ ឆ្មាំគុកចោទខ្ញុំថាមានគម្រោងរត់ទៅសៀម។ តាមពិតខ្ញុំមិនដែលស្គាល់សៀមទេ កំហុសរបស់ខ្ញុំគឺលួចរត់មកផ្ទះ។ ពេលខ្ញុំចូលក្នុងគុកដំបូង ខ្ញុំឃើញអ្នកទោសបត់ជើងដាក់ឆ្នាំង ពេលនោះខ្ញុំមានការខ្មាស់អៀនខ្លាំងណាស់ ប៉ុន្តែក្រោយមកខ្ញុំលែងអៀនខ្មាស់ហើយ។ អ្នកទោសបត់ជើងហុចបន្តគ្នា រហូតដល់អ្នកដែលនៅជិតធុងលាមកជាងគេ។ ក្រោយមក ខ្មែរក្រហមបានដោះលែងខ្ញុំ ព្រោះខ្ញុំមានទោសស្រាល។ ខ្ញុំជាប់គុកអស់រយៈពេល៣ខែ៤ថ្ងៃ គឺចាប់ពីខែកុម្ភៈ ដល់ខែឧសភា។ ខ្ញុំចាំថាខ្ញុំជាប់គុកក្នុងរដូវស្វាយខ្ចី ហើយពេលចេញពីគុកវិញនៅរដូវផ្លែស្វាយចាស់។

នៅពេលខ្មែរក្រហមមកពីខាងនិរតីចូលមកគ្រប់គ្រង ក៏មានការប្រែប្រួល បន្ទាប់មកបានរំសាយកងរបស់ខ្ញុំឲ្យមកធ្វើការនៅកន្លែងដើមវិញ។ ខ្ញុំបានវិលត្រឡប់មកធ្វើការនៅជិតវត្តនរាវិញ។ នៅថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានលួចស្តាប់វិទ្យុរបស់ខ្មែរក្រហម នៅពេលដែលខ្ញុំកំពុងបោកស្រូវ។ ក្រោយមក កងទ័ពវៀតណាម បានចូលមកដល់ ហើយខ្មែរក្រហមមួយចំនួនបានរត់គេចពីកងទ័ពវៀតណាម។ ម្តាយខ្ញុំ ប្អូនប្រុសឈ្មោះ យូម៉េង និង បងស្រីទីពីរឈ្មោះ យូរ៉ូយ បានរត់ទៅទីរួមខេត្តបាត់ដំបង។ ឪពុករបស់ខ្ញុំស្លាប់នៅក្នុងឆ្នាំ១៩៧៨ ដោយសារជំងឺនៅក្នុងវត្តនរា ដែលជាអតីតមន្ទីរពេទ្យរបស់ខ្មែរក្រហម។ ខ្ញុំនៅតែចងចាំរឿងនេះ ហើយខ្ញុំតែងតែទៅមើលទីកន្លែងដែលឪពុកខ្ញុំស្លាប់។



រូបទីពីររាប់ពីខាងស្តាំ ៖ ថៃ យូហុង នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។ ថៃ យូហុង បានប្រាប់ភ្ញៀវទេសចរពីបន្ទប់ថ្នាក់ទី៦ក២ ដែលគាត់ធ្លាប់បានរៀនកាលពីទីតាំងនេះគឺអតីតសាលាទួលស្វាយព្រៃ។ (ថៃ យូហុង / មជ្ឈមណ្ឌលឯកសារកម្ពុជា)



រូបទី៣រាប់ពីខាងឆ្វេង ៖ ឪពុករបស់ ថៃ យូ ហុង ឈ្មោះ តុ ឆ ជាមួយបងប្អូនស្រីៗរបស់គាត់។ (ថៃ យូហុង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# រស់ ស៊ីថាត និង កែ ពក

**សោម ប៊ុនថន**





*រូបឆ្វេង៖ រស់ ស៊ីថាត និង ញ៉ែម ឡឿន បន្ទាប់ពីរៀបការនៅខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*រូបស្តាំ៖ កូនរបស់ រស់ ស៊ីថាត ឈ្មោះ ណាល់ សុធី និងម្តាយឈ្មោះ យៀប នៅអំឡុងឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ ញ៉ែម ឡឿន នៅឆ្នាំ១៩៦១។ កាលនោះប្តីខ្ញុំធ្វើជាគ្រូបង្រៀន។ គាត់បានប្រលងជាប់បាក់ឌុប។ ប្តីរបស់ខ្ញុំបានចេញទៅបង្រៀនជាច្រើនកន្លែង។ ក្រោយមក ប្តីរបស់ខ្ញុំបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម និងបានទៅបង្រៀនខាងនយោបាយដល់មនុស្សចាស់ៗនៅភូមិភ្នំគូលែន និងប្រដាក ក្នុងស្រុកស្វាយលើ ខេត្តសៀមរាប នៅអំឡុងឆ្នាំ១៩៧០។ កាលនោះខ្ញុំ និងកូន៣នាក់ បានរស់នៅជាមួយប្តីរបស់ខ្ញុំ។ មានយន្តហោះម្នាក់គ្រាប់បែកសន្ធឹកសន្ធាប់នៅភូមិប្រដាក ប៉ុន្តែមិនបណ្តាលឲ្យបាត់បង់ជីវិតមនុស្ស ហើយក៏មិនត្រូវចំប្រាសាទបូរាណដែរ។ កាលនោះ កែ ពក គឺជាអភិបាល (គណៈ) ខេត្តសៀមរាប បានមកលេងផ្ទះរបស់ខ្ញុំដែលសង់អំពីឈើ និងប្រក់ក្បឿងពីរខ្នងនៅប្រដាក ព្រោះ កែ ពក បានស្គាល់ប្តីរបស់ខ្ញុំនៅពេលគាត់ចូលបម្រើខ្មែរក្រហម។ កែ ពក បានដើរដោយថ្មើរជើងនៅពេលមកលេងផ្ទះខ្ញុំ និងមានកងការពារ ២ ទៅ ៣នាក់ ដែលមានអាវុធនៅជាប់នឹងខ្លួនមកជាមួយ។ កែ ពក និងកងការពាររបស់គាត់ស្លៀកពាក់ខោអាវពណ៌ខ្មៅដូចគ្នា។ កែ ពក ជាមនុស្សរួសរាយ ប៉ុន្តែម៉ឺងម៉ាត់។ ពេលនីសាររបស់គាត់មកយឺត គាត់បានគំហក និងសំឡុតនីសារទាំងនោះ។ ខ្ញុំមិនហ៊ាននៅជិត និងសម្លឹងមុខ កែ ពក ចំទេ ព្រោះខ្ញុំខ្លាចគាត់ និងគិតថាគាត់គឺជាអ្នកធំ។

ខ្ញុំបានស្ងោរ និង អាំងត្រីឆ្តោ និងត្រីរ៉ស់ធំៗ ដែលខាងនេសាទយកមកឲ្យដើម្បីទទួល កែ ពក។ ក្រោយមក កែ ពក

បានមកលេងផ្ទះរបស់ខ្ញុំជាញឹកញាប់ គឺ២ទៅ៣ថ្ងៃ គាត់បានមកលេងផ្ទះខ្ញុំម្តង និងបានសួរនាំខ្ញុំអំពីបងប្អូនបង្កើត។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមិនមានបងប្អូនទេ គឺម្តាយខ្ញុំមានកូនតែខ្ញុំម្នាក់ប៉ុណ្ណោះ។ កែ ពក ក៏បានផ្តាំខ្ញុំឲ្យខសរ្សាហ៊ាំទៅលេងម្តាយរបស់ខ្ញុំដែរ។ គាត់បានមកលេងផ្ទះខ្ញុំតែពេលយប់ប៉ុណ្ណោះ ហើយពេលជួបគ្នាម្តងៗ កែ ពក តែងហៅខ្ញុំថា «មិត្តថាត ឬ គ្រូសារមិត្ត ឡឿន ឬ ខ្សឿន» ព្រោះប្តីខ្ញុំបានប្រើឈ្មោះទាំងពីរនេះ។

ខ្ញុំបានធ្វើការនៅក្នុងកងកាត់ដេរខោអាវឲ្យយោធាខ្មែរក្រហម ចំណែកប្តីរបស់ខ្ញុំ គឺជាគណៈស្រុកស្វាយលើ។ ខ្ញុំនិងមិត្តនារីនៅក្នុងកងកាត់ដេរជាមួយគ្នា ក៏បានជិះម៉ូតូទៅលេងម្តាយរបស់ខ្ញុំ នៅភូមិគកកណ្តាល ឃុំគូងរ៉ុង ស្រុកព្រៃឈរ ខេត្តកំពង់ចាម បានម្តងដែរ។ ខ្ញុំបានធ្វើផ្លែប៉ូវបាន ១០គីឡូយកទៅសៀមរាបវិញ។ កែ ពក ចូលចិត្ត ហូបផ្លែប៉ូវ។

នៅពេលនោះ យោធា និងប្រជាជនមានការខ្វះខាតខោអាវស្លៀកពាក់ ឃើញដូច្នេះខ្ញុំក៏បានស្នើសុំទៅ កែ ពក។ កែ ពក ក៏បានឲ្យក្រណាត់ ១០គីមកខ្ញុំ ដើម្បីកាត់ខោអាវចែកឲ្យអ្នកទាំងនោះ។

ពេលខ្ញុំពរពោះកូនទី៤ អង្គការបានមកយកប្តីខ្ញុំទៅ។ ខ្ញុំបានទៅតាមប្តីរបស់ខ្ញុំនៅសាលាស្រុក ប៉ុន្តែយោធាខ្មែរក្រហមដែលធ្លាប់ស្គាល់ខ្ញុំបានឃាត់ខ្ញុំមិនឲ្យទៅ ដោយនិយាយថា «បងកុំចូលទៅ!»។ ប្តីរបស់ខ្ញុំបានគេអូមកផ្តាំខ្ញុំថា «ប្រសិនបើឪពុកក្មេករបស់ខ្ញុំដែលរស់នៅជាមួយខ្ញុំចង់វិលទៅស្រុកវិញសូមឲ្យគាត់ទៅចុះ»។ ប្តីរបស់ខ្ញុំក៏មិនបាននិយាយអ្វីទៀតដែរ។ បន្ទាប់មក អង្គការបានមកយកខ្ញុំទៅទៀតដោយប្រាប់ថា យកទៅលត់ដំ ប៉ុន្តែតាមពិតយកខ្ញុំទៅសួរចម្លើយ និងឃុំនៅក្នុងផ្ទះហោណាំងមួយខ្នងនៅប្រជាក ក្នុងស្រុកស្វាយលើ។ កូនប្រុសទី៣ របស់ខ្ញុំម្នាក់ក៏ទៅជាមួយខ្ញុំដែរ លើកលែងតែកូនប្រុសច្បងនៅជាមួយម្តាយរបស់ខ្ញុំនៅខេត្តកំពង់ចាម និងកូនប្រុសទី២ នៅជាមួយឪពុកក្មេករបស់ខ្ញុំនៅក្នុងកងសិប្បកម្មធ្វើរទេះ នៅស្រុកស្វាយលើ។ ឆ្មាំគុកបានសួរចម្លើយខ្ញុំ និងបានចោទខ្ញុំថា គឺជាអនុធន មិនចេះធ្វើស្រែ និងមានអ្នកបម្រើ។ ឆ្មាំគុកបានសម្លុត និងយកដំបងបម្រុងវាយខ្ញុំ ប៉ុន្តែខ្ញុំបានចង្អុល និងស្តីឲ្យឆ្មាំគុកវិញថា «មិត្តឯងគិតមើល! ប្រសិនធ្វើបដិវត្តន៍ក្បត់អ៊ីចឹង មិត្តឯងហ៊ានមកធ្វើទេ ចោលម៉ែចោលឪ!»។ ចំណែកកូនរបស់ខ្ញុំភ័យរហូតលេចអាចម៍ក្រោយមកទើបឆ្មាំគុកនោះឈប់សួរ។ នៅព្រឹកថ្ងៃបន្ទាប់ ខ្មែរក្រហមបានបររទេះមកដឹកខ្ញុំយកទៅដាក់នៅក្នុងស្រុកជីក្រែងវិញ។ នៅទីនោះខ្មែរក្រហមបានបញ្ជាខ្ញុំឲ្យជីកដីធ្វើបង្គន់។ ដីរឹងខ្លាំងណាស់ ព្រោះនៅក្នុងខែមេសា (រដូវប្រាំង)។ ខ្ញុំកាប់មួយចបបានជម្រៅមួយថ្នាំងដៃតែប៉ុណ្ណោះ។ ខ្ញុំហូបតែបបរដែលមានសុទ្ធតែដីនៅក្រោមបាតចាននៅពេលជិតសម្រាលកូន។ ថ្ងៃមួយ កែ ពក បានទៅដល់កន្លែងឃុំឃាំងរបស់ខ្ញុំ។ ពេលកូនខ្ញុំឃើញ កែ ពក ក៏ស្រែកប្រាប់ខ្ញុំថា «ម៉ែៗ! នោះអ៊ំមក»។ កូនរបស់ខ្ញុំបានស្គាល់ និងចំណាំ កែ ពក ព្រោះ កែ ពក បានពរវាតាំងពីនៅតូចៗ។ កែ ពក ក្រឡេកឃើញខ្ញុំភ្លាម គាត់ក៏យំ ហើយខ្ញុំក៏យំដែរ។ កែ ពក បានសួរខ្ញុំថា ពីណាយកឯងមក? ខ្ញុំក៏ឆ្លើយថា «បើបងមិនបញ្ជាមក គេមិនយកខ្ញុំមកទេ ខ្ញុំគ្រប់ខែហើយ»។ កែ ពក តបមកខ្ញុំវិញថា «គាត់មិនបានបញ្ជាទេ គាត់សុំស្បថ»។ ខ្ញុំបានសួរគាត់បន្តថា ប្តីរបស់ខ្ញុំ មិត្តឡឿន ស្លាប់ ឬ រស់? សូមបងប្រាប់ខ្ញុំឲ្យត្រង់មក? កែ ពកបានប្រាប់ខ្ញុំថា អត់ស្លាប់ទេ គឺនៅជាមួយគាត់ ហើយគាត់ក៏សួរខ្ញុំវិញថា តើមានខោអាវទេ? ខ្ញុំឆ្លើយថា ខ្ញុំអត់មានទេ ខ្ញុំមានមួយកំប្លេតែប៉ុណ្ណោះ។ កែ ពក បានបញ្ជាឲ្យកូនចៅរបស់គាត់យកខោអាវ៤កំប្លេ មុង ភួយ អង្ករ និងត្រីងៀតមកឲ្យខ្ញុំ ហើយនៅថ្ងៃបន្ទាប់ខ្ញុំក៏កើតបានកូនស្រីទី៤។ បន្ទាប់មក កែ ពក បានឲ្យថ្នាំលេប ថ្នាំកូនខ្ចីមកខ្ញុំផឹក និងបានផ្តាំអ្នកជិតខាងកុំឲ្យប្រណែនខ្ញុំ នៅពេលឃើញខ្ញុំដាំបាយហូប។

នៅពេលកូនស្រីរបស់ខ្ញុំអាយុបាន ៧ខែ កងទ័ពវៀតណាមក៏វាយចូលមកដល់ខេត្តសៀមរាប ខ្ញុំក៏ទៅយកកូន និងឪពុកក្មេករបស់ខ្ញុំនៅស្រុកស្វាយលើត្រឡប់ទៅខេត្តកំពង់ចាមវិញ។

ដំបូងខ្ញុំខឹង កែ ពក ខ្លាំងណាស់នៅពេលយកប្តីរបស់ខ្ញុំទៅ ប៉ុន្តែនៅពេលបានជួបគាត់នៅជីក្រែង ហើយគាត់បានស្បថជាមួយខ្ញុំថាមិនបានបញ្ជាឲ្យចាប់ប្តីរបស់ខ្ញុំ ទើបខ្ញុំរសាយកំហឹង។ ចាប់តាំងពីពេលនោះមកខ្ញុំមិនដែលបានជួប កែ ពក ទៀតទេ។ ខ្ញុំបានឮដំណឹងពីជីដូនមួយរបស់ខ្ញុំដែលរស់នៅអន្លង់វែងថា កែ ពក បានស្លាប់ហើយ។ ខ្ញុំមិនខឹងនឹង កែ ពក ទេព្រោះខ្ញុំកាន់សីលជាង ៣០មកហើយ។ ខ្ញុំតែងតែងធ្វើបុណ្យខួបឧទ្ទិសឲ្យប្តីរបស់ខ្ញុំ។

# បូជាភ្លើង

## សំណួរដែលបានសួរមកខ្ញុំអំពីការសម្លាប់រង្គាលនៅអឺរ៉ុប

*ហេឌី ប្រ្វាយ*

(តពីលេខមុន)



*គំនរស្បែកជើងជនរងគ្រោះនៅក្នុងជំរំស្តុតថូហ្វ ក្នុងទីក្រុងដាស្កនៃប្រទេសប៉ូឡូញ។*
*(សូវិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

### តើអ្នកខ្លាចសេចក្តីស្លាប់ដែរឬទេ?

សេចក្តីស្លាប់មិនមានជាអ្វីដែលខ្ញុំខ្លាចនោះទេ។ អ្វីដែលកាន់តែអាក្រក់ជាងនេះ គឺភាពមិនប្រាកដប្រជា ការរង់ចាំដែលគ្មានទីបញ្ចប់ និងសេចក្តីបារម្ភទៅវិញទេ។ សេចក្តីបារម្ភ គឺតែងតែមាននៅក្នុងចិត្តខ្ញុំជានិច្ច។ សេចក្តីបារម្ភប្រៀបបានដូចជាសំឡេងរហឹមៗ នៅពីខាងក្រោយ នឹងបាត់ទៅវិញលុះត្រាតែនៅពេលណាដែលខ្ញុំមានអារម្មណ៍ភ័យខ្លាចចំពោះការគំរាមកំហែងអាយុជីវិត ដែលខិតជិតចូលមកដល់។

អ្វីដែលខ្ញុំខ្លាចគឺ ថាតើសេចក្តីស្លាប់នឹងមកដល់តាមរបៀបណា។ មិនមានជីវិតបន្តទៀត គឺជាបំណងប្រាថ្នា

ដ៏ធំបំផុតសម្រាប់យើងទាំងអស់គ្នា ប៉ុន្តែផ្លូវដែលនាំយើងទៅដល់ទីនោះទេដែលធ្វើឲ្យយើងភ័យខ្លាច។ ភាពកាចសាហាវឃោរឃៅរបស់ណាហ្ស៊ីអាចធ្វើឲ្យមានការឈឺចាប់យ៉ាងខ្លាំងមុនពេលដែលសេចក្តីស្លាប់ចូលមកដល់។ នោះហើយគឺជាអ្វីដែលខ្ញុំខ្លាច។ ខ្ញុំចាំបានថា នៅពេលដែលខ្ញុំក្រោកឡើងខ្ញុំបានគិតថា «តើខ្ញុំអាចឆ្លងផុតថ្ងៃនេះបានដែរឬទេ?» ប៉ុន្តែខ្ញុំគ្មានពេលក្នុងការសញ្ជឹងគិតនោះទេ។ សំឡេងស្រែករបស់កងការពារនារីណាហ្ស៊ីបានធ្វើឲ្យខ្ញុំស្ទុះចេញពីគ្រែ ហើយមើលកិច្ចការត្រូវធ្វើដែលកំណត់នៅក្នុងរបៀបវារៈដូចជាធ្វើគ្រែចំបើង ទៅបន្ទប់ទឹក និងការរាប់ចំនួនរបស់អ្នកទោស។ បន្ទាប់មកយើងទាំងអស់គ្នាក៏ចាប់ផ្តើមដើរទៅធ្វើការងារ ហើយរហូតទាល់តែខ្ញុំត្រឡប់មកវិញនៅពេលយប់ទើបខ្ញុំមានកម្លាំងដើម្បីគិត។

ថ្ងៃរបស់ខ្ញុំបញ្ចប់ដោយខ្ញុំរំឭកពីកំណាព្យមួយ ដែលនិពន្ធដោយជនជាតិហុងគ្រីម្នាក់ឈ្មោះថា អាវ៉ារណី ហាណុស ដែលបកប្រែជាត្រួសៗថា៖

អរគុណព្រះជាម្ចាស់
សម្រាប់ការវិលត្រឡប់មកវិញនៃពេលល្ងាច
ដែនដីដែលរងទុក្ខសោក
ឥឡូវនេះអាចសម្រាកបានដោយស្ងប់ស្ងាត់។

## តើអ្នកស្វែងរកសម្លៀកបំពាក់យ៉ាងដូចម្តេច?

នៅពេលដែលយើងមកដល់អូសឈ្វិចយើងទាំងអស់គ្នាគឺត្រូវអាក្រាតកាយ។ យើងត្រូវទុកសម្លៀកបំពាក់របស់យើងក្នុងមួយគំនរ ហើយស្បែកជើងរបស់យើងចងជាប់គ្នាដាក់ក្នុងមួយគំនរផ្សេងទៀត។ ខ្ញុំបានគិតដោយស្ងាត់ៗថា តើអ្នកទាំងអស់គ្នានឹងរកសម្លៀកបំពាក់របស់ខ្លួនវិញបានដោយរបៀបណា? ចុងក្រោយទើបខ្ញុំដឹងថា សម្លៀកបំពាក់ទាំងអស់នោះនឹងត្រូវបញ្ជូនទៅប្រទេសអាល្លឺម៉ង់ បន្ទាប់ពីកម្លាំងការងារបានបែងចែកវត្ថុណាដែលមិនអាចប្រើការបានចេញអស់ជាមុន។ សម្លៀកបំពាក់ណាដែលមិនត្រូវបានបញ្ជូនចេញទៅប្រទេសអាល្លឺម៉ង់នឹងត្រូវយកទៅសម្អាត សម្លាប់មេរោគ ហើយលាបឈើឆ្កាងពណ៌លឿងពីលើ ដើម្បីឲ្យអ្នកទោសប្រើប្រាស់។ យើងត្រូវបានគេឲ្យអាវដៃវែងពណ៌ប្រផេះដែលមានប្រវែងខុសគ្នា និងខោអាវក្នុង ដែលមានរូបរាងអាក្រក់ និងធ្វើមកពីក្រណាត់គ្រើមៗ។ ខ្ញុំមិនចាំបានទេថាយើងត្រូវបានគេឲ្យស្រោមជើងឬក៏អត់ ប៉ុន្តែយើងទទួលបានកន្សែងបង់កមួយ ដែលយើងយកមកគ្របក្បាលត្រកោលរបស់ខ្លួន។ នៅពេលដែលយើងត្រូវបានជ្រើសរើសឲ្យធ្វើការងារ យើងត្រូវប្តូរទៅស្លៀកសម្លៀកបំពាក់ «ស៊ីវិល» ដែលមានលាបឈើឆ្កាងពណ៌លឿងពីលើ ដើម្បីកុំឲ្យច្រឡំជាមួយអ្នកដែលមិនត្រូវបានជ្រើសរើស។ សម្លៀកបំពាក់នេះត្រូវបានប្តូរនៅពេលខ្លះ។ នៅពេលដែលអាកាសធាតុត្រជាក់ខ្លាំង យើងទទួលបានសម្លៀកបំពាក់បន្ថែមដែលគេហៅថា «សម្លៀកបំពាក់កក់ក្តៅ»។ ខ្ញុំបានអាវក្រៅមួយ ទោះបីជាអាវនោះស្តើងក៏ដោយ ចំណែកឯ លីវី បានអាវចាក់ដៃវែងមួយ។ ដើមឡើយអាវនោះ គឺជារបស់ប្អូនស្រីជីដូនមួយឈ្មោះថា ជីតស៊ី ដែលលីវី ចូលចិត្តជាងគេ។

ដោយសារតែបែបនេះហើយ ទើបយើងដឹងថាប្អូនស្រីជីដូនមួយក៏បានធ្វើការងារនៅក្រោមស្លាកសរសេរថា «អាបាយ មាហ៍ ហ្វ្រាយ៍ Arbeit macht frei» ការងារធ្វើឲ្យអ្នកមានសេរីភាព ដូចគ្នាដែលជាស្លាកចំអកព្យួរនៅលើច្រកចូលទៅអូសឈ្វិច។ «សម្លៀកបំពាក់កក់ក្តៅ» ត្រូវប្រគល់ត្រឡប់ទៅវិញនៅរដូវផ្ការីក ហើយអ្វីផ្សេងៗទៀត យើងទុករហូតដល់ថ្ងៃដែលត្រូវបានគេរំដោះ។ បន្ទាប់ពីការរំដោះយើងចង់កម្ចាត់សម្លៀកបំពាក់នេះចោលឲ្យបានឆាប់បំផុត និងរកសម្លៀកបំពាក់ថ្មីទៀតមកជំនួសវិញ។ នៅពេលខ្លះ យើងទទួលបានអំណោយពីទាហានអង់គ្លេស ឬយើងត្រូវចេញទៅខាងក្រៅដើម្បីស្វែងរកសម្លៀកបំពាក់ទាំងអស់នោះ ដោយខ្លួនឯង។ យើងអាច «ស្វែងរកឃើញ» សម្លៀកបំពាក់ហាលនៅលើស្ន ហើយក៏បានលួចយកមកដោយពុំទៀង



*សម្លៀកបំពាក់របស់ជនរងគ្រោះនៅក្នុងជំរំស្តុតថូហ្វ ក្នុងទីក្រុងដាស្គ្ក នៃប្រទេសប៉ូឡូញ។ បញ្ជាក់៖ សម្លៀកបំពាក់ដើមរបស់អ្នកទោសត្រូវបានរក្សាទុកនៅបណ្ណសាររសារមន្ទីរស្តុតថូហ្វដើម្បីជៀសវាងការខូចខាត រីឯសម្លៀកបំពាក់នៅក្នុងទូរកញ្ចក់នេះគឺជាការតាំងបង្ហាញ។ (សូរិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ត្រង់ ប៉ុន្តែអាល្លឺម៉ង់ បានយកទៅពីយើងច្រើនជាងអ្វីដែលយើងបានលួចយកមកនេះណាស់។ នេះមិនមែនហៅថាជាចោរនោះទេ ប៉ុន្តែហៅថា «ការរៀបចំសារជាថ្មីម្តងទៀត» ទៅវិញទេ។ នាពេលនោះដែរគេត្រូវការក្មេងស្រីដែលពូកែដេរជាច្រើននាក់។ ភួយ និងកម្រាលជាច្រើនត្រូវបានប្រែក្លាយឲ្យទៅជាសម្លៀកបំពាក់នៅក្រោមម្រាមដៃដ៏រហ័សរហួនរបស់ពួកគេ។ ក្មេងស្រីទាំងនោះបានកែប្រែភួយ និងកម្រាលឲ្យក្លាយទៅជា សំពត់ អាវក្រៅ និងរ៉ូបជាដើម។ ខ្ញុំខ្លួនឯងក៏មានរ៉ូបមួយ ដែលធ្វើមកពីក្រណាត់វាំងននពណ៌បៃតង និងបាន «ស្វែងរកឃើញ» ខោទាហានកងនាវីពណ៌ខៀវមួយគូដែលធ្វើពីរោមសត្វ។ ខ្ញុំស្លៀកខោមួយនោះ ពេលដែលយើងធ្វើដំណើរមកកាន់ប្រទេសស៊ុយអែត។ នៅទីក្រុងលូបេក យើងនិងសម្លៀកបំពាក់ត្រូវបានយកទៅសម្លាប់មេរោគ ហើយមានក្មេងស្រីមួយចំនួនអាចរក្សាទុកសម្លៀកបំពាក់ដែលខ្លួនអាចពាក់បាន។ ចំណែកខ្ញុំបានរក្សាទុកខោទាហានកងនាវីពណ៌ខៀវនោះ និងបានពាក់វាម្តងទៀតទៅកន្លែងធ្វើការដំបូងរបស់ខ្ញុំនៅទីក្រុងស្តុកខុល ។

សម្រាប់ប្រាក់ខែដំបូងរបស់ខ្ញុំ ខ្ញុំបានទិញរ៉ូបពណ៌ខ្មៅមួយធ្វើពីរោមសត្វដែលមានតំលៃ ១០០ គ្រូណារ ដែលស្មើនឹងប្រាក់ខែខ្ញុំមួយខែពេញ។ រ៉ូបនោះពិតជាសាកសមនឹងតម្លៃណាស់។ នៅទីបំផុតខ្ញុំអាចពាក់អ្វីមួយដែល «ថ្មី» ហើយធ្វើឲ្យខ្ញុំមានទំនុកចិត្តពេលដែលខ្ញុំចេញទៅជួបមិត្តភក្តិនៅហាងកាហ្វេនាពេលរសៀលក្នុងថ្ងៃអាទិត្យ។

## តើអ្នកមានជំងឺដែរឬទេ?

នៅពេលនោះ គឺសំខាន់ណាស់ដែលយើងមិនត្រូវមានជំងឺ។ យើងអាចរួចជីវិតបានយូរដរាបណាយើងអាចធ្វើការបានតែប៉ុណ្ណោះ។ ប្រសិនបើយើងឈឺ យើងនឹងមិនមានប្រយោជន៍សម្រាប់ពួកគេទៀតទេ។ យើងដឹងថាប្រសិនបើយើងត្រូវបានចាត់ទុកថាគ្មានប្រយោជន៍គេនឹងបញ្ជូនយើងទៅបន្ទប់ផ្សែងពុល។ ដូច្នេះហើយ យើងកម្រនឹងឈឺធ្ងន់ធ្ងរណាស់។ គ្នាយើងមួយចំនួនដែលធ្លាប់តែឈឺរ៉ាំរ៉ៃភ្លាមៗនោះក៏ជាសះស្បើយអស់ពីជំងឺ។ គ្មានអ្នកឈឺក្បាល ហើយក៏គ្មានជំងឺដំបៅក្រពះទៀតដែរ។

ជួនកាលយើងមានជំងឺតិចតួច ហើយនៅពេលនោះយើងត្រូវទៅមន្ទីរពេទ្យដែលត្រូវបានគេហៅថា «រេវីអឺ» ។ គ្រូពេទ្យនៅទីនោះ ក៏ជាអ្នកទោសម្នាក់ដែរ ហើយនាងមិនមានថ្នាំអ្វីច្រើនដើម្បីបំបាត់ការឈឺចាប់របស់យើងទេ។ ថ្នាំលេបដែលមានឈ្មោះថា «អិចផ្ស៊ីល» ត្រូវបានយកមកប្រើសម្រាប់ការឈឺបំពង់ក និងពងបែកៗ ភាពធូរស្រាលតែមួយគត់ ដែលបានមកពីការទៅមន្ទីរពេទ្យនោះគឺ ពេលវេលាដែលបានសម្រាក និងពាក្យលួងលោមមួយចំនួន។ ប្រសិនបើនរណាម្នាក់ មានជំងឺគ្រុនក្តៅ ឬឈឺខ្លាំងធ្ងន់ធ្ងររហូតដល់មិនអាចធ្វើការបាន យើងព្យាយាមការពារអ្នកនោះ។ យើងជួយធ្វើការរបស់គាត់ ហើយឲ្យគាត់ទៅសម្រាកនៅជ្រុងមួយ និងមានអ្នកចាំឃ្លាំមើលថានឹងមិនមានកងការពារណាហ្ស៊ីរកឃើញគាត់នោះទេ។ ជួនកាលមេបញ្ជាការមានសណ្តានចិត្តល្អ ក៏បានឲ្យគាត់អង្គុយសម្រាកនៅក្នុងរោងការងារ និងជួយការពារគាត់ពីកងការពារណាហ្ស៊ីដោយនិយាយកុហកថា គាត់កំពុងជួយធ្វើការងារនៅខាងក្នុង។ ប្រសិនបើ កងការពារនោះមានអារម្មណ៍ល្អ គេប្រហែលជាឲ្យគាត់នៅ បើមិនដូច្នោះទេគេនឹងដេញគាត់ចេញ។ នៅ រេវីអឺ មានគ្រែជាច្រើន ដូច្នេះអ្នកជំងឺអាចនៅទីនោះ ដោយមិនចាំបាច់ចេញទៅខាងក្រៅដែលមានអាកាសធាតុត្រជាក់នោះទេ។ ហេតុផលដែលធ្វើឲ្យយើងមានភាពភ័យខ្លាចក្នុងការស្នាក់នៅទីនោះ គឺយើងមិនអាចដឹងបានទេថា នៅពេលណាដែលគ្រូពេទ្យណាហ្ស៊ីដើរចូលមកដល់។ នៅពេលគ្រូពេទ្យណាហ្ស៊ីចូលមកដល់ អ្នកជំងឺត្រូវតម្រង់ជួរដោយអាក្រាតកាយ ដើម្បីឲ្យពេទ្យត្រួតពិនិត្យមើល ហើយប្រសិនបើនរណាម្នាក់មានរូបរាងស្គមពេក នោះគឺជាហេតុផលគ្រប់គ្រាន់ដើម្បីកាត់ទោសប្រហារជីវិត។ គ្រូពេទ្យដែលចង់ជួយសង្គ្រោះក្មេងស្រីដែលមានជំងឺអស់ទាំងនោះគឺមិនអាចធ្វើអ្វីបានច្រើនទេ។ ប៉ុន្តែខ្ញុំដឹងពីករណីមួយដែលគ្រូពេទ្យម្នាក់ បានលាក់ក្មេងស្រីដែលមានជំងឺធ្ងន់ធ្ងរនិងសន្លប់បានយ៉ាងប៉ិនប្រសប់ រហូតដល់នាងមិនត្រូវបានគ្រូពេទ្យណាហ្ស៊ីរកឃើញ។ ក្មេងស្រីម្នាក់នោះបានជាសះស្បើយ ហើយក៏ចាកចេញពី រេវីអឺ។ ករណីដ៏គួរឲ្យចាប់អារម្មណ៍មួយទៀតគឺ នៅពេលដែលគ្រូពេទ្យ ណាហ្ស៊ី បានស្រ ឡាញ់ក្មេងស្រីដ៏ស្រស់ស្អាតម្នាក់ ដែលដេកឈឺនៅក្នុង រេវីអឺ។ គ្រូពេទ្យនោះ មិនបានកាត់ទោសប្រហារជីវិតក្មេងស្រីម្នាក់នោះទេ ផ្ទុយទៅវិញគេបានបញ្ជូននាងឲ្យទៅព្យាបាលនៅក្នុង រេវីអឺ របស់ទាហានណាហ្ស៊ី។ រឿងរ៉ាវដែលកើតឡើងបន្ទាប់ពីនោះ ខ្ញុំមិនបានដឹងទេ ហើយខ្ញុំក៏មិនដែលបានឃើញនាងម្តងទៀតដែរ។ ខ្ញុំខ្លួនឯងធ្លាប់បានទៅ រេវីអឺ ប៉ុន្មានដងដែរ នៅពេលដែលជើងរបស់ខ្ញុំកើតដំបៅធំមួយនៅពេលដែលអាកាសធាតុត្រជាក់ខ្លាំង ពីព្រោះតែស្បែកជើងរបស់ខ្ញុំ។ ខ្ញុំមិនដឹងទេថា គឺព្រោះតែថ្នាំលាបដ៏អស្ចារ្យនៅក្នុង រេវីអឺ នោះ ឬក៏មកពីរដូវផ្ការីកដែលជិតនឹងមកដល់នោះទេ ប៉ុន្តែដំបៅនោះក៏ជាសះស្បើយទៅវិញ។

## តើមានកងការពារ ណាហ្ស៊ី ណាមួយដែលចិត្តល្អដែរឬទេ?

ខ្ញុំមិនដែលបានជួបកងការពារណាហ្ស៊ីណាម្នាក់ដែលចិត្តល្អនោះទេ។ អ្នកយាមរបស់យើងមិនដែលចាប់អារម្មណ៍ពីយើងទេ។ អ្នកយាមទាំងនោះគ្រាន់តែធ្វើកិច្ចការរបស់ខ្លួន ហើយប្រសិនបើកិច្ចការទាំងនោះទាក់ទងនឹងការវាយដំអ្នកទោស អ្នកយាមទាំងនោះនឹងប្រើដំបង។ អ្នកយាមខ្លះ



*បន្ទប់ស្នាក់នៅរបស់អ្នកទោស ដែលមានតែគ្រែឈើតូចៗជាច្រើនជាន់ៗ នៅតាមជាន់នីមួយៗ អ្នកទោសពីរទៅបីអ្នកត្រូវបានបង្ខំឲ្យដេកប្រជ្រៀតគ្នាៗ (សូរិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ត្រូវបានគេស្គាល់ថាចិត្តអាក្រក់ខ្លាំង ចំណែកឯខ្លះទៀតគ្រាន់តែចិត្តអាក្រក់ ហើយខ្លះទៀតអាចធ្វើបាបយើងដោយគ្មានមូលហេតុអ្វីទាល់តែសោះៗ អ្នកមិនអាចនិយាយបានទេថា ខ្ញុំធ្លាប់បានទទួលអំពើល្អមួយយ៉ាងពិតប្រាកដៗ កងការពារ ណាហ្ស៊ី ត្រូវបានហ្វឹកហាត់ឲ្យមានតែភាពឃោរឃៅ និងមិនមានមនោសញ្ចេតនាអ្វីទាំងអស់ៗ

នៅក្នុងសុន្ទរកថាដែលមានឈ្មោះអាក្រក់ និងត្រូវបានដកស្រង់ជារឿយៗរបស់ ហ៊ីម ឡឺ បានសរសើរអំពីភាពឃោរឃៅរបស់អ្នកបាញ់សម្លាប់ជនជាតិជ្វីហ្វដោយបានលើកឡើងថា «បានឆ្លងកាត់រឿងទាំងអស់នេះ ហើយនៅតែមានចិត្តនឹងនរ វាបានធ្វើឲ្យយើងខ្លាំងក្លាៗ នេះគឺជាទំព័រដ៏រុងរឿងមួយនៅក្នុងប្រវត្តិសាស្ត្ររបស់យើង»ៗ កងការពារ ណាហ្ស៊ី ក៏ដូចជាយើងទាំងអស់គ្នាដែរ គឺមានទាំងភាពល្អ និងភាពអាក្រក់នៅក្នុងខ្លួនរបស់គេ ប៉ុន្តែពួកគេបែរជាជ្រើសរើសយកភាពអាក្រក់ទៅវិញៗ

ក្រោយមកទើបចាប់ផ្តើមប្រកែកដោះសាថា ខ្លួនបាញ់ប្រហារមនុស្សដោយសារតែខ្លួនត្រូវតែធ្វើបែបនោះៗ ប៉ុន្តែការសិក្សាស្រាវជ្រាវបានបង្ហាញឲ្យឃើញថា រឿងរ៉ាវវ៉ាមិនមែនបែបនេះរហូតនោះទេៗ នៅក្នុងសៀវភៅដែលមានចំណងជើងថា «បុរសសាមញ្ញ» អ្នកប្រវត្តិវិទូលោក គ្រីស្តូហ្វ័រ ប្រោនីង បានចង្អុលបង្ហាញថា មានមនុស្សពីរ ឬបីនាក់តែប៉ុណ្ណោះ ដែលបានដកខ្លួនចេញ បើទោះបីជាអ្នកទាំងអស់នោះត្រូវបានប្រាប់ថាពួកគេនឹងត្រូវបានលើកលែងទោស ប្រសិនបើមនសិការរបស់ខ្លួនមិនអនុញ្ញាតឲ្យសម្លាប់មនុស្សៗ ជំនួសដោយការជ្រើសរើសសម្រាប់ខ្លួនឯង អ្នកទាំងនោះ បានធ្វើតាមសម្ពាធពីមិត្តភក្តិរបស់ខ្លួនៗ ដូចគ្នានេះដែរ ជនជាតិអាល្លឺម៉ង់ដែលល្អត្រឹមត្រូវក៏អាចជ្រើសរើសធ្វើរឿងអាក្រក់នៅក្រោមកាលៈទេសៈណាមួយបានដែរៗ យើងទាំងអស់គ្នាសុទ្ធតែមានជម្រើសៗ អ្នកយាមរបស់យើងគឺជាទាហាន

ណាហ្វ៊ីយក្មេងដែលបានស្បថស្បែយ៉ាងម៉ឺងម៉ាត់ដើម្បីស្តាប់បង្គាប់ ការពារ ព្រមទាំងរស់នៅ និងស្លាប់ដើម្បីមេដឹកនាំរបស់ខ្លួន។ ការអប់រំរបស់ ណាហ្វ៊ី ត្រូវបានចាប់ផ្តើមតាំងពីវ័យក្មេង នៅពេលដែលពួកគេងាយស្រួលនឹងលត់ដំ។ យូរៗម្តងទើបមានអ្នកយាមដែលជាទាហាននៅក្នុងកងទ័ពធម្មតា ដែលជាបុរសវ័យចំណាស់ៗដែល ណាហ្វ៊ី បានកេណ្ឌឲ្យធ្វើជាកងទ័ព។ មានភាពខុសគ្នាយ៉ាងខ្លាំងរវាងទាហានពីរក្រុមនេះ គឺក្រុម ទាហានក្នុងកងទ័ពធម្មតាមានអត្តចរិតស្លូតជាង ពីព្រោះតែចិត្តគំនិតរបស់ពួកគេមិនទាន់ត្រូវបានគេបញ្ចុះបញ្ចូលឲ្យជឿលើមនោគមវិជ្ជាទាំងស្រុងនោះទេ។ មានថ្ងៃមួយ នៅពេលដែលយើងដើរទៅកន្លែងធ្វើការ យើងមិនបានអមដោយកងការពារ ណាហ្វ៊ីវ័យក្មេងដែលកាន់ដំបងនោះទេ ប៉ុន្តែគឺជំនួសទៅដោយក្រុម ទាហានដែលមានស្ពាយកាំភ្លើងនៅលើខ្នង។ នេះគឺជាលើកទីមួយ និងតែម្តងគត់ដែលអ្នកយាមនិយាយជាមួយយើងធម្មតា និងមិនស្រែកបញ្ជាមកយើង។ មានទាហានម្នាក់ឈ្មោះថា ហ៊ីម៉ាន់ ហាក់បីដូចជាមានការជឿងឆ្ងល់ច្រើន ហើយដោយសារតែខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមមនុស្សមួយចំនួនតូចដែលចេះនិយាយភាសាអាល្លឺម៉ង់ គាត់ក៏បានដើរមកក្បែរខ្ញុំនៅពេលដែលយើងកំពុងដើរជាប្រាំជួរ។ គាត់បានចាប់ផ្តើមនិយាយជាមួយខ្ញុំ និងសួរខ្ញុំថា តើឯងជាអ្នកណា ហើយមកពីកន្លែងណា។ គាត់បានប្រាប់ខ្ញុំបន្តិចបន្តួចអំពីការលំបាកមួយចំនួនរបស់គាត់។ គាត់មានកូនស្រីម្នាក់ដែលមានអាយុស្របាលខ្ញុំ ហើយប្រហែលជាបែបនេះហើយបានជាគាត់មករកខ្ញុំប៉ុន្មានដងនៅពេលដែលក្រុម ទាហានរបស់គាត់ស្នាក់នៅក្នុងជំរំ។ ពេលខ្លះគាត់យកផ្លែប៉ោម ឬដំឡូងមកឲ្យខ្ញុំ។ ប៉ុន្តែគាត់ក៏មានអាហារតែបន្តិចបន្តួចដូចគ្នានឹងខ្ញុំដែរ។ ភាពរាក់ទាក់របស់គាត់គឺជាពន្លឺព្រះអាទិត្យនៅក្នុងជីវិតរបស់ខ្ញុំដែលពោរពេញទៅដោយភាពងងឹត។ ប៉ុន្តែអ្វីៗគឺមានរយៈពេលមួយភ្លែតតែប៉ុណ្ណោះ។ មិនយូរប៉ុន្មានកងការពារ ណាហ្វ៊ីវ័យក្មេងដែលវាយដំយើងដោយគ្មានប្រណីមេត្តា ប្រសិនបើនរណាម្នាក់ដួល ឬចេញពីជួរ បានវិលត្រឡប់មកយាមវិញ។ មានពេលខ្លះយើងដើរកាត់សួនបន្លែដែលទើបតែប្រមូលផលបានដូចជាសណ្តែកប្រូសែល ខាត់ណា និងបន្លែជាច្រើនទៀត។ នៅពេលណាដែលយើងឃើញបន្លែដែលសេសសល់ដុះចេញពីក្នុងភក់ យើងក៏ស្ទុះទៅដកវាចេញមក បើទោះបីជាប្រឈមនឹងការវាយដំក៏ដោយ ពីព្រោះនេះ គឺជាការបន្ថែមដ៏មានតម្លៃទៅនឹងរបបអាហារដ៏ក្រខ្សត់របស់យើង។ ជាពិសេសចំពោះអ្នកដែលឈឺ ហើយត្រូវបង្ខំខ្លួនទៅធ្វើការងារ។ អេលីហ្សាបែត ដែលជានារីជនជាតិ ហុងគ្រី-ជ្វីហ្វ ដ៏ស្រស់ស្អាតម្នាក់មានជំងឺយ៉ាងធ្ងន់ធ្ងរ ហើយបាត់បង់ស្មារតី។ នាងត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យ។ នៅថ្ងៃបន្ទាប់គ្រូពេទ្យ ណាហ្វ៊ី បានមកដល់ ហើយដើរពិនិត្យតាមគ្រែអ្នកជំងឺគ្រប់ៗគ្នា និងឲ្យគ្រូពេទ្យនៅ រេវីអឺ ដឹងពីការសម្រេចចិត្តរបស់គាត់តាមរយៈការងក់ក្បាល។ មកដល់គ្រែរបស់ អេលីហ្សាបែត គាត់សួរអំពីជំងឺរបស់នាង។ គាត់បានហៅនាងជាមួយនឹងពាក្យទន់ភ្លន់ថា «ហើយចុះឯងក្មេងស្រីតូច តើឯងឈឺអ្វី?» នាងឆ្លើយថា «ខ្ញុំចុករោយគ្រប់កន្លែងទាំងអស់ ខ្ញុំមិនមែនជាក្មេងទៀតទេ ខ្ញុំធ្លាប់បានរៀនអំពីប្រភេទថ្នាំពេទ្យម្តងហើយ»។

ពេទ្យ ណាហ្វ៊ី បន្ទាប់មកបញ្ជាថា នាងគួរតែបញ្ជូនទៅជំរំមួយទៀត។ នៅទីនោះនាងបានវិលត្រឡប់មកមានសុខភាពដូចធម្មតាវិញ។ មនុស្សដដែល ដែលគ្មានមនសិការបន្តិចណាសោះ នៅពេលបញ្ជូននរណាម្នាក់ឲ្យទៅស្លាប់ ត្រឡប់បានសង្គ្រោះជីវិតអ្នកដទៃម្នាក់ទៅវិញ។ យើងពេលខ្លះក៏ជួបរឿងដែលស្មុគស្មាញបែបនេះនៅក្នុងសង្គម។

មានថ្ងៃមួយទៀតមិត្តរបស់ខ្ញុំឈ្មោះ លីលី បានសន្លប់។ យើងទាំងអស់គ្នាមានទុក្ខព្រួយយ៉ាងខ្លាំងនៅពេលដែលនាងត្រូវបានបញ្ជូនទៅ រេវីអឺ។ បន្ទាប់ពីប៉ុន្មានថ្ងៃបានកន្លងផុតទៅ ហើយនៅតែមិនទាន់បានឃើញនាងវិលត្រឡប់មកវិញទៀត យើងទាំងអស់គ្នាបានសន្និដ្ឋានថា យើងនឹងមិនអាចឃើញនាងម្តងទៀតនោះទេ។ ប៉ុន្តែក្នុងមួយរំពេចសោះ នាងបែរជាកំពុងតែឈរក្នុងអំឡុងពេលរាប់ចំនួនអ្នកទោសទៅវិញ។ នៅពេលដែលយើងសួរនាងថា

តើមានរឿងអ្វីបានកើតឡើង នាងបាននិយាយថានាងចាំបានមិនសូវច្បាស់លាស់ទេថា ត្រូវបានគេយកទៅលាក់នៅក្នុងប្រអប់តូចមួយរាល់ពេលដែលគ្រូពេទ្យ ណាហ្ស៊ី ដើរចូលមកដើម្បីត្រួតពិនិត្យ។ បុគ្គលិកនៅក្នុង វេរីអឺ ក៏ជាអ្នកទោសដូចជាយើងដែរ ហើយភាពឃោរឃៅរបស់កងការពារ ណាហ្ស៊ី អាចពេលខ្លះកាត់បន្ថយបានដោយភាពសាមគ្គីរវាងអ្នកទោសដូចគ្នា។

សារ៉ា ដែលជាអ្នកទោសម្នាក់មកពីប្រទេសប៉ូឡូញ បានប្រាប់ខ្ញុំថា មុនពេលចាប់ខ្លួនគាត់បានលាក់ខ្លួននៅកន្លែងដែលគាត់ជឿជាក់ថាមានសុវត្ថិភាព។ ប៉ុន្តែគាត់ត្រូវតែប្រាប់នរណាម្នាក់អំពីគម្រោងនេះ ដើម្បីឲ្យប្ដីរបស់គាត់អាចរកគាត់ឃើញ។ គាត់បានជ្រើសរើសប្រាប់អ្នកជិតខាងម្នាក់ឈ្មោះថា អេន ដែលតែងតែមានសណ្ដានចិត្តល្អចំពោះគ្រួសារគាត់។ ថ្ងៃបន្ទាប់មក ប៉ូលីសបានមករកសារ៉ា ហើយនៅពេលនោះហើយដែលគាត់ដឹងថាសេចក្ដីសប្បុរសធម៌របស់អ្នកជិតខាង គឺតែងតែមានកម្រិតរបស់វា។ សព្វថ្ងៃនេះ ខ្ញុំតែងតែគិតថា តើខ្ញុំនឹងធ្វើបែបណា ប្រសិនបើខ្ញុំ អ្នកដែលបានកើតក្នុងឆ្នាំ១៩២៤ នៅទីក្រុងស៊ីហ្គេត បានឃើញពន្លឺថ្ងៃជានារីជនជាតិអាល្លឺម៉ង់ម្នាក់នៅ បែរឡាំង វិញនោះ។ ខ្ញុំប្រាកដជាត្រូវបានទទួលការបញ្ចុះបញ្ចូលឲ្យប្តូរគំនិតនៅក្នុងសមាគមសម្រាប់ក្មេងស្រីអាល្លឺម៉ង់ដែលដូចគ្នាទៅនឹងសមាគមរបស់ក្មេងប្រុសអាល្លឺម៉ង់ដែរ។

ខ្ញុំប្រហែលជាក្លាយទៅជាកងការពារនារី ណាហ្ស៊ី ។ ពួកគេក៏មិនល្អប្រសើជាងខាងបុរសប៉ុន្មានដែរ។ តើខ្ញុំនឹងធ្វើយ៉ាងណា? តើខ្ញុំអាចវាយអ្នកទោសដែរឬទេ? ជួយអ្នកទោសដែរឬទេ? ប្រសិនបើខ្ញុំ មានឪពុកម្ដាយដែលមានក្រមសីលធម៌ខ្ពស់ក្នុងការចិញ្ចឹមបីបាច់កូនដែលអាចទប់ទល់នឹងមនោគមវិជ្ជានៅក្នុងសម្ព័ន្ធនៃក្មេងស្រីអាល្លឺម៉ង់បាន ខ្ញុំប្រហែលអាចជាទាហានម្នាក់ក្នុងចំណោមទាហាន «ចិត្តល្អ» ក្នុងទាហាន ណាហ្ស៊ី។ ខ្ញុំបានត្រឹមតែសង្ឃឹម។ ប្រសិនបើមនុស្សម្នាក់ដឹងថាខ្លួនមានជម្រើស នោះក៏អាចមានន័យដែរថា គេមានឱកាសក្នុងការជ្រើសរើសអំពើល្អ។

ប៉ុន្តែខ្ញុំអាចប្រាប់អ្នកអំពី ណូអា ដែលមានអាយុ ១២ឆ្នាំ បានមានប្រតិកម្មបែបណានៅពេលដែលគេផ្ដល់ជម្រើសឲ្យគាត់។ គាត់រស់នៅក្នុង ហ្គេតូ ដែលមានតែភាពអត់ឃ្លាន។ អ្នករាល់គ្នានៅទីនោះព្យាយាមស្វែងរកអាហារដើម្បីបរិភោគតាមរយៈការលួច។ កុមារ គឺជាអ្នកដែលមានជំនាញលួចជាងគេ។ កុមារទាំងនោះលួចចេញពី ហ្គេតូ ជាមួយនឹងអ្វីដែលអាចប្ដូរយកអាហារបាន។ ជាញឹកញាប់កុមារទាំងនោះបានត្រឡប់មកវិញជាមួយនឹងដំឡូង ឬ ផែ្លឈើ។

មានថ្ងៃមួយ ណូអា ត្រូវបានចាប់ខ្លួនដោយកងការពារណាហ្ស៊ី ហើយចង់ដឹងថា តើអ្នកណាជាអ្នកនៅពីក្រោយរឿង «ចេញទៅក្រៅ» នេះ។ ណូអា បានបដិសេធមិនឆ្លើយសំណួរ។ កងការពារ ណាហ្ស៊ី បានល្បួង ណូអា ដោយនិយាយថា ណូអា អាចរក្សាទុកដំឡូងដែលលួចយកមកបាន ហើយនិងទទួលបានបន្ថែមមួយទៀត ព្រមទាំងអាចបានតែងតាំងឲ្យទៅជាប៉ូលីសហ្គេតូ។ ប៉ូលីស ហ្គេតូ ទទួលបានអត្ថប្រយោជន៍បន្ថែមព្រមទាំងទទួលបានម្ហូបអាហារជាច្រើនខណៈពេលដែលអ្នករស់នៅទីនោះកំពុងតែស្រេកឃ្លាន។ ណូអា បានបដិសេធយ៉ាងម៉ឺងម៉ាត់ក្នុងការធ្វើជាអ្នកផ្ដល់ព័ត៌មានឲ្យកងការពារ ណាហ្ស៊ី ទោះបីជាដឹងថា ខ្លួននឹងត្រូវបានកងការពារ ណាហ្ស៊ី វាយដំព្រោះតែការមិនគោរពកោតខ្លាចយ៉ាងណាក៏ដោយ។

## តើអ្នកធ្លាប់សុបិននៅពេលយប់ដែរឬទេ?

ភ្លាមៗនោះ ខ្ញុំនឹងឆ្លើយថាទេ។ ប៉ុន្តែអ្វីៗមិនតែងតែដូចគ្នាទាំងអស់ទេ អ្វីទាំងអស់ផ្លាស់ប្ដូរអាស្រ័យទៅតាមកន្លែងដែលយើងរស់នៅ។

នៅអូសឈ្វិច យើងមានពេលដេកតែបន្តិចម៉ោង ហើយយើងដេកដូចជាមនុស្សសន្លប់ បន្ទាប់ពីត្រូវបានវាយ១ដុំថ្ម។ នោះគឺជាការដេកលក់ភ្លឹងដោយមិនមានសុបិនអំពីអ្វីទាំងអស់។ នៅក្នុងជំរំពលកម្មអ្វីៗ គឺខុសគ្នា។



*បន្ទប់ព្យាបាលជំងឺនៅជំរំស្តុតថូហ្វ ដែលគេហៅថា រេវីអឺរ។ អ្នកទោសណាដែលមានជំងឺធ្ងន់ធ្ងរគឺមិនត្រូវបានព្យាបាលនោះទេ ពួកគេនឹងត្រូវបានយកទៅសម្លាប់ចោល។ បន្ទប់ព្យាបាលមួយចំនួននៅតាមជំរំប្រមូលផ្តុំផ្សេងៗទៀត គឺមិនមែនសម្រាប់ព្យាបាលអ្នកទោសនោះទេ ប៉ុន្តែគឺជាបន្ទប់សម្រាប់ធ្វើការពិសោធន៍យ៉ាងសាហាវឃោរឃៅទៅលើអ្នកទោស។ (សូវិចិត្រ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ទោះបីជាម៉ោងដេករបស់យើងមិនមានរយៈពេលយូរក៏សុបិន គឺតែងតែកើតមានជានិច្ច។ ជាធម្មតាយើងសុបិនថាយើងកំពុងតែនៅក្នុងផ្ទះជាមួយនឹងក្រុមគ្រួសារនៅពេលនោះភ្ញាក់ពីសុបិន គឺមានការឈឺចាប់ខ្លាំងណាស់។ ខ្ញុំសុបិនថាខ្ញុំកំពុងដើរកាន់ដៃជាមួយឪពុករបស់ខ្ញុំនៅលើវាលស្មៅក្រោមពន្លឺព្រះអាទិត្យ ហើយគាត់កំពុងតែប្រាប់ខ្ញុំអំពីរឿងមួយ  ប៉ុន្តែនៅពេលដែលពន្លឺភ្លើងបានបើកសំឡេងឪពុករបស់ខ្ញុំបានប្តូរទៅជាសំឡេងកាចអាក្រក់របស់អាល្លឺម៉ង់ទៅវិញ  អ័វហ្វាហិន (AUFWACHEN) ភ្ញាក់ឡើង! ស្នេល (SCHNEL) លឿនឡើង! រោស! រោស! (RAUS RAUS) ចេញ! ចេញ!.....

ខ្ញុំបានព្យាយាមស្រមៃថា  ក្តីសុបិន  គឺជាការពិតចំណែកឯការងារប្រចាំថ្ងៃរបស់ខ្ញុំ គឺគ្រាន់តែជាក្តីសុបិនអាក្រក់មួយប៉ុណ្ណោះ...ខ្ញុំព្យាយាមរក្សាភាពនឹងនរនៅក្នុងការពិតដ៏ឃោរឃៅមួយនេះជាមួយនឹងការស្រមើស្រមៃរបស់ខ្ញុំ។

# តើអ្វីទៅដែលល្អបំផុត?

ល្អបំផុត? តើមានអ្វីទៅដែលអាចហៅបានថាល្អបំផុត? នៅពេលដែលខ្ញុំទទួលបានសំណួរមួយនេះ ខ្ញុំស្រឡាំងកាំង។ គ្មានអ្វីដែលល្អនោះទេ ប៉ុន្តែមានពេលខ្លះដែលយើងអាចបំភ្លេចបានថា យើងនៅទីកន្លែងណា ព្រមទាំងអាចសើចសប្បាយបាន។ ខ្ញុំមានអារម្មណ៍ល្អនៅពេលយប់វា គឺជាពេលដែលការងារនឿយហត់ទាំងប៉ុន្មានបានចប់សព្វគ្រប់ទៅ ហើយខ្ញុំអាចសណ្ដូកជើងដែលចុករោយនៅលើគ្រែដ៏រឹងរបស់ខ្ញុំបាន។ យើងបានរួចជីវិតមួយថ្ងៃទៀតហើយ។ ខ្ញុំដឹងថា ពេលយប់មានរយៈពេលខ្លីណាស់ ហើយខ្ញុំនឹងមិនមានពេលសម្រាកច្រើននោះទេ ប៉ុន្តែទោះបីជាយ៉ាងណាពេលនោះ គឺខ្ញុំមានអារម្មណ៍ល្អ។

មុនពេលចូលដេក ក្រុមមិត្តភក្តិរបស់ខ្ញុំបានអង្គុយនៅលើគ្រែមួយជុំគ្នា ហើយបាន «បើកហាង អក្សរសាស្ត្រ» មួយ។ យើងសូត្រកំណាព្យ អានរឿង ហើយសួរថាតើនរណាអាចចងចាំអំពីអ្វីខ្លះ ឬក៏ពេលខ្លះយើងទាំងអស់គ្នា «ចម្អិនអាហារ» ផ្លាស់ប្តូររូបមន្តធ្វើម្ហូប និងនិយាយអំពីមុខម្ហូបឆ្ងាញ់ៗ ដែលយើងចង់បរិភោគ។ ខ្ញុំមានបទពិសោធន៍ដ៏ពិសេសមួយនៅ អូសឈ្វិច ដែលបានផ្ដល់ពន្លឺខ្លះមកក្នុងជីវិតដែលពោរពេញទៅដោយភាពខ្មៅងងឹតរបស់យើង។ មានព្រឹកមួយកងការពារ ណាហ្ស៊ី បានចូលមកក្នុងបន្ទាយ ហើយសួរកអ្នកស្ម័គ្រចិត្តពីរនាក់ ដើម្បីទៅធ្វើការ។ មិត្តរបស់ខ្ញុំឈ្មោះថា អុលហ្គា និងខ្ញុំបានស្ម័គ្រចិត្ត។ បន្ទាប់មកកងការពារ ណាហ្ស៊ី ដែលមានស្ពាយកាំភ្លើងនៅលើខ្នងនោះនាំយើងចេញទៅ។ យើងបានឆ្លងកាត់ពីតំបន់មួយទៅតំបន់មួយទៀតដែលហ៊ុមព័ទ្ធជុំវិញទៅដោយរបងបន្លាលួសរហូត យើងបានមកដល់កន្លែងមួយដែលមានបន្ទាយតូចជាងជំរំរបស់យើង។ នេះគឺជាជំរំទាហាន ហើយយើងត្រូវបានបញ្ជាឲ្យបោសសម្អាត និងដុសខាត់ឥដ្ឋ។ នៅពេលដែលយើងទៅជិតដល់បន្ទាយដើមឈើពណ៌បៃតងស្រស់បានទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំយ៉ាងខ្លាំង។ នេះប្រៀបបានដូចជាអព្ភូតហេតុមួយ នៅពេលដែលយើងបានឃើញរុក្ខជាតិពណ៌បៃតងបែបនេះ បន្ទាប់ពីរស់នៅក្នុង អូសឈ្វិច ដែលមានតែពណ៌ប្រផេះ។ នៅខាងក្រៅ គឺមានជីវិតស្រស់បំព្រង អ្វីៗមិនបានបាត់បង់នោះទេ។ អុលហ្គា និងខ្ញុំបានត្រឹមតែឈរសម្លឹងមើលជុំវិញ។ មុនដំបូងយើងសម្លឹងមើលទៅដើមឈើ បន្ទាប់មកមើលមុខគ្នាទៅវិញទៅមក ហើយដោយមិនចាំបាច់ប្រើពាក្យនិយាយ យើងក៏អាចដឹងបានដែរថា ម្នាក់ទៀតកំពុងតែគិតអំពីអ្វី។ យើងទាំងពីរនាក់បានសម្រេចចិត្តលួចយកស្លឹកឈើខ្លះចូលទៅក្នុងជំរំ ដើម្បីឲ្យមិត្តគ្រប់គ្នាបានឃើញដែរ។ ទាហានបានបង្ខំឲ្យយើងប្រញាប់ប្រញាល់ដើរចូលក្នុងជំរំដើម្បីចាប់ផ្តើមធ្វើការងារ។ គេបញ្ជាយើងឲ្យយកធុងដែលមានទឹកត្រជាក់ និងក្រណាត់កន្ទបដើម្បីសម្អាតឥដ្ឋ។ វាបានក្លាយទៅជាការងារមួយដែលលំបាក។ ដើម្បីធ្វើឲ្យឥដ្ឋកខ្វក់នោះស្អាត បន្តិចយើងត្រូវការមែកឈើមួយចំនួនដើម្បីឆ្កឹះដីកខ្វក់ចេញពីឥដ្ឋ។ នៅក្រោមការស្រែកជេរប្រទេចដ៏គួរឲ្យរំខានរបស់ពួកទាហានយើងត្រូវធ្វើកិច្ចការយ៉ាងលំបាកនោះ ដោយប្រើមែកឈើព្រមទាំងក្រញូរដៃ និងក្រចករបស់យើង ដើម្បីដុសសម្អាតឥដ្ឋនោះឲ្យបានស្អាត។

នៅពេលដែលមានសញ្ញាប្រាប់ថា ពេលវេលាធ្វើការងារបានបញ្ចប់ យើងអាចដកដង្ហើមបានស្រួលម្តងទៀត។ «ហ្វីយ៉ាអាបិន FEUERABEND» ទាហានបាននិយាយថាដល់ពេលល្ងាចហើយ។ យើងត្រូវត្រឡប់ទៅជំរំវិញ ដើម្បីឈររង់ចាំការរាប់ចំនួនអ្នកទោស។ ខ្ញុំបានលួចបេះស្លឹកឈើមួយចំនួន ប៉ុន្តែនៅតាមផ្លូវត្រឡប់មកវិញ ខ្ញុំភ័យខ្លាចខ្លាំងណាស់ តើខ្ញុំអាចលួចយកវាចូលទៅក្នុងជំរំបានដោយជោគជ័យដែរឬទេ ឬយើងទាំងពីរនាក់នឹងត្រូវបានគេឆែកឆេរខ្លួន។ ការនាំយកស្លឹកឈើជាច្រើនចូលក្នុងជំរំត្រូវបានគេហាមឃាត់យ៉ាងតឹងរ៉ឹងបំផុត។ ខ្ញុំបានលាក់មែកឈើនៅក្នុងសម្លៀកបំពាក់របស់ខ្ញុំ និងបានដាក់ស្លឹកឈើនៅក្នុងមាត់។ អុលហ្គា ក៏បានធ្វើបែបនេះដែរ។ ដោយបេះដូងញាប់ញ័រ យើងបានដើរហួស




*សារធាតុគីមីដែលមានឈ្មោះថា ហ្សុីក្លូនប៊ី ដែលណាស៊ីប្រើប្រាស់ដើម្បីសម្លាប់អ្នកទោសនៅក្នុងបន្ទប់ផ្សែងពុល។ (សូរិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

អ្នកយាមរបង ហើយយើងក៏បានរួចខ្លួន។ ប៉ុន្តែជើងរបស់យើងនៅតែញ័រនៅពេលដែលយើងឈរង់ចាំការរាប់ចំនួនអ្នកទោសឲ្យដល់ទីបញ្ចប់។ បន្ទាប់មកនៅពេលដែលយើងចូលទៅដល់ក្នុងជំរំ ហើយបង្ហាញស្លឹកឈើនោះទៅមិត្តភក្តិ ពួកគេមានសេចក្តីរីករាយយ៉ាងខ្លាំង។ ក្តីសង្ឃឹមមួយបានកើតមានឡើងនៅក្នុងចិត្តរបស់យើងទាំងអស់គ្នា ដែលគឺជាក្តីសង្ឃឹមមួយថា អនាគតដ៏ត្រចះត្រចង់មួយកំពុងតែរង់ចាំ។

## តើអ្នកដឹងនៅពេលណាថាអំពើប្រល័យពូជសាសន៍បានកើតឡើង?

ក្នុងអំឡុងពេលសង្គ្រាមលោកលើកទី ២ ពាក្យថា «អំពើប្រល័យពូជសាសន៍» មិនមានទេ ហើយក៏មិនមាននៅក្នុងវចនានុក្រមរបស់នរណាម្នាក់ដែរ។ ខ្ញុំបានឃើញច្បាស់អំពីការសម្លាប់រង្គាលនៅពេលដែលខ្ញុំនៅក្នុងជំរំអូសឈ្វិច។ កន្លងមក មិនមានមនុស្សជាច្រើនទេដែលយល់ថានេះ គឺមិនមែនគ្រាន់តែជាការសម្លាប់បុគ្គលខ្លះនោះទេ ប៉ុន្តែគឺសំដៅទៅលើមនុស្សទាំងអស់ដែលនឹងត្រូវសម្លាប់ចោលចេញពីលើពិភពលោកនេះ។

## តើអ្នកស្រមៃឃើញជីវិតបន្ទាប់ពីសង្គ្រាមបានយ៉ាងដូចម្តេច?

ខ្ញុំមិនបានគិតដិតដល់នោះទេ។ អាល្លឺម៉ង់នឹងចាញ់សង្គ្រាម គឺជាអ្វីដែលខ្ញុំជឿជាក់យ៉ាងខ្លាំង ខ្ញុំមិនបានដឹងថាអ្វីៗគ្រប់យ៉ាងមិនអាចវិលត្រឡប់ទៅដូចដើមវិញបានទេ។ ខ្ញុំជឿថា បន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅ ត្រង់ស៊ីលវ៉ានី

នឹងក្លាយទៅជាផ្នែកមួយនៃប្រទេសរូម៉ានីម្តងទៀត។ ក្តីសុបិនក្នុងវ័យជំទង់នៅតែមាននៅក្នុងចិត្តរបស់ខ្ញុំជានិច្ច។ ខ្ញុំនឹងត្រឡប់មករៀនមុខវិជ្ជាពេទ្យ និងហ្វឹកហាត់ជាវេជ្ជបណ្ឌិតឯកទេសជំងឺកុមារ។ ខ្ញុំនឹងទៅប្រទេសអាហ្វ្រិកដើម្បីព្យាបាលជំងឺ។

ខ្ញុំមិនអាចស្រមៃដឹងទេថា ទោះបីជាក្រុមសម្ព័ន្ធមិត្តបានឈ្នះសង្គ្រាមក៏ដោយ ក៏គ្មានអ្វីដែលអាចវិលត្រឡប់ទៅដូចកាលពីមុនបានដែរ។

តើយើងមិនបានសិក្សាអំពីប្រវត្តិវិទ្យានៅក្នុងសាលារៀនទេឬ? យើងបានសិក្សា ប៉ុន្តែភាគច្រើនគឺអំពី ថ្ងៃខែឆ្នាំ ឈ្មោះរបស់អ្នកដែលកាន់អំណាចនិងសមរភូមិតែប៉ុណ្ណោះ។ នេះគឺជាការរៀនសូត្រដែលមិនជិតជាប់អារម្មណ៍របស់យើង ហើយនិងត្រូវបានបំភ្លេចចោលយ៉ាងឆាប់រហ័ស។ ខ្ញុំមិនបានត្រៀមខ្លួននោះទេ។ ខ្ញុំមិនបានយល់ទេថាជីវិតមិនអាចវិលត្រឡប់ទៅដូចកាលពីមុនបានទេ។ ទោះបីជាខិតខំប្រឹងប្រែងខ្លាំងប៉ុនណា ក៏ខ្ញុំមិនអាចស្រមៃមើលឃើញនូវអ្វីដែលកើតឡើងក្រោយពីសង្គ្រាមបានឡើយ។

## តើមានរឿងអ្វីបានកើតឡើងទៅលើប្អូនស្រីរបស់អ្នក?

លីវី បានជួយជីវិតរបស់ខ្ញុំនៅក្នុងជំរំ ប៊ឺជិន-បែលសិន។ ក្នុងអំឡុងពេលចលាចលបន្ទាប់ពីការរំដោះ ខ្ញុំក្តៅខ្លួនយ៉ាងខ្លាំង ហើយបានសន្លប់បាត់បង់ស្មារតី។ លីវី បានរកឃើញគ្រូពេទ្យម្នាក់ ក្នុងចំណោមអ្នកទោសរំដោះ ដែលពេលនោះគាត់ក៏ហាក់បីដូចជាត្រូវការគ្រូពេទ្យដើម្បីព្យាបាលខ្លួនឯងដែរ។ ខ្ញុំចាំមុខរបស់គាត់បាននៅពេលដែលគាត់និយាយថា «ត្រូវហើយ អ្នកមានជំងឺ ហើយអ្នកដែលឈឺភាគច្រើនស្លាប់នៅទីនេះ»។ ពេលនោះខ្ញុំយល់ថាខ្ញុំប្រាកដជាស្លាប់ដែរហើយ។ ខ្ញុំបានចុះចាញ់លើជោគវាសនារបស់ខ្លួន ខ្ញុំបិទភ្នែក ហើយបន្ទាប់មកខ្ញុំនឹកចាំអ្វីផ្សេងទៀតមិនបានទេរហូតដល់ខ្ញុំបើកភ្នែករបស់ខ្ញុំម្តងទៀត។ ខ្ញុំឃើញ លីវី កំពុងតែឈរក្បែរគ្រែរបស់ខ្ញុំ។ បន្ទាប់



មកខ្ញុំក៏បានដឹងថា ខ្ញុំត្រូវរៀនពីរបៀបដើរម្តងទៀត។ ខ្ញុំបានសន្លប់អស់រយៈពេលជាច្រើនសប្តាហ៍ ហើយ លីវី គឺជាអ្នកដែលចាំមើលថែរក្សាខ្ញុំឲ្យមានជីវិតសារជាថ្មីឡើងវិញ។

នៅក្នុងរដូវក្តៅឆ្នាំ១៩៤៥ យើងបានសម្រេចចិត្តធ្វើដំណើរមកប្រទេស ស៊ុយអែត យើងទាំង២នាក់ក៏រស់នៅទីនេះរហូតមក។ លីវី បានរៀបការនៅពេលដែលនាងមានអាយុវ័យក្មេងនៅឡើយ។ នាងមានអាយុត្រឹមតែ១៧ឆ្នាំ ពេលដែលនាងបានជួបលោក ហាន របស់នាងដែលមានអាយុ២៧ឆ្នាំទៅហើយ។ គាត់ក៏គ្រាន់តែជាកុមារម្នាក់នៅពេលដែលគាត់ត្រូវចាកចេញពីឪពុក



*នៅខាងឆ្វេងដៃ៖ គឺជាបន្ទប់ផ្សែងពុលសម្រាប់សម្លាប់អ្នកទោស។ បើប្រៀបធៀបទៅជំរំដទៃទៀត បន្ទប់ផ្សែងពុលនៅជំរំស្តុតថូហ្វ គឺមិនធំនោះទេ ពីព្រោះជំរំនេះមិនមែនចាត់ទុកថាជាជំរំសម្លាប់។ ខាងស្តាំដៃ៖ គឺជាកន្លែងដាក់ឡសម្រាប់ដុតសាកសព។ នៅខាងមុខ៖ គឺជាទូរថភ្លើងដែលណាស៊ី យកប្រើប្រាស់សម្រាប់សម្លាប់អ្នកទោសដោយផ្សែងពុល ដូចគ្នា។ មានសាច់រឿងមួយនៅក្នុងជំរំបានបញ្ជាក់ថា ណាស៊ី បានកុហកអ្នកទោសថាពួកគេនឹងផ្លាស់ប្តូរទៅកន្លែងថ្មី ប៉ុន្តែរថភ្លើងចាកចេញពីជំរំមិនយូរប៉ុន្មាន ផ្សែងពុលត្រូវបានបញ្ចេញដើម្បីសម្លាប់អ្នកទោស។ (សូវិចិត្រ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ម្តាយរបស់គាត់ ដែលនៅក្នុងប្រទេស អាល្លឺម៉ង់ ដើម្បីជួយសង្គ្រោះជីវិតខ្លួនឯង។ គាត់បានទៅប្រទេស ដាណឺម៉ាក ហើយពីទីនោះមក គាត់បានធ្វើដំណើរទៅប្រទេសស៊ុយអែត ជាមួយក្រុមសង្គ្រោះ ដាណឺម៉ាក។ ពួកគេទាំងពីរនាក់មានកូនដំបូងនៅពេលដែល លីវី មានអាយុ ១៩ឆ្នាំ ហើយបន្ទាប់មកមានកូនពីរនាក់ថែមទៀត។ ហាន បានស្លាប់នៅក្នុងឆ្នាំ ២០០០ ដោយសារតែជំងឺវង្វេងវង្វាន់។

សព្វថ្ងៃនេះ លីវី ហើយនិងខ្ញុំរស់នៅក្បែរគ្នា។ នៅពេលដែលយើងនៅវ័យក្មេង យើងឃើញមុខគ្នាជារៀងរាល់ថ្ងៃ។ បច្ចុប្បន្ននេះ យើងទាំងពីរនាក់មានភាពលំបាកក្នុងការដើរ ដូច្នេះហើយ ទើបយើងនិយាយគ្នាតាមទូរស័ព្ទជំនួសវិញ។ នៅរៀងរាល់ព្រឹកម៉ោង ៩ យើងតែងតែទូរស័ព្ទរកគ្នា និងនៅពេលខ្លះទៀត យើងក៏ព្យាយាមជួបមុខគ្នាជាញឹកញាប់តាមដែលអាចធ្វើបាន។ លីវី មានអាយុជិត ៩០ឆ្នាំហើយ ប៉ុន្តែនាងនៅតែទៅសាលារៀនផ្សេងៗ ដើម្បីនិយាយអំពីរឿងរ៉ាវជីវិតរបស់យើង។

**(តនៅលេខក្រោយ)**













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ភាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្តនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!












# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

*ហួ ផុនា និង ជាវ៉ាវដ្ឋ មេត្តា*

(តពីលេខមុន)



*នួន ជា នៅបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ (ហេង ស៊ីនិត/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

**២.៥.២.** *ការចោទប្រកាន់អំពីវិការៈនៅក្នុងកិច្ចស៊ើបសួរ*

**១១២.** *មេធាវីការពារក្តី នួន ជា លើកឡើងនូវអំណះអំណាងដែលបានលើកឡើងជាច្រើនដងរួចមកហើយថា សហចៅក្រមស៊ើបអង្កេតមានភាពលម្អៀង និងបានរំលោភសិទ្ធិមេធាវីការពារក្តីដោយបានដកពួកគេចេញពីកិច្ចស៊ើបសួរ។ មេធាវីការពារក្តីសន្និដ្ឋានបន្ថែមទៀតថាជាលទ្ធផលសំណុំរឿងមានភាពលម្អៀង។ អង្គជំនុំជម្រះរំឭកថា ខ្លួនធ្លាប់បានឆ្លើយតបរួចមកហើយពាក់ព័ន្ធនឹងការលើកឡើងអំពីភាពលម្អៀងផ្នែកនីតិវិធីនៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ។ អង្គជំនុំជម្រះបានកត់សម្គាល់ថាជនជាប់ចោទបានប្រើប្រាស់ការធានាផ្នែកនីតិវិធីយ៉ាងច្រើន ដែលមានចែងនៅក្នុងក្របខណ្ឌគតិយុត្តិរបស់*

អ.វ.ត.ក ដើម្បីឲ្យមានការដោះស្រាយការចោទប្រកាន់អំពីវិការៈនៅក្នុងកិច្ចស៊ើបសួរ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬនៅពេលប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចទាំងនេះត្រូវបានអង្គជំនុំជម្រះតុលាការកំពូលច្រានចោល ដោយបដិសេធមិនពិនិត្យទៅលើបញ្ហាទាំងនេះឡើងវិញនៅក្នុងបរិបទនៃសាលដីកាសំណុំរឿង ០០២/០១។ ជនជាប់ចោទមិនបានចោទប្រកាន់អង្គហេតុ ឬកាលៈទេសៈថ្មីដែលលេចឡើង ចាប់តាំងពីពេលដែលសេចក្តីសម្រេចទាំងនេះត្រូវបានចេញ ដែលបានផ្តល់យុត្តិកម្មដល់ការពិចារណាថ្មីៗទៅលើបញ្ហាទាំងនេះទេ។ ទោះបីជាយ៉ាងណា ក្នុងករណីមានការចោទប្រកាន់ពីវិការៈនៅក្នុងកិច្ចស៊ើបសួរជាក់លាក់ណាមួយនោះ ហើយមានភាពជាប់ពាក់ព័ន្ធច្បាស់ទៅនឹងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះនឹងពិចារណាទៅលើវិការៈទាំងនេះ នៅក្នុងការវាយតម្លៃចុងក្រោយលើភស្តុតាង។

**២.៥.៣.** *ភាពមិនលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូង*

**១១៣.** នៅក្នុងការព្យាយាមគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនអំពីអត្ថិភាពនៃទ្រឹស្តី «Manichean» មេធាវីការពារក្តី នួន ជា សន្និដ្ឋានថា យោងតាមហេតុផលមួយចំនួន ចៅក្រមអង្គជំនុំជម្រះសាលាដំបូងគ្មានអព្យាក្រឹត្រភាពទេ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា វិធាន៣៤ នៃវិធានផ្ទៃក្នុង ចែងអំពីនីតិវិធីជាក់លាក់ ក្នុងការដោះស្រាយការចោទប្រកាន់លើអព្យាក្រឹត្យភាពរបស់ចៅក្រម។ ចៅក្រមអាចដកខ្លួន នៅក្នុងករណីមានភាពលម្អៀង ឬមើលឃើញថាលម្អៀង។ ក្នុងចំណោមលក្ខខណ្ឌវិការផ្សេងៗនោះ គឺការតម្រូវឲ្យមានការដាក់សំណើសុំឲ្យបានលឿននៅពេលភាគីបានដឹងអំពីមូលដ្ឋាននៃភាពលម្អៀងទាំងនេះ។ សំណើរនេះត្រូវតែវិនិច្ឆ័យដោយក្រុមប្រឹក្សាពិសេសដោយមិនមានចៅក្រមដែលមិនត្រូវចោទប្រកាន់នោះទេ។ ហេតុដូច្នេះ បុព្វហេតុ បញ្ហានេះមិនអាចយកមកវិច្ឆ័យដោយអង្គជំនុំជម្រះមិនត្រូវឆ្លើយតបបន្ថែមទៀតទៅហ្នឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់លើអព្យាក្រឹត្យភាពនៃចៅក្រមអង្គជំនុំជម្រះសាលាដំបូងទេ។

**១១៤.** មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងពីបញ្ហាទាក់ទងនឹងសេចក្តីសម្រេចមួយចំនួន របស់អង្គជំនុំជម្រះសាលាដំបូងដែលមេធាវីយល់ឃើញថា បានបង្ហាញភស្តុតាងពីសច្ចធារណ៍នៃសុចរិតភាពរបស់សហព្រះរាជអាជ្ញា និងពុំមានសុចរិតភាពសម្រាប់មេធាវីការពារក្តី រួមទាំងការអនុញ្ញាតឲ្យការិយាល័យសហព្រះរាជអាជ្ញាបន្តបង្ហាញភស្តុតាងដាក់បន្ទុកពីសំណុំរឿង០០៣ និង០០៤ ការតម្រូវឲ្យមេធាវីការពារក្តីចូលរួមនៅក្នុងសាវនាការក្នុងសំណុំរឿង០០២/០១ ហើយនឹងការអន្តរាគមន៍នៅក្នុងសំណុំរឿង០០២/០២នៅពេលមេធាវីកំពុងមមាញឹកខ្លាំងក្នុងការរៀបចំបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមនៃសំណុំរឿង០០២/០១ ហើយនឹងការអន្តរាគមន៍នៅក្នុងពេលមេធាវីការពារក្តីដេញដោលសាក្សីដាក់បន្ទុក ប៉ុន្តែមិនបានធ្វើអន្តរាគមន៍នៅពេលសាក្សីទាំងនេះសម្តែងឥរិយាបថមិនសមរម្យចំពោះមេធាវីការពារក្តី។

**១១៥.** ជាបឋម អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សេចក្តីសន្និដ្ឋានបែបនេះជាច្រើនត្រូវបានច្រានចោលដោយក្រុមប្រឹក្សាពិសេសនៃអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងការសម្រេចលើបណ្តឹងជិតចិត្តចៅក្រហម។ ចំពោះបញ្ហាដែលនៅសេសសល់ ប្រសិនបើមេធាវីការពារក្តី ខៀវ សំផន យល់ឃើញថាបញ្ហាទាំងនោះមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់នោះ វាជាបន្ទុករបស់មេធាវីការពារក្តីក្នុងការដាក់សំណើសុំប្តឹងជិតចិត្តចៅក្រម ដោយផ្អែកលើមូលដ្ឋាននោះ។ នៅក្នុងដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធីនេះទៅហើយ មេធាវីការពារក្តីពុំមានភាពច្បាស់លាស់ថា តើខ្លួនត្រូវស្នើ

សុំដំណោះស្រាយអ្វីខ្លះ ឬដំណោះស្រាយអ្វីខ្លះដែលត្រូវផ្ដល់ជូនៗ ចំពោះខ្លឹមសារនៃការជំទាស់អង្គជំនុំជម្រះយោងទៅលើហេតុផល ដែលបានផ្ដល់ជូនទៅពេលអង្គជំនុំជម្រះបានចាត់វិធានការផ្អែកនីតិវិធីដែលត្រូវបានរិះគន់នាពេលមុននោះៗ ពាក់ព័ន្ធនឹងការចោទប្រកាន់ពីភាពលម្អៀងវិញ អង្គជំនុំជម្រះសូមយោងទៅលើមតិយោបល់របស់ខ្លួនដែលបានបង្ហាញខាងលើរួចហើយៗ

២.៥.៤ *សមភាពរវាងគូភាគី*

**១១៦.** *ជនជាប់ចោទសន្និដ្ឋានថា អង្គជំនុំជម្រះបានរំលោភទៅលើគោលការណ៍សមភាពរវាងគូភាគីដោយមានភាពលម្អៀងទៅខាងសហព្រះរាជអាជ្ញាជាងមេធាវីការពារក្ដី នៅក្នុងសេចក្ដីសម្រេចជ្រើសរើសសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញឲ្យមកផ្ដល់សក្ខីកម្មនៅពេលជំនុំជម្រះព្រមទាំងនៅក្នុងសេចក្ដីសម្រេចស្ដីពីការទទួលយកភស្តុតាងៗ*

**១១៧.** *អង្គជំនុំជម្រះរម្លឹកថា តុលាការសិទ្ធិមនុស្សអឺរ៉ុបនៅក្នុងរឿងក្ដី Bulut តទល់នឹងប្រទេសអូទ្រីសបានសម្រេចថា«យោងតាមគោលការណ៍សមភាពរវាងគូភាគីដែលជាផ្នែកមួយសំខាន់នៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ គឺភាគីត្រូវផ្ដល់ឱកាសសមស្របដើម្បីបង្ហាញរឿងក្ដីរបស់ខ្លួនក្រោមលក្ខខណ្ឌ ដែលពុំខូចប្រយោជន៍ដល់ខ្លួននឹងគូបដិបក្ខរបស់ខ្លួន»ៗ ក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក វិធាន ២១ នៃវិធានផ្ទៃក្នុង ឆ្លុះបញ្ចាំងអំពីស្មារតីនៃគោលការណ៍នេះ វិធាននេះ ចែងថា «ដំណើរការនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានភាពយុត្តិធម៌ និងត្រូវ គោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ»ៗ*

២.៥.៤.១. *ការចោទប្រកាន់ដោយផ្អែកលើសេចក្ដីសម្រេចអំពីសាក្សី*

**១១៨.** *មេធាវីការពារក្ដី នួន ជា សន្និដ្ឋានថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកោះហៅសាក្សីជាច្រើននាក់ ដែលខ្លួនបានស្នើសុំឲ្យមកផ្ដល់សក្ខីកម្មបានរំលោភលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ជាពិសេសគោលការណ៍សមភាពរវាងគូភាគី និងសិទ្ធិរបស់គាត់ក្នុងការការពារក្ដីប្រកបដោយប្រសិទ្ធភាពៗ មេធាវី ការពារក្ដី នួន ជា សន្និដ្ឋានថាសំណើសុំសារណាសង្ខេបរបស់អង្គជំនុំជម្រះ ស្ដីពីភាពពាក់ព័ន្ធនៃសាក្សីបន្ថែមដែលខ្លួនបានស្នើឡើង បានរំលោភលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានសាក្សីដោះបន្ទុក ក្រោមលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក ព្រោះអង្គជំនុំជម្រះបានដាក់លក្ខខណ្ឌក្នុងការស្ដាប់សាក្សីរបស់ខ្លួនៗ មេធាវីការពារក្ដីសន្និដ្ឋានថាសំណើរសុំសារណាសង្ខេបនេះមាន «ភាពអយុត្តិធម៌ដែលមិនអាចទទួលយកបាន» ដោយសារវា «ជាប្រយោជន៍បន្ថែមដល់សហព្រះរាជអាជ្ញា»ៗ មេធាវីការពារក្ដីស្នើសុំឲ្យពិចារណាសាជាថ្មី បន្ថែមទៀតលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលច្រានចោលសាក្សី និងអ្នកជំនាញចំនួន ២៣នាក់ ដែលពួកគេបានស្នើឡើង ដូចមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ២ នៃសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីការពារក្ដី នួន ជាៗ*

**១១៩.** *អង្គជំនុំជម្រះរម្លឹកថា កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធពលរដ្ឋនិងសិទ្ធិនយោបាយ និងច្បាប់ អ.វ.ត.ក ធានាថា ជនជាប់ចោទគ្រប់រូបមានសិទ្ធិ «សួរចម្លើយ ឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំលឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក»ៗ យ៉ាងណាមិញដូចដែល អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់រួចហើយថា ជនជាប់ចោទពុំមានសិទ្ធិដាច់ខាតក្នុងការហៅសាក្សីដែលខ្លួនពេញចិត្តនោះទេៗ អង្គជំនុំជម្រះសាលាដំបូងនៅតែមានឆន្ទានុសិទ្ធិក្នុងការសម្រេចថា តើសាក្សីរបស់មេធាវីការពារក្ដីណាខ្លះដែលសមស្របគួរ*



ខៀវ សំផន នៅបន្ទប់សវនាការ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កោះហៅ។ ចំណុចសំខាន់នោះ គឺថាអង្គជំនុំជម្រះសាលាដំបូងរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគី ដើម្បីធានាឲ្យមានការគោរពគោលការណ៍សមភាពរវាងគូភាគី។

**១២០.** សេចក្តីសន្និដ្ឋានថាអង្គជំនុំជម្រះបានរំលោភសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានសាក្សីដោះបន្ទុកក្រោមលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក កើតចេញពីសំណើសុំចំនួនប្រាំដែលមេធាវីការពារក្តី នួន ជា បានដាក់បន្ទុកនៅក្នុងខែមីនា ឆ្នាំ២៩១៦ ដើម្បីស្តាប់សាក្សីបន្ថែមសរុបចំនួន ៤៥នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បន្ថែម។ សាក្សីជាច្រើនពុំត្រូវបានស្នើសុំកាលពីពេលមុនដោយជនជាប់ចោទនោះទេ ហេតុដូច្នេះត្រូវបានស្នើសុំជាថ្មី អនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ ពាក់ព័ន្ធនឹងសាក្សីផ្សេងទៀត ដែលបានស្នើសុំដោយមេធាវីការពារក្តីនៅពេលចាប់ផ្តើមការជំនុំជម្រះ មេធាវីការពារក្តីបានស្នើសុំពន្លឿនសេចក្តីសម្រេចកោះហៅ ពួកគេ ឬសំណើសុំឲ្យពិចារណាសាជាថ្មីលើសេចក្តីសម្រេចមិនកោះហៅពួកគេ។ សំណើសុំនីមួយៗបានផ្អែកលើការអះអាងថាសក្ខីកម្មរបស់បុគ្គលដែលបានស្នើសុំ គឺ«ពាក់ព័ន្ធទីនឹងចំណុចស្នូលនៃសំណុំរឿងរបស់ នួន ជា ដែរ និងជាពិសេស ការអះអាងដែលថា ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យត្រូវបានបែកខ្ញែកជាបក្ខពួក ទំនាស់ដែលមួយចំនួនគាំទ្រជាសម្ងាត់ដោយវៀតណាម»។ នៅពេលមុនសម្រេចថា តើត្រូវស្តាប់បុគ្គលដែលបានស្នើសុំទាំង ៤៦ នាក់នោះហើយ ដោយពិចារណាលើកិច្ចដំណើរការនីតិវិធីដំណាក់កាលចុងក្រោយហើយនោះ នៅពេលសំណើសុំទាំងនេះបានធ្វើឡើង អង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យមេធាវីការពារក្តី នួន ជា ពន្យល់បន្ថែមថា តើអត្ថិភាពនៃបក្ខពួកទំនាស់អាចផ្តល់ការការពារក្តីចំពោះការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយដោយរបៀបណា ឬអាចត្រូវបានចាត់ទុកថាជាស្ថានសម្រាលទោសរបៀបណា។ មេធាវីការពារក្តីបានដាក់ចម្លើយតបពន្យល់ពីជំហររបស់គាត់«ដោយមានការតវ៉ា»។

**១២១.** នៅពេលសេចក្តីសម្រេចលើករណីថា តើគួរកោះហៅសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះ អង្គជំនុំជម្រះបានផ្អែកលើគោលការណ៍ណែនាំស្តីពីការពិចារណាជាមូលដ្ឋានលើភាពពាក់ព័ន្ធ។ វិធាន ៨៧ នៃវិធានផ្ទៃក្នុងតម្រូវថាភាគីធ្វើសំណើសុំដាក់សេចក្តីសន្និដ្ឋានដែលមានសម្អាងហេតុ ដើម្បីស្តាប់សាក្សីថ្មីៗ កាលណាសំណើ

ពុំមានសម្អាងហេតុគ្រប់គ្រាន់ អង្គជំនុំជម្រះអាចត្រូវសម្រេចថា ត្រូវច្រានចោលសំណើសុំ ឬតម្រូវឲ្យធ្វើការបញ្ជាក់។ យោងតាមហេតុផលនេះហើយ ទើបនៅក្នុងករណីនេះ អង្គជំនុំជម្រះបានស្នើព័ត៌មានបន្ថែមពីមេធាវីការពារក្តី នួន ជា ដោយផ្អែកលើមូលដ្ឋានថា ធាចជាការជួយដល់ការធ្វើសេចក្តីសម្រេចចាំបាច់ស្តីពីភាពពាក់ព័ន្ធនៃសាក្សីដែលបានស្នើសុំមួយចំនួន។ ការសាកសួរបែបនេះមានភាពសមស្របទាំងស្រុងទៅនឹងមុខងាររបស់អង្គជំនុំជម្រះក្នុងការជ្រើសរើសសាក្សី។

**១២២.** លើសពីនេះទៀត អង្គជំនុំជម្រះមានភារកិច្ចធានាថា «ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែមានភាពយុត្តិធម៌ និងត្រូវគោរពតាមការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ»។ ដើម្បីធានាថា ការសួរដេញដោលធ្វើឡើងចំពោះមុខ រួមទាំងបញ្ហាថា តើសាក្សីឡើងត្រូវកោះហៅ ឬមិនកោះហៅនោះ អង្គជំនុំជម្រះ និងភាគីចាំបាច់ ត្រូវមានការយល់ដឹងឲ្យបានច្បាស់ពីមូលហេតុនៅក្នុងសំណើសុំពិនិត្យភ័ស្តុតាង។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះមានសិទ្ធិណែនាំឲ្យភាគីផ្តល់ការបញ្ជាក់ឲ្យបានទាន់ពេលវេលាដែលអាចឲ្យមានការពិភាក្សាចំពោះមុខបាន។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សំណើសុំដាក់សារណាមានភាពសមស្រប និងពិតជាជួយដល់ការវាយតម្លៃពីលក្ខណៈនៃសំណើរបស់មេធាវីការពារក្តីសុំស្តាប់សាក្សីបន្ថែម។

**១២៣.** មេធាវីការពារក្តី នួន ជា មានការភ័ន្តច្រឡំក្នុងការបញ្ជាក់ថា សិទ្ធិក្នុងការធ្វើការពារក្តីប្រកបដោយប្រសិទ្ធភាព គឺដូចគ្នានឹងសិទ្ធិដែលគ្មានលក្ខខណ្ឌក្នុងការកោះហៅសាក្សីទាំងអស់ ដែលខ្លួនបានស្នើសុំ។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសូមរម្លឹកពីយុត្តិសាស្ត្រដែលបានកត់សម្គាល់ខាងលើ ហើយច្រានចោលសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា។

**១២៤.** ជាចុងក្រោយ នួន ជា ផ្តោតជាពិសេសលើការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកោះហៅលោក ហេង សំរិន,អ៊ុក ប៊ុនឈឿន, ជា ស៊ីម និង ប៉ុល សារឿន ដែលជាសាក្សីនៅក្នុងរឿងនេះ។ នួន ជា បានធ្វើសំណើសុំជាច្រើនដង សុំស្តាប់សាក្សីទាំងនេះ ហើយសម្អាងថា លោក ហេង សំរិន ជាពិសេស គឺជាសាក្សីសំខាន់បំផុតនៅក្នុងសំណុំរឿង០០២។ អង្គជំនុំជម្រះរម្លឹកថា អង្គជំនុំជម្រះបានចាត់វិធានការដើម្បីបញ្ជាក់ពីឆន្ទៈរបស់លោក ហេង សំរិន, អ៊ុក ប៊ុនឈឿន និង ប៉ុល សារឿន ក្នុងការមកផ្តល់សក្ខីកម្ម(លោក ជា ស៊ីម បានទទួលមរណភាពនៅក្នុងអំឡុងពេលដែលអង្គជំនុំជម្រះចេញសេចក្តីសម្រេច)។ អង្គជំនុំជម្រះកត់សម្គាល់ទៀតថា កិច្ចសម្ភាសន៍យ៉ាងយូរជាមួយលោក ហេង សំរិន, ជា ស៊ីម និង អ៊ុក ប៊ុនឈឿន មាននៅក្នុងសំណុំរឿង។ ដោយសារអង្គជំនុំជម្រះមិនអាចរកសំឡេងគាំទ្រភាគច្រើនលើសលុបក្នុងការកោះហៅលោក ហេង សំរិន, អ៊ុក ប៊ុនឈឿន និង ប៉ុល សារឿន នោះអង្គជំនុំជម្រះពុំបានចេញដីកាកោះហើយសាក្សីទាំងនេះពុំត្រូវបានស្តាប់ចម្លើយនៅក្នុងសវនាការនោះទេ។ អង្គជំនុំជម្រះនឹងពិចារណាបន្ថែមទៀតអំពីផលប៉ះពាល់(ប្រសិនបើមាន) នៃនត្ថិភាពនៃសក្ខីកម្មរបស់សាក្សី ៣នាក់នេះ នៅពេលវាយតម្លៃភ័ស្តុតាងទាំងអស់។

**១២៥.** ចំពោះសំណើរបស់មេធាវី ការពារក្តីសុំឲ្យពិចារណាឡើងវិញ លើសេចក្តីសម្រេចរបស់ខ្លួនក្នុងការច្រានចោលសាក្សី និងអ្នកជំនាញចំនួន ២៣នាក់ ដែលមេធាវីការពារក្តីស្នើសុំនោះ អង្គជំនុំជម្រះរម្លឹកថា ការពិចារណាឡើងវិញមិនមែនជាផ្នែកនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក នោះទេ។ អង្គជំនុំជម្រះនឹងពិចារណាលើសំណើសុំជាថ្មីតែក្នុងករណីដែល «សំណើជាថ្មីនោះមានភ័ស្តុតាងថ្មី ឬកាលៈទេសៈថ្មី»តែប៉ុណ្ណោះ។ មេធាវីការពារក្តី នួន ជា ពុំបានបង្ហាញអង្គហេតុឬ កាលៈទេសៈថ្មី ដែល

អាចជាយុត្តិកម្មក្នុងការចេញសេចក្តីសម្រេចមួយខុសពីមុនពាក់ព័ន្ធនឹងបុគ្គលទាំង ២៣ នាក់នេះនោះទេ ដោយមេធាវីការពារក្តីគ្រាន់តែដាក់ឈ្មោះរបស់បុគ្គលទាំងនេះក្នុងឧបសម្ព័ន្ធ និងយោងទៅលើសេចក្តីសម្រេចពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ។ ហេតុដូច្នេះ សំណើសុំរបស់មេធាវីការពារក្តី នួន ជា ត្រូវបដិសេធចោល។

**១២៦.** *មេធាវីការពាក្តី ខៀវ សំផន សន្និដ្ឋានថា ករណីដែលថាមានតែបុគ្គល ២នាក់ ដែលខ្លួនបានស្នើសុំត្រូវបានស្តាប់ចម្លើយ ក្នុងចំណោមសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំង ១៨៦នាក់ ដែលបានស្តាប់ចម្លើយនៅក្នុងសំណុំរឿង០០២/០២ បង្ហាញថាអង្គជំនុំជម្រះលម្អៀងទៅខាងសហព្រះរាជអាជ្ញា។*

**១២៧.** *អង្គជំនុំជម្រះរម្លឹកថា ចំនួនសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានជ្រើសរើសដោយអង្គជំនុំជម្រះពីក្នុងចំណោមអ្នកដែលស្នើឡើងដោយភាគីអាស្រ័យលើភាពពាក់ព័ន្ធនៃបុគ្គលទាំងនោះ។ អង្គជំនុំជម្រះរម្លឹកបន្ថែមទៀតអំពីសម្អាងហេតុរបស់ខ្លួនដែលបានលើកឡើងនៅក្នុងកថាខណ្ឌ១១៩ ខាងលើ។ អង្គជំនុំជម្រះពិចារណាឃើញថា នៅក្នុងករណីនេះមេធាវីការពារក្តីពុំបានបង្ហាញភ័ស្តុតាងអំពីការរំលោភគោលការណ៍សមភាពរវាងគូភាគីនោះឡើយ។ អង្គជំនុំជម្រះបានអនុវត្តបទដ្ឋានដូចគ្នា ដោយផ្អែកលើភាពពាក់ព័ន្ធនឹងសំណើសុំទាំងអស់ ដោយមិនគិតថាភាគីណាជាអ្នកដាក់សំណើសុំនោះឡើយ។*

**២.៥.៤.២** *ការចោទប្រកាន់ដោយផ្អែកលើសេចក្តីសម្រេចអំពីការទទួលយកភ័ស្តុតាង និងសេចក្តីសម្រេចអំពីការពិចារណាឡើងវិញ*

**១២៨.** *មេធាវីការពារក្តី នួន ជា បានលើកឡើងថា អង្គជំនុំជម្រះបានរំលោភសិទ្ធិរបស់ នួន ជា ក្នុងការបង្ហាញភ័ស្តុតាងដោះបន្ទុក តាមរយៈការសម្រេចមិនទទួលយកប្រតិចារឹកនៃការសម្ភាសន៍ ចំនួនបួនដែលធ្វើឡើងដោយ ថេត សម្បត្តិ និង Robert LEMKIN របាយការណ៍អង្គការ Human Right Watch និង «ភ័ស្តុតាងមួយចំនួន» ដែលមាននៅក្នុងឧបសម្ព័ន្ធ១ នៃសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ មេធាវីការពារក្តី នួន ជា យល់ថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបង្ហាញពីភ័ស្តុតាងនៃ «បទដ្ឋានពីរ» របស់អង្គជំនុំជម្រះសាលាដំបូង ដោយសារតែអង្គជំនុំជម្រះទទួលយកភ័ស្តុតាងដែលអ្នកជំនាញ Alexander HINTON និង Henri LOCARD ផ្តល់ឲ្យរួមទាំងការសម្ភាសន៍ដែល «ប្រភពមិនមានឈ្មោះឬ មិនមានទីកន្លែង»។ មេធាវីការពារក្តី នួន ជា ស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញលើសេចក្តីសម្រេចទាំងនោះ។ ជាជម្រើសមួយទៀតមេធាវីការពារក្តី នួន ជា ស្នើសុំឲ្យបើកសវនាការពិនិត្យភ័ស្តុតាង និងធ្វើការពិចារណាឡើងវិញ ចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានបដិសេធសំណើរបស់មេធាវីការពារក្តី នួន ជា សុំស្តាប់សាក្សីបន្ថែមនិងសុំបំពេញការស៊ើបសួរបន្ថែម ដូចបានរៀបរាប់នៅក្នុងឧបគ្គសមម្ព័ន្ធ ១ និង ឧបគ្គសម្ព័ន្ធ។*

**១២៩.** *ចំពោះប្រតិចារឹកនៃការសម្ភាសន៍ទាំងបួន (ឧបសម្ព័ន្ធ១) អង្គជំនុំជម្រះបានកត់សម្គាល់ថា ខ្លួនបានទទួលយកផ្នែកខ្លះនៃប្រតិចារឹកមួយក្នុងចំណោមប្រចារឹកទាំងបួន ព្រោះអង្គជំនុំជម្រះ តុលាការកំពូលបានរកឃើញថាការសម្ភាសន៍នោះគឺជាការសម្ភាសន៍របស់ ទាត់ ធឿន ដែលបានមកផ្តល់សក្ខីកម្មនៅក្នុងសវនាការលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១។ ពាក់ព័ន្ធនឹងប្រតិចារឹកចំនួនបីផ្សេងទៀតនោះ អង្គជំនុំជម្រះបានរកឃើញថាក្នុងចំណោមបញ្ហានានា អត្តសញ្ញាណនៃអ្នកផ្តល់ការសម្ភាសន៍មិនមានភាពច្បាស់លាស់ ហើយលោក LEMKIN មិនសហការជាមួយនឹងអង្គជំនុំជម្រះនៅក្នុងការកំណត់អត្តសញ្ញាណពួកគេ។ បើទោះបីជាមិនមាន*

ព័ត៌មានគ្រប់គ្រាន់ដើម្បីកំណត់អត្តសញ្ញាណសាក្សីទាំងនេះ ប៉ុន្តែអង្គជំនុំជម្រះបានណែនាំឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញព្យាយាមកំណោត់អត្តសញ្ញាណ និងស្វែងរកបុគ្គលពីរនាក់ នៅក្នុងចំណោមបីនាក់នោះៗ យ៉ាងណាមិញ ការខិតខំប្រឹងប្រែងនេះបានបរាជ័យៗ បន្ថែមពីនេះទៀត ដោយសារតែការសម្ភាសន៍ធ្វើឡើងជាភាសាខ្មែរ ចំណែកឯប្រតិចារឹកធ្វើឡើងជាភាសាអង់គ្លេស អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មិនមានព័ត៌មានអំពី «ភាពត្រឹមត្រូវ ឬភាពពេញលេញនៃការបកប្រែ ឬសម្ភារដែលបានប្រើប្រាស់ក្នុងការបង្កើតប្រតិចារឹកជាភាសាអង់គ្លេសនោះទេ» ឬ «ពុំមានព័ត៌មានអំពីរយៈពេលនៃកិច្ចសម្ភាសន៍នីមួយៗ និងរបៀបជ្រើសរើស និង/ឬការកែសម្រួលចំណុចដកស្រង់ចេញពីការសម្ភាសន៍ ដែលបង្កើតជាប្រតិចារឹកផងដែរៗ ដោយមិនដឹងពីអត្តសញ្ញាណរបស់អ្នកផ្តល់ការសម្ភាសន៍ និងមិនមានមធ្យោបាយវាយតម្លៃទៅលើភាពពេញលេញ ឬភាពត្រឹមត្រូវនៃការបកប្រែជាភាសាអង់គ្លេសនោះ អង្គជំនុំជម្រះយល់ឃើញថា ប្រតិចារឹកចំនួនបីផ្សេងទៀតនោះ មិនបានបំពេញនូវលក្ខខណ្ឌតម្រូវនៃការបញ្ជាក់បឋម នៃភាពអាចជឿជាក់បាននៅក្នុងការទទួលយកធ្វើជាភ័ស្តុតាងអនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុងៗ ទោះបីជានាពេលនេះមេធាវីការពារក្តី នួនជា បានលើកឡើងថា ខ្លួនមានខ្សែអាត់សំឡេងនៃការសម្ភាសន៍ទាំងនោះ និងបានបញ្ជាក់ថាខ្លឹមសារនៃការសម្ភាសន៍ទាំងនោះត្រឹមត្រូវដូចនៅក្នុងប្រតិចារឹកក៏ដោយ ប៉ុន្តែអត្តសញ្ញាណរបស់បុគ្គលទាំងបីនាក់នោះនៅតែមិនមានភាពច្បាស់លាស់ ហើយអង្គជំនុំជម្រះនៅតែមិនមានមធ្យោបាយក្នុងការវាយតម្លៃពីភាពពេញលេញ និងភាពត្រឹមត្រូវនៃការបកប្រែជាភាសាអង់គ្លេសនោះទេៗ លើសពីនេះទៀត គួរបញ្ជាក់ថា មេធាវីការពារក្តីមិនគោរពទៅតាមគោលការណ៍នៃនីតិវិធីសួរដេញដោលនៅចំពោះមុខ ដោយមិនផ្តល់ជូនអង្គជំនុំជម្រះ និងភាគីដទៃទៀតនូវលទ្ធភាពនៅក្នុងការពិនិត្យមើលខ្សែអាត់សំឡេងទាំងនោះ ឬស្នើសុំឲ្យទទួលយកខ្សែអាត់សំឡេងទាំងនោះធ្វើជាសម្ភារភ័ស្តុតាងៗ ដោយហេតុថា អង្គជំនុំជម្រះធ្វើការសម្រេចផ្អែកលើសម្ភារដែលត្រូវបានសួរដេញដោល និងក្រោយមកត្រូវបានទទួលយកធ្វើជាភ័ស្តុតាង អង្គជំនុំជម្រះយល់ឃើញថា ខ្សែអាត់សំឡេងដែលបានលើកឡើងទាំងនោះ មិនមាននូវកាលៈទេសៈថ្មី ឬអង្គហេតុថ្មីដែលអាចផ្តល់ជាយុត្តកម្មនៅក្នុងការពិចារណាសាជាថ្មីលើបញ្ហានេះនោះទេៗ ជាមួយគ្នានេះផងដែរ អង្គជំនុំជម្រះជឿជាក់ថា ការកោះហៅលោក LEMKIN ឲ្យមកផ្តល់សក្ខីកម្មមិនអាចបញ្ជាក់ពីអត្តសញ្ញាណរបស់បុគ្គលទាំងបីនេះ ដូចដែលមេធាវីការពារក្តី នួន ជា បានលើកឡើងនោះឡើយ ដោយសារតែលោក LEMKIM បានបដិសេធផ្តល់ព័ត៌មាននេះជូនដល់អង្គជំនុំជម្រះជាច្រើនដងរួចមកហើយៗ ហេតុដូច្នេះ សំណើសុំរបស់មេធាវីការពារក្តី នួន ជា ត្រូវបដិសេធចោលៗ

**១៣០.** មេធាវីការពារក្តី នួន ជា បានស្នើសុំឲ្យពិចារណាឡើងវិញជាលើកទីពីរទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ក្នុងការមិនទទួលយករបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សដែលមានចំណងជើងថា «រយៈពេល ៣០ឆ្នាំ នៃការកាន់ដំណែងរបស់ ហ៊ុន សែន» ដោយសារតែមិនមានភាពអាចជឿជាក់បានៗ ទោះបីជាមេធាវីការពារក្តីសំអាងទៅលើឯកសារដែលរកបានជាសាធារណៈនៅក្នុងសារណា និងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្តីរបស់ខ្លួន តែមិនមានកាលៈទេសៈ ឬអង្គហេតុថ្មីដែលត្រូវបានរកឃើញ ដែលតម្រូវឲ្យអង្គជំនុំជម្រះពិចារណាលើសំណើនេះសាជាថ្មីឡើយៗ ដោយសារអង្គជំនុំជម្រះអាចពិចារណាតែទៅលើភ័ស្តុតាងដែលត្រូវបានទទួលយកធ្វើជាភ័ស្តុតាង ហេតុនេះហើយរាល់គ្រប់ការយោងទៅលើរបាយការណ៍នេះនៅ

***(តនៅលេខក្រោយ)***

# ១៧ មេសា គឺជាថ្ងៃនៃការចាប់ផ្តើម

## សោកនាដកម្មរបស់ប្រជាជនកម្ពុជាក្នុងរបបខ្មែរក្រហម

សោម ប៊ុនថន



ប្រជាជនជម្លៀសចេញពីផ្ទះសម្បែង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺថ្ងៃដែលយោធាខ្មែរក្រហមឡើងកាន់អំណាច បន្ទាប់ពីរបបសាធារណរដ្ឋខ្មែរបានដួលរលំ ហើយក៏ជាថ្ងៃបញ្ចប់សង្រ្គាមស៊ីវិលដែលបានអូសបន្លាយរយៈពេល ៥ឆ្នាំ នៅក្នុងប្រទេសកម្ពុជា។ ប្រជាជននៅទូទាំងប្រទេសបានចូលរួមអបអរជ័យជម្នះនេះ និងបានស្វាគមន៍វត្តមានរបស់យោធាខ្មែរក្រហមស្របពេលពិធីអបអរបុណ្យចូលឆ្នាំប្រពៃណីខ្មែរមិនទាន់បញ្ចប់នៅឡើយ។ ប្រជាជនសង្ឃឹមថា សន្តិភាព និងភាពរីករាយនឹងកើតមាននៅក្នុងប្រទេសកម្ពុជា។

ប៉ុន្តែប៉ុន្មានម៉ោងក្រោយមក ការសង្ឃឹមរបស់ប្រជាជនកម្ពុជាក៏បានរសាយបាត់ទៅវិញ ហើយភាពភ័យរន្ធត់ តក់ស្លុត ក៏បានកើតឡើងនៅទូទាំងប្រទេសកម្ពុជា



យោធាខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ប្រជាជនជម្លៀសចេញពីផ្ទះសម្បែង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយយោធាខ្មែរក្រហមបានបង្ខំប្រជាជនឲ្យចាកចេញពីផ្ទះសម្បែង ក្រោមកម្ដៅថ្ងៃក្ដៅហួតហែង។ កម្ពុជាគឺជាប្រទេសដែលទទួលរងអាកាសធាតុត្រូពិក និងបានបែងចែកយ៉ាងច្បាស់លាស់រវាងរដូវប្រាំងដែលស្ថិតនៅចន្លោះពីខែធ្នូ ដល់ខែឧសភា និងរដូវវស្សាដែលស្ថិតនៅចន្លោះពីខែមិថុនា ដល់ខែវិច្ឆិកា។ ខែមេសា ស្ថិតនៅក្នុងរដូវប្រាំងដែលខ្វះខាតទឹកស្អាតសម្រាប់ផឹក និងប្រើប្រាស់ ហើយអាកាសធាតុក្ដៅក្នុងខែនេះ បានបណ្ដាលឲ្យកើតមានជំងឺឆ្លង និងជំងឺអាសន្នរោគផ្សេងៗ។

គោលនយោបាយជម្លៀសរបស់មេដឹកនាំខ្មែរក្នុងខែមេសានេះ បានបណ្ដាលឲ្យប្រជាជនកម្ពុជាដែលត្រូវធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយ និងគ្មានគោលដៅច្បាស់លាស់បានស្លាប់ជាបន្តបន្ទាប់។ ការព្រាត់ប្រាស គ្រោះទុរ្ភិក្ស ភាពអត់ឃ្លាន និងការសម្លាប់បានកើតឡើងដែរ។

សោកនាដកម្មនៅក្នុងខែមេសានេះ បានបន្សល់នូវការចងចាំ ភាពឈឺចាប់ និងជំងឺផ្លូវចិត្តដល់ជនរងគ្រោះរហូតមកដល់សព្វថ្ងៃ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ ១៩៧៩ ដំណើរការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ត្រូវបានផ្ដួចផ្ដើមឡើងតាមរយៈការបង្កើតតុលាការប្រជាជនបដិវត្តន៍ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម រួមទាំង ការធ្វើញត្តិប្ដឹងមេដឹកនាំខ្មែរក្រហម និងរបបកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើប្រជាជនកម្ពុជាទៅអង្គការសហប្រជាជាតិទៀតផង។

ទោះបីយ៉ាងណាតុលាការប្រជាជនបដិវត្តន៍កម្ពុជា មិនត្រូវទទួលស្គាល់ជាអន្តរជាតិឡើយ។ តុលាការនេះបានត្រឹមតែចេញសាលក្រម ប៉ុន្តែមិនអាចនាំយកជនជាប់ពិរុទ្ធមកទទួលទោសឡើយ។ ចំណែកញត្តិដែលបានបញ្ជូនទៅអង្គការសហប្រជាជាតិក៏មិនត្រូវបានអើពើដែរ ព្រោះរបបកម្ពុជាប្រជាធិបតេយ្យនៅមានអាសនៈនៅអង្គការសហប្រជាជាតិនៅឡើយ ថែមមានការគាំទ្រពីប្រទេសមហាអំណាច និងប្រទេសអាស៊ានមួយចំនួនទៀតផង។

ដំណើរការស្វែងរកយុត្តិធម៌ជូនរងគ្រោះត្រូវបានអូសបន្លាយអស់រយៈពេលជាង បីទសវត្សរ៍ រហូតដល់មានកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ឬសាលាក្តីខ្មែរក្រហម) ដែល ចាប់ផ្តើមដំណើរតាំងពីឆ្នាំ២០០៦មក។ រហូតមកដល់សព្វថ្ងៃ មានមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតខ្មែរក្រហមពីររូបដែលស្ថិតនៅក្នុងសំណុំរឿង០០១ និង០០២ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ខណៈពេលដែលសំណុំរឿង ០០៣ និង០០៤ មិនទាន់បិទបញ្ចប់នៅឡើយ។ ទោះបីមានការកាត់ទោសមេដឹកនាំខ្មែរក្រហម និងមានដំណើរការយុត្តិធម៌ជូនជនរងគ្រោះ ក៏នៅមិនទាន់គ្រប់គ្រាន់តាមការចង់បានរបស់ប្រជាជនកម្ពុជានៅឡើយ។

មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាស្ថាប័នឯករាជ្យដែលធ្វើការស្រាវជ្រាវ និងចងក្រងប្រវត្តិសាស្ត្រពីរបបខ្មែរក្រហមបានរួមចំណែកក្នុងដំណើរការស្វែងរកយុត្តិធម៌ និងការចងចាំ ដោយដាក់បញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ការចារឹកពាក្យស្លោកដែលនិយាយពីរបបខ្មែរក្រហម ដែលនិយាយពីការផ្សះផ្សា ការអត់ឱនអធ្យាស្រ័យគ្នានៅតាមសាលារៀន ការរៀបចំវេទិការអប់រំសាធារណៈអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់សិស្សានុសិស្ស វគ្គបណ្តុះបណ្តាលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់លោកគ្រូ អ្នកគ្រូ ផ្នែកប្រវត្តិសាស្ត្រ តាមវិទ្យាល័យ និងមហាវិទ្យាល័យនៅក្នុងប្រទេសកម្ពុជា ហើយនៅពេលថ្មីៗនេះ ក៏មានការលើកទឹកចិត្តឲ្យសាធារណជន ជាពិសេស គ្រូបង្រៀន សិស្ស និស្សិតស្រាវជ្រាវ និងសរសេររឿងរ៉ាវចេញពីតំបន់ដែលខ្លួនរស់នៅក្នុងរបបខ្មែរក្រហម រឺហៅថា ប្រវត្តិសាស្ត្រភូមិ។



អដ្ឋិធាតុរបស់ជនរងគ្រោះក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

«ផ្ទះផង់ធូលី»

## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# កុក សារឿន ៖ អនុសេនីយ៍ឯក

ខ្ញុំចូលចិត្តស្លៀកពាក់ឯកសណ្ឋាន។ ខ្ញុំស្លៀកពាក់ឯកសណ្ឋាននៅក្នុងរូបនេះបានតែម្តងគត់ នៅពេលដែលខ្ញុំត្រូវបានតម្លើងឋានន្តរស័ក្តិ។ នៅពេលដែលខ្ញុំទៅធ្វើការ ខ្ញុំស្លៀកពាក់ស៊ីវិល។

ខ្ញុំមិនចង់ធ្វើជាទាហានទេ។ បន្ទាប់ពីបញ្ចប់វិទ្យាល័យនៅខេត្តតាកែវមក ខ្ញុំបានបន្តរៀនសូត្រនៅទីក្រុងភ្នំពេញ។ ខ្ញុំចង់ធ្វើជាគ្រូបង្រៀន ប៉ុន្តែបានប្រឡងចូលធ្លាក់ ដូច្នេះខ្ញុំបានដាក់ពាក្យសុំធ្វើជាប៉ូលីស។

បន្ទាប់មក ខ្ញុំត្រូវបានបញ្ជូនទៅខេត្តកំពង់ចាមជិតពីរឆ្នាំរៀនច្បាប់ស៊ីវិល ច្បាប់ចរាចរ ច្បាប់ ទម្លាប់របស់ប្រទេសកម្ពុជា និងក្បួនយុទ្ធសាស្រ្តកងទ័ព ។ បន្ទាប់ពីបញ្ចប់ការសិក្សាមក ខ្ញុំត្រូវបានផ្ទេរទៅខេត្តកំពតមួយឆ្នាំ និងបន្ទាប់មកទៅខេត្តកោះកុង។

ខ្ញុំបានត្រឡប់មកស្រុកកំណើតរបស់ខ្ញុំរកមើលនារីម្នាក់ដើម្បីរៀបការ។ បន្ទាប់ពីដើរមើលតាមផ្ទះនៅក្នុងភូមិមក ខ្ញុំមិនបានចាប់ចិត្តនារីណាម្នាក់ទេ ទោះបីជាសមាជិកនៅក្នុងគ្រួសាររបស់នារីនោះសុំឲ្យខ្ញុំរៀបការជាមួយកូនស្រីរបស់គាត់ក៏ដោយ។ មានបុរសម្នាក់បានផ្តល់ប្រាក់ទិញម៉ូតូមួយគ្រឿងឲ្យខ្ញុំ ប្រសិនបើខ្ញុំរៀបការជាមួយកូនស្រីរបស់គាត់។

បន្ទាប់មក ខ្ញុំបានទៅផ្ទះរបស់លោកគ្រូបង្រៀនម្នាក់ឈ្មោះ កាន់ ហើយបាន



កុក សារឿន អាយុ២៨ឆ្នាំ
នៅក្នុងអំឡុងឆ្នាំ១៩៦០។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឃើញកូនស្រីរបស់គាត់កំពុងត្បាញក្រណាត់សូត្រ។ កាន់ បាននាំខ្ញុំទៅមើលនារីជាច្រើននាក់ ហើយត្រឡប់មកវិញហូបបាយល្ងាចនៅផ្ទះគាត់។ បន្ទាប់ពីអាហារពេលល្ងាច កាន់ បាននាំខ្ញុំទៅមើលនារីផ្សេងទៀត។ ទោះជាយ៉ាងណា ខ្ញុំបានប្រាប់គាត់ថា ផ្ទះរបស់គាត់ជាទីដែលខ្ញុំចូលចិត្តស្នាក់នៅ។

ហោរាបានទាយថា ប្រសិនបើខ្ញុំបានរៀបការជាមួយកូនស្រីរបស់ កាន់ ខ្ញុំអាចនឹងមានជីវភាពធូរធារ វណ្ណៈភាពមធ្យម និងមិនមានការលែងលះទេ។ គ្រូទាយបានប្រាប់ខ្ញុំទៀតថា ខ្ញុំប្រហែលជានឹងរៀបការជាលើកទីពីរ។ អីចឹង ខ្ញុំបានសុំឪពុកម្តាយរបស់ខ្ញុំ ឲ្យគាត់ទៅមើលអនាគតកិរិយារបស់ខ្ញុំ។ គាត់ទាំងពីរនាក់ពេញចិត្តនាងជាខ្លាំង។ យើងបានរៀបការដោយក្តីស្រឡាញ់ ខ្ញុំជាអ្នកចំណាយថ្លៃបណ្ណាការនៃអាពាហ៍ពិពាហ៍នេះ។

បន្ទាប់ពីរៀបការរួច ខ្ញុំបាននាំប្រពន្ធរបស់ខ្ញុំទៅខេត្តកោះកុង និងបានផ្ទេរធ្វើការងារនៅមន្ទីរព្យាបាលតាមប៉ុស្តិ៍។ ខ្ញុំអាចសន្សំប្រាក់បានច្រើននៅខេត្តកោះកុង ព្រោះអីវាមានអ្នកជំងឺគ្រុនចាញ់ជាច្រើន។ ប៉ុន្តែនៅឆ្នាំ១៩៦៤ ខ្ញុំបានផ្ទេរទៅធ្វើការនៅខេត្តតាកែវ និងបន្ទាប់មកនៅឆ្នាំ១៩៧០ ទៅខេត្តកណ្តាល។

បន្ទាប់ពីបានរៀនសូត្រក្បួនយុទ្ធសាស្រ្តកងទ័ពនៅប្រទេសវៀតណាមចំនួនប្រាំបីខែមក ខ្ញុំត្រូវបានតម្លើងឋានន្តរស័ក្តិជាអនុសេនីយ៍ឯក ហើយត្រឡប់ទៅតាខ្មៅ ដែលជាមជ្ឈមណ្ឌលប្រត្តិបត្តិការសឹក ដើម្បីការពារមូលដ្ឋានកងទ័ពភ្នំពេញ។ ខ្ញុំធ្វើការនៅផ្នែកភ័ស្តុភារដែលទទួលខុសត្រូវលើស្បៀងអាហារ និងទំនិញផ្សេងៗ។

នៅពេលដែលខ្ញុំត្រូវបានបញ្ជូនទៅវាយប្រយុទ្ធនៅភូមិសិតត្បូរ ខ្ញុំបានបែកចេញពីទាហានផ្សេងទៀត និងសន្លប់ពីរយប់ពីរថ្ងៃ។ កងទ័ពរបស់ខ្ញុំគិតថាខ្ញុំបានស្លាប់នៅលើសមរភូមិប្រយុទ្ធហើយ ប៉ុន្តែខ្ញុំបានត្រឡប់មកវិញប្រកបដោយ

សុវត្ថិភាព ក្នុងស្ថានភាពល្អប្រសើរ។

បន្ទាប់មក ខ្ញុំបានចំណាយប្រាក់បីសែនរៀលជាការសូកប៉ាន់ ដែលខ្ញុំអាចនឹងផ្ទេរទៅធ្វើការនៅការិយាល័យយោធិនពិការ ព្រោះខ្ញុំមិនចង់ចេញទៅសមរភូមិទៀតទេ។ ខ្ញុំធ្វើការនៅទីនោះរហូតដល់ឆ្នាំ១៩៧៥។

នៅថ្ងៃដែលខ្មែរក្រហមជម្លៀសអ្នកភ្នំពេញ ខ្មែរក្រហមបានសន្យាថា មួយសប្តាហ៍ក្រោយមកប្រជាជនអាចត្រឡប់ទៅផ្ទះវិញ។ ខ្មែរក្រហមបាននិយាយទៀតថា ខ្លួនត្រូវការពេលវេលាបោសសម្អាតខ្មាំងស ត្រូវឲ្យអស់ពីទីក្រុង។ ខ្ញុំបានលាក់ឯកសណ្ឋានយោធា និងកាំភ្លើងរបស់ខ្ញុំ ហើយស្លៀកពាក់ស៊ីវិលចាកចេញពីផ្ទះ។ ខ្ញុំដាក់របស់របរប្រើប្រាស់ផ្ទាល់ខ្លួនមួយចំនួននៅលើកង់ ហើយធ្វើដំណើរ១៥ថ្ងៃ ទើបទៅដល់ស្រុកកំណើត។

អង្គការបានចាត់តាំងខ្ញុំ ឲ្យទៅរស់នៅជាមួយឪពុកម្តាយរបស់ខ្ញុំដែលជាអ្នកមូលដ្ឋាន។ អ្នកភូមិទាំងអស់បានដឹងអំពីអតីតភាពមុខងាររបស់ខ្ញុំ ព្រោះអីខ្ញុំបានជួយជាច្រើនដង ពេលខ្ញុំធ្វើជាទាហាន លន់ នល់។ ជាខទាហរណ៍ មានម្តងនោះ ទាហាន លន់ នល់ ចាប់បានយោធាខ្មែរក្រហមមួយចំនួនដែលមកទិញថ្នាំពេទ្យនៅតាខ្មៅ ប៉ុន្តែខ្ញុំបានដោះលែងអ្នកទាំងអស់នោះវិញ។ ខ្មែរក្រហមទាំងនោះបានអរគុណចំពោះការជួយរបស់ខ្ញុំ។

នៅពេលយើងទៅដល់ដំបូង យើងមានអាហារហូបចុកគ្រប់គ្រាន់។ គណ:ភូមិមានសន្តានចិត្តល្អចំពោះខ្ញុំ និងគ្រួសាររបស់ខ្ញុំ។ គាត់បានប្រាប់កម្មាភិបាលឲ្យយកចិត្តទុកដាក់ដល់ខ្ញុំ។ ស្របពេលគ្នានោះដែរ ខ្ញុំបានឃើញប្រជាជនថ្មីបានបាត់ខ្លួនពីភូមិជារៀងរាល់ថ្ងៃ។ អង្គការបានបញ្ជាឲ្យខ្ញុំទៅលើកទំនប់ និងជីកប្រឡាយ។

ក្រោយមក អង្គការបានបញ្ជូនខ្ញុំទៅវត្តអង្គចង្អេរ នៅក្នុងស្រុកសំរោង។ ខ្ញុំត្រូវបានឃុំឃាំងនៅទីនោះ ព្រោះខ្ញុំជាទាហាន លន់ នល់។ គឺ ដែលជាអ្នកធ្វើការនៅមន្ទីរសន្តិសុខ បានប្រាប់ខ្ញុំថា កុំនិយាយស្តីអ្វី បើមិនអញ្ចឹងទេនឹងត្រូវគេសម្លាប់។ នៅក្នុងបន្ទប់ដែលខ្ញុំជាប់ឃុំនោះ មិនមានកន្ទេលដេកទេ មានតែស្លឹកត្នោតប៉ុណ្ណោះ អ្នកទោសទាំងអស់បានបត់ជើងតូច-ធំ ដាក់ក្នុងពាងធំមួយ។ យើងធ្វើការចាប់ពីម៉ោង ៤ និង៣០នាទី នាពេលព្រលឹមស្រាងៗ រហូតដល់យប់។ បន្ទាប់ពីនៅក្នុងមន្ទីរសន្តិសុខបានបីថ្ងៃមក គណ:ឃុំបានប្រាប់ខ្ញុំថា ខ្ញុំអាចដេកនៅក្រៅបន្ទប់នោះបាន ហើយខ្ញុំត្រូវបានចាត់ឲ្យធ្វើជាអ្នកយកអាហារទៅឲ្យអ្នកទោស។

កំឡុងពេលដែលខ្ញុំជាប់ឃុំឃាំង បងប្រុស និងម្តាយរបស់ខ្ញុំបានស្លាប់ដោយសារអត់បាយ។ ខ្ញុំត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរសន្តិសុខ ចំនួនមួយអាទិត្យឲ្យទៅកប់សាកសពអ្នកទាំងពីរ។

បន្ទាប់មកអង្គការបានបញ្ជូនប្រពន្ធរបស់ខ្ញុំ និងកូនៗមករស់នៅជាមួយខ្ញុំនៅក្នុងសហករណ៍ជាទីដែលខ្ញុំបានជាប់ឃុំឃាំង។ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានអង្គភាពរកម្ហូបអាហារសម្រាប់សហករណ៍។ ទោះជាបុរសឈ្មោះកេតបានប្រាប់អង្គការថា ខ្ញុំមិនបានបំពេញការងារល្អយ៉ាងណាក៏ដោយ ក៏អង្គការបានបន្តតាមដានការងារដែលខ្ញុំធ្វើ និងបានដឹងថា ខ្ញុំមិនបានធ្វើអ្វីខុសឆ្គងឡើយ។ ហេតុដូច្នេះហើយ ខ្ញុំបានធ្វើការនៅទីនោះរហូតដល់កងទ័ពវៀតណាមចូលមករំដោះប្រទេសកម្ពុជា។

នៅឆ្នាំ១៩៧៩ ខ្ញុំបានយកអង្ករខោអាវ និងប្រាក់ដុល្លារអាមេរិកមួយចំនួនពីផ្ទះម្តាយរបស់ខ្ញុំ ដែលខ្ញុំបានយកមកពីភ្នំពេញជាយូរមកហើយ រួចប្រមូលដាក់ក្នុងរទេះអូសមួយ។ នៅតាមផ្លូវទៅភ្នំពេញ យោធាខ្មែរក្រហមបានព្យាយាមបាញ់ខ្ញុំ។ ខ្ញុំបានបោះបង់ចោលរបស់របរប្រើប្រាស់ផ្ទាល់ខ្លួនរបស់ខ្ញុំនៅកន្លែងនោះ រួចរត់យករួចខ្លួន។

ខ្ញុំបានឆ្អែតចិត្តជាមួយនឹងអតីតភាពការងាររបស់ខ្ញុំ ហើយមិនអនុញ្ញាតឲ្យកូនៗរបស់ខ្ញុំ ធ្វើជាប៉ូលិស ឬទាហានឡើយ។

**ប៉ាង ពីច័ន្ទ និង ទេនី ខកះហ្គៀល**

### «ផេះផង់ធូលី»

## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ខៀវ នឿន ៖ អនុសេនីយ៍ទោ

**ប្អូនស្រីរបស់ ខៀវ នឿន ឈ្មោះ ខៀវ ណេង បាននិយាយរៀបរាប់ប្រាប់ថា ៖**

នឿនបានរៀនសូត្រនៅខេត្តកណ្ដាល។ គាត់ជាសិស្សពូកែម្នាក់ បានទទួលសញ្ញាប័ត្រឌីប្លូម។ នៅអំឡុងពេលវឹកវរបន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ នឿន បានស្ម័គ្រចិត្តចូលក្នុងកងកុម្មង់ដូ ការពារសាលារៀនរបស់គាត់នៅពេលយប់ ព្រោះខ្លាច យៀកកុង ចូលមកដុតបំផ្លាញសាលារៀន។ គាត់ស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវដូចស្លឹកឈើ និងកាន់កាំភ្លើង។ ទោះបីជាគាត់ត្រូវបង់មួយខែចំនួន ៥០០រៀល សម្រាប់ការងារនេះក្ដី វាមិនគ្រប់គ្រាន់សម្រាប់ម្ហូបអាហារទេ។

នៅឆ្នាំ១៩៧២ គ្រាប់បែកជាច្រើនបានធ្លាក់នៅក្នុងភូមិរបស់យើង។ ដូច្នេះ នឿន បានទៅភ្នំពេញ។ នៅភ្នំពេញ គាត់បានស្ម័គ្រចិត្តចូលបំរើទាហាន លន់ នល់។ ពីរឆ្នាំក្រោយមក គាត់ត្រូវបានបញ្ជូនទៅហ្វឹកហ្វឺនយោធានៅខេត្តឡុង ហៃ ប្រទេសវៀតណាមចំនួនបីខែ។ នៅពេលដែលគាត់មកលេងផ្ទះ គាត់បានស្នាក់នៅតែពីរបីថ្ងៃទេ។ គ្រាមួយនោះគាត់បានមកផ្ទះដោយមានកាន់របស់របរមួយចំនួន រួមមាន ចង្ក្រានមួយ រូបថតច្រើនសន្លឹក និងសារ៉ុងជាច្រើន។

បន្ទាប់មក នឿន បានផ្ទេរទៅខេត្តបាត់ដំបង ជាមួយបងប្អូនជីដូនមួយពីរបីនាក់ទៀត។ គាត់បានឡើងឋានន្តរស័ក្ដិជាអនុសេនីយ៍ទោនៅក្នុងទ័ពអាកាស។ គាត់បានរៀបការជាមួយនារីម្នាក់ឈ្មោះ រឿន ជាគ្រូបង្រៀនមកពីស្វាយស៊ីសុផុន។

ដំបូងឡើយយើងមិនបានដឹងថាគាត់រៀបការទេ ព្រោះទំនាក់ទំនងបានកាត់ផ្ដាច់នៅអំឡុងពេលសង្គ្រាម ប៉ុន្តែបន្ទាប់មកយើងបានឮព័ត៌មាននេះពីបងប្អូនជីដូនមួយរបស់ខ្ញុំដែលធ្វើការនៅខេត្តបាត់ដំបង។

នឿន បានធ្វើការនៅក្រុងភ្នំពេញនៅពេលដែលខ្មែរក្រហមជម្លៀសអ្នកទីក្រុង។ គាត់បានព្យាយាមទៅផ្ទះនៅភូមិរបស់យើង ប៉ុន្តែផ្លូវត្រូវបានបិទ។ ដូច្នេះ នឿន បានលក់ខោអាវដែលគាត់យកមកឲ្យយើង ហើយគាត់និងប្រពន្ធរបស់គាត់បានទៅភូមិកំណើតឪពុកម្ដាយរបស់ប្រពន្ធគាត់នៅខេត្តបាត់ដំបង។ អង្គការបានចាត់គាត់ឲ្យទៅដឹកជញ្ជូនស្រូវពោតទៅសហករណ៍ផ្សេងៗ។



ខៀវ នឿន ក្នុងឯកសណ្ឋានសន្តិសុខការពារសាលារៀន ក្នុងរបប លន់ នល់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃមួយនៅក្នុងឆ្នាំ១៩៧៦ រទេះគោដែលគាត់បរនោះបានក្រឡាប់។ ប្រធានក្រុមបានរាយការណ៍ទៅអង្គការអំពីរឿងនេះ ដោយបាននិយាយថា ការបំផ្លាញរទេះ គឺហាក់ដូចជាគាត់បានបំផ្លាញអង្គការដែរ។ ប្រធានក្រុមនោះបានបន្ថែមទៀតថា នឿន ធ្លាប់ធ្វើជាអនុសេនីយ៍ទោនៅក្នុងកងទ័ពលន់ នល់។ បន្ទាប់មកកម្មាភិបាលបានចាប់គាត់ ហើយបានយកគាត់ទៅសម្លាប់។

រឿន ដែលជាប្រពន្ធរបស់ នឿន បានរង់ចាំការវិលត្រឡប់មកវិញរបស់ នឿន យ៉ាងយូរ។ បន្ទាប់មកប្រធានក្រុមដដែលនោះបានសុំ រឿន រៀបការ និងបាននិយាយថា គាត់នឹងសម្លាប់នាង និងគ្រួសាររបស់យើងប្រសិនបើនាងប្រកែក។ ការសម្លុតបំភ័យនោះ រឿន បានយល់ព្រម។ កូនប្រុសរបស់នាងជាមួយ នឿន ទើបតែមានអាយុពីរឆ្នាំទេ នៅពេលនោះ។

រឿន បានផ្ញើរូបថតជាច្រើនមកឲ្យគ្រួសារខ្ញុំ យើងបានស្គាល់នាងតាមរូបថតទាំងនោះ។ បន្ទាប់មក នាងបានមកលេងស្រុកកំណើតរបស់ខ្ញុំនៅខេត្តកណ្ដាល។ រឿន បានប្រាប់យើងថា គាត់បានលែងលះប្ដីទីពីររបស់នាង នៅពេល



ខៀវ នឿន ឈរនៅខាងឆ្វេងម្តាយរបស់គាត់ឈ្មោះ ទូច, និងបងប្អូនប្រុសស្រី ៧ នាក់ ក្នុងចំណោមបងប្អូន៩នាក់របស់គាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ខៀវ ណឹម នៅជួរមុខកណ្តាល និង ខៀវ នឿន ប្រត់បង្កេះ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដែលរបបខ្មែរក្រហមបានដួលរលំ។ ទោះបីជាអ្នកទាំងពីរមានកូនពីរនាក់ជាមួយគ្នាក៏ដោយ ប្តីរបស់ រឿន ជាអ្នកលេងល្បែង និងបានចាញ់ល្បែងអស់ប្រាក់កាសពីខ្លួន។

បងប្រុសទីពីររបស់ខ្ញុំឈ្មោះ ណឹម បានបញ្ចប់វិទ្យាល័យនៅក្នុងរបប លន់ នល់ បន្ទាប់មកគាត់បានរៀនវេជ្ជសាស្ត្រពេទ្យ នៅក្រុងភ្នំពេញ។ មុនពេលចូលឆ្នាំខ្មែរបន្តិច នៅខែមេសា ឆ្នាំ១៩៧៥ ណឹម បានមកលេងផ្ទះរបស់យើង។ គាត់បម្រុងស្នាក់នៅតែមួយថ្ងៃប៉ុណ្ណោះ ប៉ុន្តែយោធាខ្មែរក្រហមមិនបានអនុញ្ញាតឲ្យគាត់ចាកចេញឡើយ។ ដូច្នេះគាត់បានស្នាក់នៅក្នុងភូមិ ហើយមួយឆ្នាំក្រោយមកអង្គការបានជ្រើសរើសគាត់ឲ្យធ្វើជាឈ្លបភូមិ។

មិត្តភក្តិម្នាក់របស់ ណឹម ដែលបានរៀនសូត្រជាមួយគ្នា បានរាយការណ៍ប្រាប់អង្គការថា ណឹម បានរៀនសូត្រ និងចេះពីរភាសា គឺបារាំង និងអង់គ្លេស។ ទាំងនេះបានបង្កើតបញ្ហាច្រើនសម្រាប់យើង ខ្ញុំមានបងប្រុសម្នាក់ជាអតីតទាហានលន់ នល់ និងម្នាក់ទៀតជាខ្មែរក្រហម។

អង្គការបានចាត់តាំង ណឹម ឲ្យធ្វើជានីរសារ រត់សំបុត្រ គេឡេក្រាម ព្រោះអីយើងមិនមានទូរស័ព្ទប្រើទេនៅពេលនោះ។ ថ្ងៃមួយគេបានកុហក ណឹម ដោយបាននិយាយប្រាប់គាត់ថា ឲ្យទៅប្រូតស្រូវនៅឆ្ងាយពីភូមិ។ ក្មួយប្រុសរបស់ខ្ញុំដែលទៅជាមួយ ណឹម បាននិយាយប្រាប់ថា គេយកគាត់ទៅច្បាំងជាមួយទាហានវៀតណាម។ ក្មួយប្រុសខ្ញុំបានរត់ចោលសមរភូមិប្រយុទ្ធ ហើយមកផ្ទះវិញ ប៉ុន្តែ ណឹម ពិបាករត់ចេញណាស់ ព្រោះអីគាត់កាន់តេឡេក្រាម និងមានគ្រាប់ផ្លោងធ្ងាក់ជាច្រើន។ ប្រសិនបើ ណឹម រត់ចេញនៅតាមផ្លូវ គាត់នឹងត្រូវបានចាប់ខ្លួន។

ឪពុកម្តាយរបស់ខ្ញុំ ប្អូនប្រុស និងប្អូនស្រី បានរង់ចាំមើលផ្លូវគាត់ ប៉ុន្តែការទន្ទឹងរង់ចាំចេះតែកន្លងផុតទៅយូរទៅៗ។ បន្ទាប់ពីការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ ខ្ញុំបានទៅរកគ្រូទាយម្នាក់សុំឲ្យគាត់ទាយអំពីបងប្រុសរបស់ខ្ញុំទាំងពីរ។ អ្នកគ្រូទាយបាននិយាយថា ពួកគាត់មិនត្រឡប់មកវិញទេ ដូច្នេះខ្ញុំអស់សង្ឃឹមថាបានជួបពួកគាត់ម្តងទៀតហើយ។

**ប៉ាង ពីច័ន្ទ និង ខេនី ខកហ្គ្បៀល**

# «ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# វីង វន ៖ ពលទាហាន

**ឈ្មោះ សូ វី ត្រូវជាប្រពន្ធរបស់ វីង វន បាននិយាយរឿងរ៉ាវប្រាប់ថា ៖**

*ប្តីរបស់ខ្ញុំឈ្មោះ វន គាត់មានសម្បុរសណ្តែកសៀងៗ គាត់ជាមនុស្សស្លូតបូត ខស្សហ៍ធ្វើការ និងគួរឲ្យស្រឡាញ់ៗ យើងបានរៀបការនៅពេលដែលខ្ញុំមានអាយុ១៦ឆ្នាំៗ ប្រហែលជាមួយខែក្រោយមក រដ្ឋអំណាចភូមិ និងឃុំបានបញ្ចុះបញ្ចូល វន ឲ្យចូលបម្រើកងទ័ពលន់ នល់ៗ គាត់មិនចង់ចូលទេ ប៉ុន្តែគាត់មានជម្រើសតិចតួចៗ គាត់បានវាយប្រយុទ្ធនៅលើសមរភូមិជាច្រើនៗ*

*នៅដើមឆ្នាំ១៩៧៥ ប្តីរបស់ខ្ញុំត្រូវបានបញ្ជូនឲ្យទៅភូមិមួយ នៅជាយក្រុងភ្នំពេញ នៅទីនោះគាត់ត្រូវរបួសនៅលើភ្លៅៗ បន្ទាប់ពីសហការីរបស់គាត់ បានផ្តល់ឲ្យខ្ញុំនូវដំណឹងរបស់គាត់ ខ្ញុំក៏បានជិះឧទ្ធម្ភាគចក្រពីខេត្តតាកែវមកមើលថែគាត់ៗ មុនដំបូង នៅពេលដែលខ្ញុំឃើញរបួសគាត់ ខ្ញុំបានស្រែកយំៗ គាត់មិនអាចបញ្ឈប់ការហូរឈាមបានទេ ហើយដំបៅរបស់គាត់មានដង្កូវជាច្រើនៗ វេជ្ជបណ្ឌិតជាច្រើននាក់បានព្យាយាមជួយគាត់ ប៉ុន្តែ វន មិនអាចដើរបានទេៗ*

*ខ្ញុំបានប្រកែកមិនចាកចោលគាត់ នៅពេលដែលខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញៗ នៅពេលដែលខ្មែរក្រហមបានបង្ខំយើងឲ្យចាកចេញពីមន្ទីរពេទ្យ ខ្ញុំបានដាក់*



*រូបថត វីង វន មួយខែមុនពេលគាត់រៀបការៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*វន នៅក្នុងរទេះអូសមួយ រួចចងគាត់នឹងក្រមាភ្ជាប់រទេះ ដើម្បីកុំឲ្យធ្លាក់ចេញពីរទេះៗ ខ្ញុំស្ទើរតែហៀបនឹងឆ្លងទន្លេ ព្រោះពោះរបស់ខ្ញុំវាធំខ្លាំងពេកដូច្នេះវារឹតតែធ្វើឲ្យខ្ញុំមានការលំបាកក្នុងការធ្វើដំណើរៗ*

*នៅតាមផ្លូវខ្ញុំបានកប់ឯកសារ និងឯកសណ្ឋានរបស់ វនៗ នៅពេលដែលខ្មែរក្រហមសួរយើង ខ្ញុំប្រាប់ថាប្តីរបស់ខ្ញុំជាអ្នកលក់ការ៉េមកី ហើយខ្ញុំជាមេផ្ទះៗ ប៉ុន្តែដោយសារ វន មានរបួសជើង ខ្មែរក្រហមមិនជឿយើងឡើយៗ ខ្មែរក្រហមបានយកប្តីខ្ញុំដាក់ចូលទៅក្នុងរថយន្តមួយៗ ខ្ញុំគិតថាខ្មែរក្រហមបានសម្លាប់គាត់ ព្រោះអីគាត់ជាទាហានលន់ នល់ៗ ខ្ញុំត្រូវបានជម្លៀសទៅភូមិចំបក់ នៅក្នុងខេត្តកំពង់ចាម បន្ទាប់*

ពីខ្ញុំទៅដល់១៥ថ្ងៃ ក្រោយមក ខ្ញុំបានឆ្លងទន្លេកើតបានកូនស្រីម្នាក់។ ខ្ញុំមានការខ្លាចរអាជាខ្លាំង ដោយខ្ញុំមិនដឹងថាត្រូវកើតកូនង៉ាយ៉ាងម៉េច ហើយនៅទីនោះមិនមានពេទ្យឆ្មបជួយខ្ញុំទេ។ យ៉ាងណាក៏ដោយ មានមនុស្សម្នាក់នៅក្នុងចំណោមអ្នកជិតខាងរបស់ខ្ញុំបានដឹងអំពីការបង្កើតកូន ហើយគាត់ក៏បានជួយខ្ញុំ។ វាជាការកើតកូនតាមធម្មជាតិនិងមានការឈឺចាប់យ៉ាងខ្លាំង។

អ្នកភូមិជាច្រើននាក់បានប្រាប់ខ្ញុំឲ្យដាក់ឈ្មោះកូនស្រីរបស់ខ្ញុំថា ចំបក់ ដូច្នេះនាងមិនអាចបំភ្លេចទីកន្លែងដែលនាងបានចាប់កំណើតឡើយ។ ១៥ថ្ងៃបន្ទាប់មក ខ្ញុំត្រូវបានចាត់ឲ្យទៅធ្វើការនៅវាលស្រែ។ ខ្ញុំបានយកចំបក់ទៅស្រែជាមួយ ហើយបានដាក់នាងឲ្យដេកនៅក្នុងអង្រឹងមួយ ខណៈដែលខ្ញុំកំពុងធ្វើការ។ ប៉ុន្តែ នៅពេលដែលនាងឈឺក្តៅខ្លួនខ្លាំង នៅទីនោះមិនមានវេជ្ជបណ្ឌិតព្យាបាលនាងទេ។ នាងបានស្លាប់នៅពេលដែលនាងមានអាយុ៩ខែ។ ខ្ញុំបានសួរអង្គការថា ខ្ញុំអាចកប់សាកសពកូនស្រីរបស់ខ្ញុំបានទេ? ប៉ុន្តែអង្គការបានបដិសេធ ហើយបានគ្រវែងសាកសពនាងចូលទៅក្នុងស្មឹង។ ខ្ញុំយំយ៉ាងស្ងៀមស្ងាត់ ព្រោះបើកម្មាភិបាលឮខ្ញុំយំ ខ្ញុំនឹងត្រូវសម្លាប់។

ខណៈដែលខ្ញុំកំពុងធ្វើការនៅវាលស្រែ ឈ្លបស៊ើបការណ៍បានមកឆែកឆេរផ្ទះខ្ញុំច្រើនដង ប៉ុន្តែឈ្លបមិនអាចរកអ្វីឃើញឡើយ។ ខ្ញុំបានលាក់ទុករូបថតរបស់យើងនៅក្នុង ថង់ផ្លាស្ទិកមួយ ហើយរក្សាទុករូបថតទាំងនោះនៅក្នុងហោប៉ៅអាវរបស់ខ្ញុំ។ អង្គការបានបន្តសួរនាំខ្ញុំអំពីប្តីរបស់ខ្ញុំ ប៉ុន្តែខ្ញុំបានប្រាប់


រូបថត សូរី មួយខែមុនពេលគាត់រៀបការ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គេថាគាត់ជាអ្នកលក់ការ៉េមគី ហើយត្រូវបានយកទៅសម្លាប់រួចហើយ។ ទីបំផុតអង្គការបានឈប់សួរនាំខ្ញុំអំពី វាន។

នៅពេលដែលកងទ័ពវៀតណាមចូលមករំដោះនៅឆ្នាំ១៩៧៩ ខ្ញុំបានរត់ទៅភូមិ ហើយលួចបានស្រូវមួយចំនួនដែលទើបតែច្រូតកាត់ប្រមូលបាន។ ខ្ញុំបានឲ្យស្រូវពីរកញ្ជើ ទៅអ្នករត់ទូក ដូច្នេះ គាត់នឹងនាំខ្ញុំត្រឡប់ទៅភ្នំពេញវិញ។ ជាចុងក្រោយ ម្តាយរបស់ខ្ញុំបានរកខ្ញុំឃើញ ហើយយើងបានត្រឡប់ទៅផ្ទះរបស់យើងនៅក្នុងខេត្តតាកែវ ប៉ុន្តែនៅពេលដែលយើងទៅដល់ យើងឃើញថាផ្ទះនោះត្រូវបានបំផ្លាញទាំងស្រុង ដោយសារគ្រាប់បែក។

ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំថា ខ្មែរក្រហមបានសម្លាប់ឪពុករបស់ខ្ញុំ ព្រោះគាត់បានបដិសេធធ្វើតាមអង្គការដែលបានបញ្ជាឲ្យបងស្រីរបស់ខ្ញុំរៀបការ។ កម្មាភិបាលពីរនាក់បានបណ្តើរឪពុកខ្ញុំចេញពីភូមិ ហើយគាត់បានបាត់ខ្លួនរហូត។ ពីរបីថ្ងៃក្រោយមកបងស្រីរបស់ខ្ញុំបានបាត់ខ្លួន ដូចគ្នានឹងឪពុករបស់ខ្ញុំដែរ។

**ប៊ុន ពីរ័ន្ត និង ទេនី ខករហ្គៀល**

## «ផ្ទះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ហេង សុផាណា ៖ ពលបាលទោ

ខ្ញុំមានសំណាងណាស់ដែលបានរៀបការជាមួយប្ដីខ្ញុំ។ ប្រសិនបើខ្ញុំរៀបការជាមួយបុរសកំណាញ់វិញ ខ្ញុំប្រហែលនឹងត្រូវស្លាប់ពីការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម។ ប្ដីរបស់ខ្ញុំជាបុរសសង្ហារម្នាក់ និងមាននារីជាច្រើនបានចោមរោមគាត់។ យើងបានទៅសាលារៀនជាមួយគ្នា រយៈពេលបួនឆ្នាំ មុនពេលយើងរៀបការជាមួយគ្នា។ គាត់តែងតែរង់ចាំខ្ញុំនៅច្រកទ្វារសាលារៀន និងពេលខ្លះបានទុកសំបុត្របុប្ផានៅលើតុរបស់ខ្ញុំ។

ឪពុកម្ដាយរបស់ខ្ញុំមិនចូលចិត្តប្ដីរបស់ខ្ញុំឡើយ។ នៅថ្ងៃមួយឪពុកខ្ញុំបានបញ្ជូនខ្ញុំឲ្យទៅរស់នៅជាមួយឪពុកធំខ្ញុំនៅខេត្តកំពង់ចាម ដោយសង្ឃឹមថាខ្ញុំនឹងបំភ្លេចប្ដីរបស់ខ្ញុំ។ ប៉ុន្តែខ្ញុំបានឈប់ញ៉ាំ ឈប់ផឹករហូតដល់ខ្ញុំធ្លាក់ខ្លួនឈឺជាទំនង់។ បន្ទាប់មក ឪពុករបស់ខ្ញុំបានអនុញ្ញាតឲ្យខ្ញុំត្រឡប់មកភ្នំពេញវិញ និងយល់ព្រមឲ្យខ្ញុំរៀបការ។

បន្ទាប់ពីយើងរៀបការរួចមក ខ្ញុំបានទៅធ្វើការនៅការិយាល័យមួយនៅក្នុងមន្ទីរពេទ្យព្រះមុនីវង្ស ក្រុងភ្នំពេញ។ ថ្វីបើខ្ញុំបានរៀនក្បួនយុទ្ធសាស្ត្រយោធាខ្លះៗក្ដី ខ្ញុំមិនដែលចេញទៅសមរភូមិឡើយ។ ប្ដីរបស់ខ្ញុំបានប្រឡងវិទ្យាល័យ



ហេង សុផាណា (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ស្រស់ កូនស្រីរបស់ ហេង សុដាណា (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ធ្លាក់ ដូចនេះ គាត់បានសម្រេចចិត្តធ្វើការឲ្យឪពុករបស់គាត់ ដែលមានយានដ្ឋានជួសជុលរថយន្តផ្ទាល់ខ្លួន។

នៅថ្ងៃទី១៧ មេសា គ្រួសាររបស់ខ្ញុំដែលមានសមាជិកច្រើននាក់ ត្រូវបានជម្លៀសបែកខ្ញែកពីគ្នា។ យើងបានជួបជុំគ្នាវិញនៅក្បែរស្រុកកៀនស្វាយ ហើយនៅទីនោះរង់ចាំការប្រកាសឲ្យអ្នកទីក្រុងវិលត្រឡប់ចូលភ្នំពេញវិញ។ ប៉ុន្តែបន្ទាប់មក ឪពុកម្តាយរបស់ខ្ញុំនិងបងប្អូនប្រុសស្រីបានទៅរស់នៅខេត្តបាត់ដំបង ខណៈដែលប្តីរបស់ខ្ញុំ និងកូនៗរបស់យើង និងខ្ញុំបានទៅខេត្តបន្ទាយមានជ័យ។

គ្រាមួយនោះ អង្គការបានប្រាប់យើងថា ប្រជាជនដែលជាជនជាតិវៀតណាមអាចវិលត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ។ ដូច្នេះខ្ញុំបានសុំស្ត្រីចំណាស់ម្នាក់ ដែលជាជនជាតិវៀតណាម ហើយមិនអាចនិយាយភាសាខ្មែរច្បាស់ធ្វើជាម្តាយរបស់ខ្ញុំ។ ប្តីរបស់ខ្ញុំ និងខ្ញុំបានប្តូរឈ្មោះរបស់យើងទៅជាឈ្មោះជនជាតិវៀតណាម។ ប្តីខ្ញុំមានឈ្មោះ ខ្វាង ហ៊្វួត និងខ្ញុំឈ្មោះ គីម ឡាង។ បន្ទាប់មកជនជាតិវៀតណាម ចំនួន ២០គ្រួសារ ត្រូវបានយកចេញពីភូមិ។ ខ្ញុំបានឮថា អ្នកទាំងនោះត្រូវបានដាក់នៅក្នុងទូកជាច្រើន នៅពេលទូកចេញទៅដល់កណ្តាលទន្លេ អង្គការបានពន្លិចទូកទាំងនោះ។ អង្គការបានចាក់ភ្លេងឮសម្លេងខ្លាំង ដែលធ្វើហាក់ដូចជាវាមិនមានរឿងអីសោះកើតឡើង។ បន្ទាប់ពីនោះមក យើងបានប្តូរឈ្មោះត្រឡប់ទៅឈ្មោះដើមរបស់យើងវិញ។

នៅពេលដែលខ្ញុំឃ្លាន មានតែប្តីរបស់ខ្ញុំម្នាក់គត់ ដែលបានព្យាយាមរកអាហារសម្រាប់ខ្ញុំ។ ខ្ញុំនៅចងចាំបានប្រាប់គាត់ថា ខ្ញុំចង់ផឹកកាហ្វេ។ គាត់បានដើរចេញទៅក្រៅមិនបាននិយាយអ្វីមួយម៉ាត់។ មួយសន្ទុះក្រោយមក

គាត់បានត្រឡប់មកផ្ទះវិញមានទឹកមុខញញឹមញញែមៗ គាត់បានបង្ហាត់ភ្លើងលីងអង្ករពីរក្តាប់ទាល់តែខ្មោច ហើយបន្ថែមស្ករត្នោតមួយស្លាបព្រាៗ បន្ទាប់មកគាត់បានលាងសម្អាតមើមក្រវាញច្រាំដុំ នៃឫសក្រវាញ រួចបុកឲ្យម៉ត់ បន្ថែមចូលទៅក្នុងទឹកដាំពុះៗ បន្ទាប់មកចាក់លាយចូលទៅក្នុងត្រឡោកដូងមួយ, គាត់បានឲ្យខ្ញុំ នេះជា "កាហេ" របស់ខ្ញុំៗ

នៅថ្ងៃមួយខ្ញុំបានឈឺពោះឆ្លងទន្លេ ប្តីរបស់ខ្ញុំបានរត់ចេញទៅទាំងយប់ទៅរកឆ្មបរបស់ខ្មែរក្រហមៗ ប៉ុន្តែឆ្មបនោះបានជាប់រវល់ ព្រោះប្រពន្ធរបស់គណៈភូមិបានឆ្លងទន្លេបានកូនមួយនៅពេលតំណាលគ្នានេះដែរៗ ម្យ៉ាងទៀត ឆ្មបនោះមិនចង់មក ព្រោះប្តីខ្ញុំមិនបានឲ្យអ្វីដល់គាត់ជាសរគុណៗ យ៉ាងណាក៏ដោយ ខ្ញុំបានបង្កើតកូនប្រុសដែលមានសុខភាពល្អម្នាក់ ដោយមានជំនួយពីអ្នកជិតខាងរបស់ខ្ញុំៗ ព្រឹកបន្ទាប់មកប្តីរបស់ខ្ញុំបានធ្វើបបរមាន់ជូនស្ត្រីដែលបានជួយខ្ញុំៗ

មុនពេលប្តីខ្ញុំចេញទៅធ្វើការ គាត់តែងតែប្រាប់ខ្ញុំថា កុំបោកគក់កន្ទបកូនគាត់នឹងបោកគក់កន្ទបនោះ នៅពេលដែលគាត់ត្រឡប់មកវិញៗ ប៉ុន្តែខ្ញុំមិនបានស្តាប់គាត់ឡើយ រួចបានបោកគក់កន្ទបនោះនៅក្នុងប្រឡាយទឹកមួយៗ ខ្ញុំបានស្ពឹកជើងទាំងពីរដោយសារនៅក្នុងទឹកយូរពេកៗ ប្តីខ្ញុំបានច្របាច់ជើងរបស់ខ្ញុំពេញមួយអាទិត្យៗ បន្ទាប់មកគាត់បានអៀវខ្ញុំលើខ្នងគាត់ជាមួយនឹងកូនង៉ារបស់យើងទៅមន្ទីរពេទ្យៗ មន្ទីរពេទ្យនោះមានចម្ងាយ៥គីឡូម៉ែត្រៗ

នាយប់មួយ ដែលមានព្រះខែរះពេញវង់ ខ្ញុំបានយល់សប្តិឃើញកាំបិតមួយបានបាក់ជាពីរកំណាត់ៗ វាហាក់ដូចជាមានប្រផ្នូលអាក្រក់នឹងកើតមានឡើង ហើយខ្ញុំមិនអាចត្រឡប់ចូលទៅដេកវិញឡើយៗ ព្រឹកបន្ទាប់មកកម្មាភិបាលម្នាក់ បានប្រាប់ប្តីខ្ញុំឲ្យទៅភ្ជួរស្រែៗ ខ្ញុំបានឲ្យដែកកេះដុតបារីមួយទៅគាត់ក្នុងករណីគាត់ត្រូវការវា បន្ទាប់មកខ្ញុំបានចេញទៅធ្វើការៗ ខណៈដែលខ្ញុំកំពុងស្ទូងស្រូវ កម្មាភិបាលខ្មែរក្រហមម្នាក់បានចំអកឲ្យខ្ញុំ ដោយនិយាយថា "សមមិត្តក្លាយជាស្ត្រីមេម៉ាយក្មេងវ័យហើយៗ ខ្ញុំពិតជាអាណិតអាសូរអ្នកណាស់"ៗ ខ្ញុំបានតបថា "សមមិត្តឯងប្រឡំទេដឹង ប្តីរបស់ខ្ញុំនៅរស់នៅឡើយ"ៗ ក្រោយមកខ្ញុំបានឃើញកម្មាភិបាលនោះបានប្រើដែកកេះដុតបារីរបស់ប្តីខ្ញុំៗ ខ្ញុំបានដឹងថាប្តីខ្ញុំនឹងមិនមកផ្ទះជារៀងរហូតៗ

កូនបីនាក់របស់ខ្ញុំបានស្លាប់នៅក្នុងរបបនោះៗ កូនប្រុសទីមួយឈ្មោះ ភ័ក្រ បានស្លាប់ដោយសារការអត់ឃ្លាននៅឆ្នាំ១៩៧៨ៗ កូនស្រីទីពីរឈ្មោះ ស្រស់ បានស្លាប់ដោយសារជំងឺនៅក្នុងឆ្នាំ១៩៧៥ៗ កូនប្រុសទីបីបានស្លាប់នៅពេលវាមានអាយុបានបីខែ ដោយជំងឺប៉ោវក្លាយ អាប់សែជិតតម្រងនោមរបស់វាៗ ប្រសិនបើប្តីខ្ញុំនៅរស់ គាត់នឹងរកបានម្ហូបគ្រប់គ្រាន់សម្រាប់កូនៗ ហើយពួកគេនឹងមិនស្លាប់ឡើយៗ

នៅឆ្នាំ១៩៧៩ ខ្ញុំបានជួបមិត្តខ្ញុំម្នាក់ និងបានប្រាប់នាងថា ខ្ញុំនៅរង់ចាំប្តីរបស់ខ្ញុំៗ នាងបាននិយាយថា ខ្ញុំបានដើរជាន់លើក្បាលប្តីរបស់ខ្ញុំរាល់ពេលនៅពេលដែលខ្ញុំដើរតាមផ្លូវកាត់ទៅស្រែដើម្បីធ្វើការៗ នាងបានព្យាយាមប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំបានស្លាប់ហើយ ប្រហែលជាបានកប់នៅតាមផ្លូវដែលខ្ញុំដើរញឹកញាប់នៅក្នុងកំឡុងរបបនោះៗ

រឿងរ៉ាវនេះយោងពីសំណេរមួយរបស់ ហេង សុផាណា ដែលមានចំណងជើងថា "ស្រមោលបង"ៗ រឿងនេះទទួលបានរង្វាន់ជ័យលាភីលេខមួយនៅក្នុងការប្រឡងប្រជែងមួយដែលឧបត្ថម្ភដោយសមាគមអ្នកនិពន្ធខ្មែរ និងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅឆ្នាំ២០០៤ៗ

**ប៊ុន ពីរ័ន្ត និង ដេវី ខកហ្កៀល**

«ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# អ៊ុក តាត ៖ អនុសេនីយ៍ទោ

**ថ្លុប ប៊ុនថន ជាកូនស្រីរបស់ អ៊ុក តាត បាននិយាយរៀបរាប់ប្រាប់ថា៖**

ឪពុករបស់ខ្ញុំឈ្មោះ អ៊ុក តាត គាត់ជាទាហានម្នាក់ៗ នៅក្នុងគ្រួសារមានតែគាត់ម្នាក់គត់បានទទួលការសិក្សារៀនសូត្រៗ គាត់បានទៅសាលារៀននៅក្នុងវត្តមួយ និងបានជួយគ្រួសាររបស់គាត់ដឹកជញ្ជូនបន្លែ ផ្លែឈើទៅផ្សារៗ បន្ទាប់មក រដ្ឋាភិបាលបារាំងបានជ្រើសគាត់ឲ្យចូលបម្រើកងទ័ពៗ

ម្ដាយរបស់ខ្ញុំឈ្មោះ ឈឹម រ៉ែត ធ្លាប់បានលក់នំនៅក្នុងផ្សារ កាលពីគាត់នៅក្មេងៗ ឪពុកខ្ញុំបានឃើញម្ដាយរបស់ខ្ញុំ ហើយបានតាមម្ដាយខ្ញុំទៅដល់ផ្ទះរបស់គាត់នៅជិតក្រុងភ្នំពេញៗ ឪពុកខ្ញុំបានស្នើសុំម្ដាយខ្ញុំរៀបការដោយខ្លួនគាត់ផ្ទាល់ ប៉ុន្តែជីដូនរបស់ខ្ញុំបានបដិសេធសំណើរបស់គាត់ ព្រោះអីឪពុកខ្ញុំមិនបាននាំឪពុកម្ដាយរបស់គាត់មកជាមួយទេៗ អ៊ីចឹង គាត់ក៏បាននាំចាស់ទុំម្នាក់មកផ្ទះម្ដាយខ្ញុំ ដើម្បីស្នើសុំរៀបការៗ បន្ទាប់មកជីដូនជីតារបស់ខ្ញុំបានយល់ព្រមៗ



អ៊ុក តាត និង ភរិយារបស់គាត់ ឈឹម រ៉ែត នៅខេត្តកណ្ដាល នៅឆ្នាំ១៩៧២ឬ ឆ្នាំ១៩៧៣ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងរបបសង្គមរាស្ត្រនិយម ពេលដែលការិយាល័យរបស់គាត់រកបេក្ខជនជាច្រើននាក់ទៅចូលរួមប្រឡងប្រណាំងកីឡាមួយ ឪពុកខ្ញុំបានស្ម័គ្រចិត្ត ព្រោះអីគាត់ជាអ្នកជិះកង់ប្រណាំងផង និងជាគ្រូបង្វឹកផង ហើយគាត់បានឈ្នះការប្រឡងជិះកង់ប្រណាំងថ្នាក់ជាតិៗ គាត់បានធ្វើដំណើរទៅប្រទេសឥណ្ឌូណេស៊ី ចូលរួមប្រកួតបានចំនួនបីដងៗ លើកទីមួយគាត់ប្រណាំងចាញ់ លើកទីពីរគាត់បានទទួលមេដៃធម្មតាមួយៗ ម្ដាយខ្ញុំបានប្រាប់ឪពុកខ្ញុំថា គាត់ចាញ់ ដោយសារគាត់ជាមនុស្សខិលៗ គាត់បានសុំទោសម្ដាយខ្ញុំពីការដែលគាត់មិនបានទទួលជ័យជម្នះ និងបាននិយាយថា គាត់បាត់បង់ការប្រមូលផ្ដុំអារម្មណ៍ ដោយសារឥណ្ឌូណេស៊ីបានបញ្ជូនស្រីស្អាតៗ មករោមចែចង់ជាមួយក្រុមរបស់គាត់ៗ

នៅពេលបន្ទាប់ ឪពុកខ្ញុំបានត្រៀមចិត្ត និងមានអារម្មណ៍នឹងនរ ហើយក៏ទទួលជ័យជម្នះបានលេខពីរ។ គាត់រីករាយសប្បាយចិត្តយ៉ាងខ្លាំង និងដាក់តាំងបង្ហាញពានប្រាក់របស់គាត់នៅក្នុងផ្ទះ។ ចោរហ្វាយ របស់គាត់បានទាមទារប្រាក់រង្វាន់មួយចំណែក ហើយក៏ចង់បានពាននោះដែរ។ គាត់បានខឹងនឹងឪពុកខ្ញុំ ព្រោះឪពុកខ្ញុំបានបដិសេធ។ ក្រោយមកចោរហ្វាយនោះបានផ្ទេរឪពុកខ្ញុំទៅច្បាំងនៅខេត្តបន្ទាយមានជ័យ។

ម្តាយខ្ញុំលក់ពងទាស្ងោរ និងលក់បបរត្រីឲ្យទាហានរបស់ឪពុកខ្ញុំ ដូច្នេះម្តាយខ្ញុំអាចរកចំណូលបន្ថែមជួយផ្គត់ផ្គង់គ្រួសាររបស់យើង។

មិត្តភក្តិរបស់ឪពុកខ្ញុំ និងប្រពន្ធរបស់ពួកគាត់បានសរសើរម្តាយខ្ញុំ ហើយបាននិយាយថា ម្តាយរបស់ខ្ញុំជាភរិយាគំរូម្នាក់ មិនដូចភរិយាអ្នកផ្សេងទៀតដែលញៀននឹងល្បែងនោះទេ។

សាច់ញាតិរបស់ឪពុកខ្ញុំខ្លះនៅខេត្ត មានមុខដំណែងសំខាន់ៗ នៅក្នុងជួរទាហានបានជួយផ្ទេរឪពុកខ្ញុំឲ្យត្រឡប់ទៅភ្នំពេញវិញ ធ្វើការជាគណនេយ្យករនៅក្នុងការិយាល័យយោធា ទោះបីគាត់មិនយល់ដឹងអ្វីសោះអំពីគណនេយ្យក៏ដោយ។

ប្រហែលឆ្នាំ១៩៧០ ឪពុកខ្ញុំបានឡើងឋានន្តរសក្តិជាអនុសេនីយ៍ទោ ហើយបានរក្សាដំណែងនេះរហូតដល់ឆ្នាំ១៩៧៥។ បន្ទាប់ពីគាត់ត្រឡប់មកភ្នំពេញ គាត់បានស្លៀកពាក់ឯកសណ្ឋានរបស់គាត់តែនៅក្នុងការិយាល័យប៉ុណ្ណោះ។ គាត់ស្លៀកពាក់ស៊ីវិលទៅធ្វើការនិងត្រឡប់មកផ្ទះវិញនៅពេលយប់។

ឪពុកខ្ញុំជាបុរសរួសរាយរាក់ទាក់។ គាត់មិនមែនជាបុរសសង្ហារទេ ប៉ុន្តែគាត់មានវិធីសាស្ត្រនិយាយបានល្អ។ គាត់ក៏ខិលណាស់ដែរ ហើយមានប្រពន្ធលួចលាក់ម្នាក់ ឬពីរនាក់។ នៅមុនថ្ងៃដែលយើងជម្លៀសចេញពីក្រុងភ្នំពេញ គាត់បាននាំប្រពន្ធទីពីររបស់គាត់មកជួបម្តាយរបស់ខ្ញុំ។ ស្ត្រីនោះបានលុតជង្គង់អង្វរម្តាយខ្ញុំឲ្យលើកលែងទោស។ ម្តាយរបស់ខ្ញុំបានគិតថា ស្ត្រីនោះគ្រាន់តែជាមិត្តស្រីធម្មតា ដែលឪពុកខ្ញុំមិនសូវចាប់អារម្មណ៍នឹងនាងប៉ុន្មានឡើយ។ ប៉ុន្តែ បន្ទាប់មកម្តាយខ្ញុំបានដឹងថាឪពុកខ្ញុំបានឲ្យប្រាក់ខែរបស់គាត់ជាច្រើនទៅស្ត្រីនោះ ដែលនាងមានកូនប្រុសពីរនាក់ជាមួយឪពុកខ្ញុំ។ មានក្មេងស្រីពីរនាក់នៅក្នុងគ្រួសាររបស់ខ្ញុំ ប៉ុន្តែឪពុកខ្ញុំគាត់ស្រឡាញ់កូនប្រុស និងចង់បានក្មេងប្រុស ទាំងអស់។

ក្មេងប្រុស ទាំងពីរនាក់ស្រដៀងទៅនឹងឪពុកខ្ញុំ។

នៅថ្ងៃដែលខ្មែរក្រហមឲ្យយើងចាកចេញពីទីក្រុង ឪពុកខ្ញុំដឹងថាទាហានលន់ នល់ នឹងចាញ់ ដូច្នេះគាត់បានគ្រវាត់ឯកសណ្ឋានយោធារបស់គាត់ចោល រួចពាក់អាវយឺតសធម្មតា។ គាត់បានដាក់ប្រាក់ទាំងអស់ដែលគាត់សន្សំបានទៅក្នុងថង់មួយ។ គាត់បានប្រាប់យើង មិនឲ្យនិយាយប្រាប់អ្នកផ្សេងអំពីវិជ្ជាជីវៈដែលគាត់បានធ្វើទេ។ គាត់បានប្តូរឈ្មោះរបស់គាត់ទៅជាគង់ ទៀង ឈ្មោះដើមរបស់គាត់គឺអ៊ុក តាត។ ក្រោយមកឪពុកខ្ញុំបាននាំប្រពន្ធទីពីររបស់គាត់ និងកូនៗ មកជាមួយគ្រួសាររបស់យើងទាំងពីរបានធ្វើដំណើរជាមួយគ្នា។

ដំបូងឡើយ យើងដើរមិនឆ្ងាយទេពីភ្នំពេញទៅផ្ទះរបស់យើងនៅស្រុកកៀនស្វាយ ប៉ុន្តែនៅពេលយើងទៅដល់ យើងឃើញថា អ្នកជម្លៀសជាច្រើនបានស្នាក់នៅរួចទៅហើយ។ យើងបានដេកផ្ទាល់ដីនៅក្រោមផ្ទះ។ បន្ទាប់មកអង្គការបានប្រាប់យើងឲ្យចាកចេញ។ ឪពុកខ្ញុំបានសម្រេចចិត្តថាយើងត្រូវតែទៅស្រុកជីដូនរបស់ខ្ញុំនៅព្រៃវែង ព្រោះអីទីនោះមានអ្វីៗហូបជាច្រើន។

បន្ទាប់ពីស្នាក់នៅជាមួយជីដូនរបស់ខ្ញុំមួយរយៈមក យើងត្រូវបានជម្លៀសទៅកាន់សហករណ៍មួយ ជាទីដែលឪពុកខ្ញុំគាត់កាប់សម្អាតព្រៃឫស្សីគាស់ដើមឈើ និងដាំស្រូវ។ នៅទីនោះ ពួកគេរើសអើងប្រជាជនថ្មីណាស់ ប្រជាជនមូលដ្ឋានបានទទួលបាយពីមួយទៅបីវែក ប៉ុន្តែមិនមែនសម្រាប់យើងទេ យើងទទួលបានបាយតែមួយវែកក្នុងមួយពេល។ ប្រជាជនមូលដ្ឋានត្រូវបានផ្តល់សម្ភត្រីមុន បន្ទាប់ពីប្រជាជនមូលដ្ឋានហូបរួច មិនមាននៅសល់ត្រីសម្រាប់ប្រជាជនថ្មីទេ។ ម្តាយរបស់ខ្ញុំ និងប្រពន្ធទីពីររបស់ឪពុកខ្ញុំបានធ្វើការយ៉ាងលំបាកជាមួយគ្នា ហើយមិនដែលឈ្លោះប្រកែកគ្នាម្តងណាឡើយ។ ខ្ញុំក៏បានមើលថែទាំកូនៗប្រពន្ធទីពីររបស់ឪពុកខ្ញុំដែរ។

ប្រហែលជានៅចុងឆ្នាំ ១៩៧៧ អង្គការបានបញ្ជូនបុរសម្នាក់ឈ្មោះស៊ុំ ទៅធ្វើការនៅសហករណ៍ផ្សេងទៀត បន្ទាប់មកគាត់ក៏បានបាត់ខ្លួន។ ឪពុកខ្ញុំគិតថា គាត់ជាអ្នកបន្ទាប់ព្រោះ



ឈឹម វ៉ែត (នៅខាងឆ្វេងដៃ) ជាមួយបងប្អូនជីដូនមួយអ៊ុក តាត, នី និង កេត ព្រមទាំងកូនស្រី ជួប ប៊ុនថន នៅក្នុងពិធីមង្គលការរបស់ នី នៅភ្នំពេញ ក្នុងរបប លន់ នល់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អីគាត់បាននិយាយភាសាបារាំងញឹកញាប់ជាមួយស៊ុំ។ ពីរបីថ្ងៃក្រោយមក ឪពុកខ្ញុំត្រូវបានប្រាប់ឲ្យចេញទៅដឹកជញ្ជូនអំបិលទៅសហករណ៍ផ្សេងទៀត។ ប៉ុន្តែមិនមានអំបិលនៅក្នុងសហករណ៍របស់យើងត្រូវដឹកជញ្ជូនទេ។ មុនពេលដែលឪពុកខ្ញុំចេញទៅ គាត់បានប្រាប់ម្តាយខ្ញុំឲ្យមើលថែទាំកូនៗទាំងអស់។ ម្តាយខ្ញុំបានតបថា ប្រសិនបើឪពុកខ្ញុំដឹងថា មានរឿងអាក្រក់នឹងកើតឡើង គាត់ត្រូវតែរត់គៀសខ្លួនចេញទៅ។ ខ្មែរក្រហមបានចាប់ឪពុកខ្ញុំប្រហែលមកពីគាត់និយាយភាសាបារាំង ហើយខ្មែរក្រហមគិតថា គាត់ជាខ្មាំងសត្រូវរបស់អង្គការ។

នៅព្រឹកបន្ទាប់ ខ្ញុំភ្ញាក់ឡើងយឺតពេល ដើម្បីនិយាយពាក្យថា លាហើយទៅកាន់ឪពុកខ្ញុំ ព្រោះគាត់បានចាកចេញទៅបាត់ហើយ។ ប្រជាជនមូលដ្ឋាននៅក្នុងសហករណ៍បានខ្សឹបប្រាប់ម្តាយខ្ញុំថា មិនបាច់ចាំឪពុកខ្ញុំទេ អង្គការបានបញ្ជូនគាត់ទៅសម្លាប់ហើយ។ បន្ទាប់ពីថ្ងៃនោះ បុរសម្នាក់ឈ្មោះ ហ៊ួន ដែលជាប្អូនប្រុសរបស់គណៈសហករណ៍ បានឃើញរូបថតរបស់ឪពុកខ្ញុំមួយសន្លឹក ហើយបានចោទគាត់ថាជាវរសេនីយ៍ឯក និងចោទខ្ញុំថាជាកូនស្រីរបស់ខ្មាំង។ ហ៊ួន បាននិយាយថា "នេះជាសាច់ញាតិរបស់ពួកអាណានិគមខ្មាំង។

គាត់បានប្រាប់អ្នកភូមិថា ឪពុកខ្ញុំជាអ្នកធាក់ស៊ីក្លូ ប៉ុន្តែ ការពិតគាត់ជានាយទាហាន"។ តាំងពីពេលនោះមក យើងមិនមានព័ត៌មានអំពីឪពុករបស់ខ្ញុំទេ ហើយខ្ញុំក៏មិនមានឱកាសកប់សាកសពរបស់គាត់ឲ្យបានត្រឹមត្រូវឡើយ។

ចម្លើយសារភាពរបស់ អ៊ុក តាត ពីទួលស្លែងមានប្រាំទំព័រវែង ដែលនិយាយថា គាត់ត្រូវបានចោទប្រកាន់ដោយបុរសម្នាក់ឈ្មោះ យិន ស៊ុម ដែលត្រូវបានចាប់ខ្លួន។ គាត់បានចោទប្រកាន់ អ៊ុក តាត ព្រោះអីគេបានជួបគ្នានៅតាមផ្លូវ អំឡុងពេលជម្លៀសចេញ និងពិភាក្សាអំពីសម្តេចសីហនុ ហ៊ូ យន់ និង ខៀវសំផន។

**ប៉ាង ពីច័ន្ទ និង ទេរី ខកហ្កៀល**

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់
## នៅក្នុងរបបខ្មែរក្រហម ចារទុកក្នុងសៀវភៅរំឭក
## វិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

*ផាន់ថាន់ រ៉ៅជារ៉ា និង ឡុង ដានី*

(តពីលេខមុន)

**តាច់ ឌី** *មានអាយុ៥០ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់លោកតា តាច់ និងលោកយាយ តុំ មានប្រពន្ធឈ្មោះ ឌឹម ហ៊ិន មានកូនប្រុស ៣នាក់ និងស្រី ៤នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកម្ពុស្រ៊ិ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០១ បន្ទប់តូច ៥។ ខ្មែរក្រហមចាប់បញ្ជូន តាច់ ឌី ឬ តាច ឌី ទៅដល់គុកទួលស្លែងនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។*

**តាន់ គឹមហ៊ាង** *ឬ តាន់ គឹមហៀង ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅ ស-២១យ ថ្ងៃ៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ សូមមើលព័ត៌មានលម្អិតខាងលើទាក់ទងនឹងឈ្មោះ តាង គឹមថា ឬ តាន់ គឹមថា។*

**តាន់ គឹមឆួន** *មានអាយុ២៩ឆ្នាំក្នុងឆ្នាំ១៩៧(៦) មានស្រុកកំណើតនៅជីក្រែង ខេត្តសៀមរាប ជាកូនរបស់ពូ តាន់ ឆួន និងមីង ហោ ឆន មានប្រពន្ធឈ្មោះ សំរិត យុនលី មានកូនស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៧(៦) ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ១ បន្ទប់តូច ៣។ ខ្មែរក្រហមចាប់បញ្ជូន តាន់ គឹមឆួន ពីស-២១យ ទៅដល់គុកទួលស្លែងនិងសម្លាប់នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ឬថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦។*

**តាន់ បូរ៉ា** *មានអាយុ៤៤ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅសំរោងទង ខេត្តកំពង់ស្ពឺ ជាកូនរបស់អ៊ំ តាន់ ឃិន និងអ៊ំស្រី យូរ ដូ មានប្ដីឈ្មោះ អ៊ូ លន់ មានកូនប្រុស ៩នាក់និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភូមិកំពង់ស្វាយ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក បន្ទប់ធំ ០៧ បន្ទប់តូច ១៩។ តាន់ បូរ៉ា ត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី២ ឬ ៥ ខែមីនា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។*

**តាន់ ផេង** *មានអាយុ៣៨ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតវេជ្ជបណ្ឌិត មានស្រុកកំណើតនៅសំរោង ខេត្តតាកែវ ជាកូនរបស់អ៊ំ តាន់ ឃុន និងអ៊ំស្រីង តាំង ពា មានប្រពន្ធឈ្មោះ តាន់ កិចឆេង ហៅ នាង មានកូនប្រុស ២នាក់ និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅជប់ ឃុំព្រះនេត្រព្រះ ថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០១ បន្ទប់ធំ ២។ ខ្មែរក្រហមចាប់បញ្ជូន តាន់ ផេង ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១០០ ថ្ងៃ។*

**តាន់ ស៊ីវឆេង** មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ពូ តាំង គីអាន និងមីង ទ្រី ប៊ុយ យ៉ុង មានប្តីឈ្មោះ តាន់ ស៊ីប៊ុន ហៅ ស៊ុំ ប៊ុន មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរ ក-១៥ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ តាន់ ឬ តាំង ស៊ីវឆេង នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៣ ថ្ងៃ។

**តាន់ សុកហួយ** ហៅ ជាតិ មានអាយុ៣១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅឆ្លូង ខេត្តក្រចេះ ជាកូនរបស់អ៊ំ កាក់ ផ្លួន និងអ៊ំស្រី ឈៀង ហន មានប្តីឈ្មោះ ខៃ ហេង ហៅ ណូ មានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបន្ទី ប-១ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ២។ ខ្មែរក្រហមសម្លាប់ តាន់ សុកហួយ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧។

**តាន់ សុខា** មានអាយុ៣៣ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្អាង ខេត្តកណ្តាល ជាកូនរបស់ អ៊ំ តាន់ ហួរ និងអ៊ំស្រី សៃ ហុង មានប្រពន្ធឈ្មោះ ជា អិន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកង១៣ ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឃ បន្ទប់ធំ ៤ បន្ទប់តូច ៣។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**តាយ ង៉ូវ** ហៅ វ៉ាន់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រ ជ-១ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន តាយ ង៉ូវ ទៅដល់គុកទួលស្លែងនៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**តាំង ខែត្ត** ហៅ ខាន់ មានអាយុ៤១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅជ្រោយញាវ ជាកូនរបស់អ៊ំ ខែស និងអ៊ំស្រី អ៊ាត មានប្រពន្ធឈ្មោះ ភីម ត្រូវបានខ្មែរក្រហមចាប់ខ្លួនភូមិភាគបស្ចិម ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ៤ បន្ទប់តូច ៦។ ខ្មែរក្រហមចាប់បញ្ជូន តាំង ខែត្ត ឬ តាំង ខែត ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦ ឬ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។

**តាំង ឆាន** ហៅ យាន ត្រូវបានខ្មែរក្រហមចាប់ខ្លួនកងពល៥០២ ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦។ (គ្មានក្នុងបញ្ជី)។

**តាំង ម៉េងហ៊ីរ** ហៅ ទី មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ពូ តាំង ម៉េងយូរលី និងមីង វង់ ង មានប្រពន្ធឈ្មោះ វង យុតគីង ហៅ គីម មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអង្គរបូរី ថ្ងៃទី២៦ ខែមិនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ០៥ បន្ទប់តូច ៦។ ខ្មែរក្រហមសម្លាប់ តាំង ម៉េងហ៊ីរ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦។

**តាំង វណ្ណាស៊ី** ហៅ ទូច អតីតទាហានជាងម៉ាស៊ីនយន្តហោះ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ តាឡី ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន តាំង វណ្ណាស៊ី ឬ តាំង វ៉ាន់ណាស៊ី ឬ តាំង វ៉ាន់ណាល់ ទៅដល់គុកទួលស្លែងនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៦ ថ្ងៃ។

**តាំង ខេច ស៊ីម** មានអាយុ៤៧ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅខេត្តកំពង់ចាម ជាកូនរបស់អ៊ំ តាំង សាន និងអ៊ំស្រី ណៃ គី មានប្តីឈ្មោះ គីម ស៊ីនួន ហៅ ស៊ីថន មានកូនប្រុស ៦នាក់និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភូមិព្រែកស្តី ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក

បន្ទប់ធំ ០៧ បន្ទប់តូច ២០។ ខ្មែរក្រហមចាប់បញ្ជូន តាំង វេច ស៊ីម ទៅដល់គុកទួលស្លែងនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។ គ្រួសារមួយនេះ គឹម ស៊ីនួន (ប្ដី), តាំង វេច ស៊ីម (ប្រពន្ធ), គឹម ស៊ីថា (កូន), គឹម សុផាន់ណា (កូន), គឹម ដារី (កូន), គឹម ប៉ារ៉ាឌី (កូន) ត្រូវបានខ្មែរក្រហមចាប់មកសម្លាប់ទាំងអស់។ សូមមើលព័ត៌មានលម្អិតតាមឈ្មោះនីមួយៗពីខាងដើម។

**តាំង ស៊ីវឡេង** មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតសាស្ត្រាចារ្យភូមិប្រវត្តិវិទ្យា មានស្រុកកំណើតនៅក្រចេះខេត្តក្រចេះ ជាកូនរបស់ពូ តាំង ទ្រាង និងមីង លី គិកឈុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបារាយណ៍ ថ្ងៃទី៧ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ៥ បន្ទប់តូច ៥។ ខ្មែរក្រហមចាប់បញ្ជូន តាំង ស៊ីវឡេង ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៧៦ ថ្ងៃ។

**តាំង សុខសារិន** ហៅ គឹម ស្រេង មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៧ អតីតនិស្សិតពេទ្យមកពីប៉េកាំង មានស្រុកកំណើតនៅបាទី ខេត្តតាកែវ ជាកូនរបស់ពូ តាំង ហួត និងមីង លី ស្រ៊ុយ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបឹងត្របែក ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ០១ បន្ទប់តូច ៧។ ខ្មែរក្រហមសម្លាប់ តាំង សុងសារិន ឬ តាំង គឹមស្រេង នៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៩ ថ្ងៃ។

**តាំង សេត ហៅ** សំអឿន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល២៩០ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន តាំង សេត ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៣៩ ថ្ងៃ។

**តាំង ហួយ** ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រតម្បាញ ត-៦។ ខ្មែរក្រហមចាប់បញ្ជូន តាំង ហួយ ឬ គាន់ ហួយ ទៅដល់គុកទួលស្លែងនៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១១ ថ្ងៃ។

**តាំង អ៊ិល** មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូ រស់ តាំង និងមីង ឈឹម អ៊ឹម ត្រូវបានខ្មែរក្រហមចាប់ខ្លួនស្រុកបារាយណ៍ ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន តាំង អ៊ិល ទៅដល់គុកទួលស្លែងនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៣ ថ្ងៃ។

**តឹក សេងអេង** មានអាយុ៥៤ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់ស្វាយ ខេត្តកំពង់ធំ ជាកូនរបស់លោកតា ជូ និងលោកយាយ ឃិម មានប្រពន្ធឈ្មោះ តិក សេងអេង មានកូនប្រុស ៤នាក់ និងស្រី ៦នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនរទេះភ្លើង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ ៤ បន្ទប់តូច ៩។ ខ្មែរក្រហមចាប់បញ្ជូន តឹក សេងអេង ឬ តឹក សេងអេង ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ២៧៦ ថ្ងៃ។

**តី ហ៊ុន** ហៅ តី ហាគ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន តីហ៊ុន ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៩ ថ្ងៃ។

**តឹក គាំសិទី** ហៅ រី មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅមោងឫស្សី ខេត្តបាត់ដំបង ជាកូនរបស់ពូ តឹក សេងអេង និងមីង ម៉ក់ ណយស៊ុម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរទេះភ្លើង ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦ គឺចាប់ខ្លួននៅថ្ងៃជាមួយឪពុកដែរ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ៥ បន្ទប់តូច ៥។ ខ្មែរក្រហមសម្លាប់ តឹក គាំសិរី ហៅ រី នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧ ថ្ងៃ។

**តឹក ចន្ថា** មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកោះសូទិន ខេត្តកំពង់ចាម ជាកូនរបស់ពូ អៀវ គឹមសាន និងមីង នៅ ស៊ុយីម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុក១៦ តំបន់ ២៥ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១០ បន្ទប់ធំ ៤។ ខ្មែរក្រហមចាប់បញ្ជូន តឹក ចន្ថាបុ តឹក ចាន់ថា ទៅដល់គុកទួលស្លែងនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៥៣ ថ្ងៃ។

**តឹក គូ** មានអាយុ៤២ឆ្នាំក្នុងឆ្នាំ១៩៧៥ អតីតវេជ្ជបណ្ឌិត មានស្រុកកំណើតនៅខេត្តស្ទឹងត្រែង ជាកូនរបស់អ៊ំ តឹក ម៉េងហោរ និងអ៊ំស្រី លិម ធួន មានប្រពន្ធឈ្មោះ វ៉ាវ វ៉ែនសុន ហៅ អុក មានកូនប្រុស ២នាក់ និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៧៥ នៅភូមិក្តីចាស់ ឃុំបាក់ខែង ស្រុកមុខកំពូល តំបន់២៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៧ បន្ទប់លេខ ៨។ ខ្មែរក្រហមចាប់បញ្ជូន តឹក គូ ជាដំណាក់ៗ ដូចជា បញ្ជូនទៅរកាកោងនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៥, ទៅព្រែកពោធិ៍នៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៦, ទៅដល់ភ្នំពេញនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦។ អង្គការបានឲ្យប្រពន្ធ និងកូន ៣នាក់ ព្រមទាំងម្តាយក្មេក និងប្អូនថ្លៃ មកតាមខ្លួនដល់ភ្នំពេញនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦។ តឹក គូ ត្រូវបានខ្មែរក្រហមចាប់បញ្ជូន ទៅដល់គុកទួលស្លែងនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ដូចកំណត់សម្គាល់ខាងលើ និងសម្លាប់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៣៣៦ ថ្ងៃ។

**តឹម សំ** ហៅ តឹម សែម មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូ តឹម និងមីង ជួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ៤ បន្ទប់តូច ២។ ខ្មែរក្រហមចាប់បញ្ជូន តឹម សំ ទៅដល់គុកទួលស្លែងនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១០៣ ថ្ងៃ។

**តុង ប៉ោត** មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅស្រុក២០ ខេត្តកណ្តាល ជាកូនរបស់ពូ ស៊ុយ តុង និងមីង អៀម ហៀក ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅវត្តស្រះស្រង់ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៣ បន្ទប់តូច ១០។ ខ្មែរក្រហមចាប់បញ្ជូន តុង ប៉ោត ពីមន្ទីរស-២១យ ទៅដល់គុកទួលស្លែងនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៦ (តាមឯកសារ)។

**តុង អេង** ហៅ ធឿន មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅទូកមាស ខេត្តកំពត ជាកូនរបស់ពូ តុង សុង និងមីង ភឹម ឈួន មានប្តីឈ្មោះ ធឿន ឡឿន មានកូនប្រុស ២នាក់និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរទេះភ្លើង ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ៥ បន្ទប់តូច ១១។ ខ្មែរក្រហមចាប់បញ្ជូន តុង អេង

ទៅដល់គុកទួលស្លែងនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។ ប្តីឈ្មោះ ធឿន ឡឿន ឬ ម៉ម ឡឿន ឬ វ៉ាត ឡឿន ត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី១៥ ឬ ១៧ ខែមិថុនា ឆ្នាំ១៩៧៨ តែនៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**គុញ ធន** ហៅ សំអាត មានអាយុ៤២ឆ្នាំក្នុងឆ្នាំ១៩៧(៦) មានស្រុកកំណើតនៅឈូក ខេត្តកំពត ជាកូនរបស់អ៊ុំ ចិន គុញ និងអ៊ុំស្រី អ៊ុក ខាន់ មានប្រពន្ធឈ្មោះ សាភឿនហៅ ម៉ែនមានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបឹងត្របែកខាងត្បូង ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧(៦) ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ ៥ បន្ទប់តូច ៤។ ខ្មែរក្រហមចាប់បញ្ជូន គុញ ទន ទៅដល់គុកទួលស្លែងនៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៩ ថ្ងៃ។

**គុន គូ** មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅសន្ទុក ខេត្តកំពង់ធំ ជាកូនរបស់ពូ ជួប គុន និងមីង នុត ឡុង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ៤ បន្ទប់តូច ៩។ ខ្មែរក្រហមសម្លាប់ គុន គូ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ២៨ ថ្ងៃ។

**គុប ង៉ូវឡេង** ហៅ គុប ម៉ុង មានអាយុ២៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្អាង ខេត្តកណ្តាល ជាកូនរបស់ពូ គុប សៀក ស្រ៊ុន និងមីង ណៃ គី មានប្រពន្ធឈ្មោះ ង៉ិច សេង មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអគ្គីសនីទី២ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ៤ បន្ទប់តូច ១០។ ខ្មែរក្រហមសម្លាប់ គុប ង៉ូវឡេង នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៣ ថ្ងៃ។

**គុប សៀប** មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅអង្គស្នួល (ខេត្តកណ្តាល) ជាកូនរបស់ពូ សឹង សឿង និងមីង ហន ត្រូវបានខ្មែរក្រហមចាប់ខ្លួនមន្ទីរពេទ្យ ១៧ មេសា ថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ២ បន្ទប់តូច ១២។ ខ្មែរក្រហមចាប់បញ្ជូន គុប សៀប ទៅដល់គុកទួលស្លែងនៅថ្ងៃទី៥ ឬ ៧ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។

**គុប ស្រ៊ុន** ជាឪពុករបស់ គុប ម៉ុង (ឈ្មោះខាងលើ) ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអគ្គិសនីទី២ ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ គុប ស្រុនឬ ស្រ៊ុន នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១ ថ្ងៃ។ កូនប្រសាររបស់គាត់ឈ្មោះ ង៉ិច សេង ជាប្រពន្ធរបស់ គុប ម៉ុង ត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១ ថ្ងៃ។

**គុំ ផាន់ដារ៉េត** មានអាយុ១៨ឆ្នាំក្នុងឆ្នាំ១៩៧៥ កូនសិស្សថ្នាក់ទី៧ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ពូ គុំ សាវ៉ាវ៉ាន់ និងមីង ហ៊ុយ សុខុន ត្រូវបានខ្មែរក្រហមចាប់ខ្លួនព្រែកពោធិ៍ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០១ បន្ទប់តូច ១២។ (គ្មានក្នុងបញ្ជី)។

**តូច សាភាព** មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រីសន្ធរ ខេត្តកំពង់ចាម ជាកូនរបស់ពូ ជា ផាន និងមីង សំ អឹម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៦

ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០១ បន្ទប់ធំ ៣។ ខ្មែរក្រហមចាប់បញ្ជូន គួច សាភាព ឬ គួច សុភាព ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១២៨ ថ្ងៃ។

**គួច អឿន** ហៅ ឈឿន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពាណិជ្ជកម្មក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន គួច អឿន ឬ គួច ឈឿន ទៅដល់គុកទួលស្លែងនៅថ្ងៃទី ១២ ឬ ១៣ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី ៦ ខែធ្នូ ឆ្នាំ១៩៧៦។

**គួច អែម** ហៅ ភាព ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន គួច អែម ឬ គួច ឯម ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ១៩៧៦ និងសម្លាប់នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៣៦ ថ្ងៃ។

**គេង សិន** មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្អាង ខេត្តកណ្ដាល ជាកូនរបស់ពូ គេង ស៊ីម និងមីង នូ យ៉ាន់ មានប្រពន្ធឈ្មោះ ជួន សំអុល មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ៦ បន្ទប់តូច ៤។ ខ្មែរក្រហមចាប់បញ្ជូន គេង សិន ទៅដល់គុកទួលស្លែងនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៥ ថ្ងៃ។

**គេង សុខ** មានអាយុ២៤ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅកំពង់ត្រាច ខេត្តកំពត ជាកូនរបស់ពូ យី ទៀន និងមីង គុត ឡាយ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្ទឹងមានជ័យ កន្លែងកងវរសេនាតូច ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ០៧ បន្ទប់តូច ១៦។ ខ្មែរក្រហមចាប់បញ្ជូន គេង សុខ ឬ គេង សុក ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៤១ ថ្ងៃ។

**តែ លាងសេង** ហៅ ទី លុច មានអាយុ២៥ឆ្នាំក្នុងឆ្នាំ ១៩៧៦ មានស្រុកកំណើតនៅស្រីសន្ធរ ខេត្តកំពង់ចាម ជាកូនរបស់ពូ តែ ម៉េងហេង និងមីង សេង ណៃ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរទេះភ្លើងភ្នំពេញ ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន តែ លាងសេង ទៅដល់គុកទួលស្លែងនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៦៩ ថ្ងៃ។

**តែម សូផុន** ហៅ ជឹម មានអាយុ៤០ឆ្នាំក្នុងឆ្នាំ ១៩៧៥ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់អ៊ំ តែម ហ៊ាងកេត មានប្រពន្ធឈ្មោះ គឹម ហុង មានកូនប្រុស ២នាក់ និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនរោងចក្រកង់ឡានរដ្ឋ-តាខ្មៅ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៨ បន្ទប់ធំ ៩។ ខ្មែរក្រហមសម្លាប់ តែម សូផុន ឬ តែម សុផុន ក្នុងឆ្នាំ១៩៧៦។

**តៃ សេង** មានអាយុ៣៨ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកណ្ដាលស្ទឹង ខេត្តកណ្ដាល ជាកូនរបស់ពូ បាក់ កែ និងមីង គី ហ៊ាង ត្រូវបានខ្មែរក្រហមចាប់ខ្លួនរោងចក្រ ត-៣ ថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៧។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**តោ ឈុន** មានអាយុ៤២ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតសាស្ត្រាចារ្យ មានស្រុកកំណើតនៅកំចាយមារ ខេត្តព្រៃវែង ជាកូនរបស់អ៊ំ តោ អន និងអ៊ំស្រី បេះ ស៊ុនមានប្រពន្ធឈ្មោះ ជា ស៊ុន្ធន មានកូនប្រុស ៤នាក់ និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៦ នៅ”ភូមិគោកតាវាជ ស្រុកភ្នំស្រុក

បាត់ដំបង (កន្លែងដែលអង្គការទើបបញ្ជូនទៅក្នុង១ខែ)” ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៨ បន្ទប់លេខ១១។ ខ្មែរក្រហមចាប់បញ្ជូន គោ ឈុន ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៩ ថ្ងៃ។ រីឯប្រពន្ធឈ្មោះ ជា ស៊ុន្ទួន ត្រូវបានខ្មែរក្រហមចាប់បញ្ជូនពីស-២១យ ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៣ ឬ ១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦។

**ត្រាំ គឹមយូយ** អតីតគ្រូបង្រៀន ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅតាឡីក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ត្រាំ គឹមយូយ ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧៥ ថ្ងៃ។

**ត្រាំង ទី** មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅសំរោងទង ខេត្តកំពង់ស្ពឺ ជាកូនរបស់ពូ ត្រាំង យូហេង និងមីង សេង គី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅការដ្ឋានមន្ទីរ៩០ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០១ បន្ទប់តូច ៧។ ខ្មែរក្រហមចាប់បញ្ជូន ត្រាំង វី ទៅដល់គុកទួលស្លែងនៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១១៤ ថ្ងៃ។

**ត្រឹង ខួន** ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំបាសិតក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ត្រឹង ផ្ទួន ទៅដល់គុកទួលស្លែងនៅថ្ងៃទី១២ ឬ ១៣ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦។

**ត្រឹង យ៉ាងកែវ** មានអាយុ៥០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅអាងភូខេត្តឡុងចូវទៀន ឪពុកម្តាយឈ្មោះ ត្រឹង យាំងយូវ និង ង្វៀង ធីជីវ មានប្រពន្ធឈ្មោះ ង្វៀង ធីណាំ មានកូនប្រុស ១នាក់និងស្រី ៥នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព្រែកស្បូវ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០២ បន្ទប់តូច ១។ ខ្មែរក្រហមចាប់បញ្ជូន ត្រឹង យ៉ាងកែវ ឬ ត្រឹង យ៉ាងកាវ ទៅដល់គុកទួលស្លែងនៅថ្ងៃទី២ ឬ ៤ ឬ ៥ ខែមីនា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**(តនៅលេខក្រោយ)**

## ការបោះពុម្ពផ្សាយរឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

ទស្សនាវដ្ដីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមថាប្រជាជនកម្ពុជាគ្រប់រូប និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅ អំពីរឿងរ៉ាវពិតផ្ទាល់ខ្លួនទាក់ទងនឹងរបបខ្មែរក្រហម ហើយមានបំណងផ្សព្វផ្សាយ សូមផ្ញើមកទស្សនាវដ្ដីស្វែងរកការពិតតាមអាសយដ្ឋាន ៖
ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជណាចក្រកម្ពុជា។
ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥ ឬ (៨៥៥) ៩៩៦ ៧៥០
អ៊ីម៉ែល៖ truthbunthorn.s@dccam.org - គេហទំព័រ៖ www.dccam.org

រូបថតក្របមុខ៖
ប្រជាជនចាកចេញពីផ្ទះសម្បែងតាមបញ្ជារបស់យោធាខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
ប្រជាជនបានវិលត្រឡប់មកផ្ទះសម្បែងវិញ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org
A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 244, April 2020 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.